សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ការអនុវត្តសិទ្ធិ និងយន្តការដោះស្រាយ វិវាទលើប្រកាសនីយបត្រតក្កកម្ម នៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **គីម លីហ៊ាង**

សាស្ត្រាចារ្យណែនាំ

លោក **ទេព សុខ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៨ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

## សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទឈ្មោះ **គីម លីហ៊ាង** និស្សិត (ក្រុម $L_4B_1$) ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៥-២០១៩ ។

## ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ

ជីដូនឈ្មោះ **អ៊ឹង ស្រ៊ន់** និងលោកឪពុកឈ្មោះ **ទ៉ា ស្រ៊េង** ជាទីគោរព ហើយមាននូវមហាគុណដ៏ឧត្តុងឧត្តម និងធំធេងបំផុតគ្មានអ្វីមកប្រៀបស្មើរបាន និងមិនអាចបំភ្លេចបានក្នុងជីវិតកូនចៅ ព្រោះលោកទាំងពីរជាអ្នកទំនុកបម្រុងទាំងការរស់នៅ និងការសិក្សារៀនសូត្រ ផ្តល់ភាពកក់ក្តៅតាំងពីកូននៅតូចៗ រហូតដល់ធំដឹងក្តី លោកតែងតែអប់រំ ទូន្មានប្រៀនប្រដៅឲ្យកូនជៀសឆ្ងាយពីគ្រឿងឧបាយមិនល្អ ឲ្យកូនសេពគប់មនុស្សល្អ និងលត់ដំខ្លួនឲ្យក្លាយទៅជាមនុស្សល្អនៅក្នុងសង្គម។ ត្បិតតែលោកទាំងពីរជាគ្រួសារក្រីក្រ ត្រកូលកសិករ ប៉ុន្តែលោកទាំងពីរខិតខំប្រឹងប្រែង មិនខ្លាចនឿយកាយ រិះរកគ្រប់របរ ធ្វើយ៉ាងណាបញ្ជូនកូនៗគ្រប់គ្នាឲ្យបានចូលសាលា និងសិក្សាឲ្យបានចប់ថ្នាក់ខ្ពស់ ព្រោះលោកមិនចង់ឃើញកូនៗរបស់លោកជាមនុស្សល្ងង់ខ្លៅ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រី សាស្ត្រាចារ្យ បុគ្គលិកការិយាល័យសិក្សា ការិយាល័យស្រាវជ្រាវ ព្រមទាំងបណ្ណារក្សទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកម្លាំងកាយ កម្លាំងចិត្តក្នុងការដឹកនាំ គ្រប់គ្រង ជ្រោមជ្រែង និងបង្ហាត់បង្រៀនដល់ខ្ញុំបាទឲ្យទទួលបាននូវចំណេះដឹងយ៉ាងច្រើនកន្លងមកនេះ។

លោកសាស្ត្រាចារ្យណែនាំ **ទេព សុខ** លោកបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ និងចំណាយពេលវេលាផ្ទាល់ខ្លួនដ៏មានតម្លៃក្នុងការជួយពន្យល់ណែនាំ ផ្តល់មតិយោបល់ល្អៗ និងផ្តល់ឯកសារមួយចំនួន ព្រមជួយកែសម្រួល កែតម្រូវយ៉ាងយកចិត្តទុកដាក់បំផុតរហូតសារណាមួយក្បាលនេះបានបញ្ចប់ និងលេចចេញជារូបរៀងឡើងបានដោយជោគជ័យ។

មិត្តរួមថ្នាក់ឈ្មោះ **ធី ពិសី** ដែលបានចំណាយពេលវេលាមានតម្លៃខិតខំជួយកែលម្អចំណុចខ្វះខាត សម្រួលឃ្លា និងពិនិត្យអក្ខរាវិរុទ្ធ។

ជាចុងក្រោយខ្ញុំបាទ សូមសម្តែងនូវសេចក្តីគោរព និងអំណរគុណយ៉ាងជ្រាលជ្រៅ ជាពិសេសសូមបួងសួងវត្ថុស័ក្តិសិទ្ធិទាំងឡាយជួយតាមថែរក្សាលោកអ្នកមានគុណឲ្យជួបតែសេចក្តីសុខ។

# អារម្ភកថា

ចាប់តាំងពីបានចូលសិក្សានៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេល ៤ឆ្នាំមក ខ្ញុំបាទទទួលបានចំណេះដឹងជាច្រើនទាំងនិតិឯកជន និងនីតិសាធារណៈ។ ដោយចង់បន្សល់ស្នាដៃបន្តិចបន្តួចសម្រាប់ប្អូនៗជំនាន់ក្រោយ ខ្ញុំបាទបានសម្រេចចិត្តចាប់ សរសេរសារណាក្រោមប្រធានបទស្តីអំពី **ការអនុវត្តសិទ្ធ និងយន្តការដោះស្រាយវិវាទលើប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា។** ការលេចចេញនូវស្នាដៃនេះឡើងគឺសុទ្ធតែមានការជ្រោមជ្រែងយ៉ាងយកចិត្តទុកដាក់បំផុតពីសំណាក់សាស្ត្រាចារ្យណែនាំ និងមិត្តភ័ក្ត្រដែលបានជួយពិគ្រោះ និងឲ្យយោបល់។ សមិទ្ធិផលនេះខ្ញុំសូមនិយាយថាគឺជាសមិទ្ធិផលរួម ដើម្បីទុកជាឯកសារដែលមានសារសំខាន់សម្រាប់សិស្សនិស្សិតជំនាន់ក្រោយក្នុងការសិក្សាស្វែងយល់អំពីបញ្ហានេះ។

ខ្ញុំបាទជឿជាក់ថាសារណាមួយក្បាលនេះនៅមានចំណុចខ្វះខាត មិនទាន់មានភាពល្អឥតខ្ចោះ ដែលបណ្តាលមកពីការស្រាយជ្រាវមិនគ្រប់ជ្រុងជ្រោយ ឬមិនបានជិតដល់ពីបញ្ហាណាមួយ ប៉ុន្តែខ្ញុំបាទសង្ឃឹមថាសារណានេះអាជាឯកសារមួយសម្រាប់ប្អូនៗនិស្សិតជំនាន់ក្រោយក្នុងការសិក្សា និងដកយកចំណុចខ្លះៗដើម្បីបំពេញការស្រាវជ្រាវរបស់ពួកគាត់។

សៀវភៅសារណាមួយក្បាលនេះគឺជាស្នាដៃដំបូងបង្អស់របស់ខ្ញុំបាទ ដោយបានខិតខំ និងតស៊ូ សិក្សាស្រាវជ្រាវ ព្រមទាំងត្រង់ត្រាប់ស្តាប់រាល់ការបង្រៀនរបស់សាស្ត្រាចារ្យទាំងអស់។ ចំពោះការស្រាវជ្រាវមានការលំបាកស្វែងរកឯកសារពាក់ព័ន្ធ ប៉ុន្តដោយសារមានការពន្យល់ណែនាំ និងកែតម្រូវយ៉ាងយកចិត្តទុកដាក់ពីសាស្ត្រាចារ្យណែនាំ **ខេព សុខ** ទើបសារណានេះប្រសូតចេញជារូបរាងឡើង។

ជាចុងក្រោយ ខ្ញុំបាទរង់ចាំទទួលយកនូវមតិរិះគន់ពីគ្រប់មជ្ឈដ្ឋាននានាក្នុងគោលបំណងដើម្បីកែរលម្អនូវរាល់កំហុសឆ្គងទាំងឡាយពីសំណាក់សាស្ត្រាចារ្យ មិត្តនិស្សិត និងមិត្តអ្នកអានទាំងឡាយដោយសេចក្តីគោរពរាប់អាន

# មាតិកា


សេចក្តីផ្តើម ... ១

## ជំពូកទី១

## សញ្ញាណគតិយុត្តនៃប្រកាសនីយបត្រក្កកម្ម

ផ្នែកទី១. ប្រកាសនីយបត្រតក្កកម្ម ... ៤

១. និយមន័យនៃប្រកាសនីយបត្រក្កកម្ម ... ៤

១.១ និយមន័យនៃប្រកាសនីយបត្រក្កកម្ម ... ៤

១.២ ឋានៈជាម្ចាស់នៃប្រកាសនីយបត្រក្កកម្ម ... ៤

២. អត្ថប្រយោជន៍នៃប្រកាសនីយបត្រក្កកម្ម ... ៥

២.១ សិទ្ធិផ្តាច់មុខ និងឧត្តមភាពលើទីផ្សារ ... ៦

២.២ ថាមពលក្នុងការចរចារ និងរូបភាពវិជ្ជមានដល់សហគ្រាស ... ៧

ផ្នែកទី២: តក្កករ និង តក្កកម្ម ... ៧

១. តក្កករ ... ៧

១.១ និយមន័យនៃតក្កករ ... ៧

១.២ ប្រភេទតក្កករ និង ការដាក់ឈ្មោះតក្កករ ... ៨

១.២.១ ប្រភេទតក្កករ ... ៨

១.២.២ ការដាក់ឈ្មោះតក្កករ ... ៩

២. តក្កកម្ម ... ៩

២.១ និយមន័យតក្កកម្ម ... ៩

២.២ តក្កកម្មដែលមិនមែនជាកម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្ម ... ១០

២.៣ ប្រព័ន្ធ First to file និង ប្រព័ន្ធ First to invent ... ១០

## ជំពូកទី២

## និតិវិធីនៃការផ្តល់ប្រកាសនីយបត្រក្កកម្ម

ផ្នែកទី១: ការដាក់ពាក្យសុំ ... ១២

១. សមត្ថកិច្ចទទួលបន្ទុកពាក្យស្នើសុំ ... ១២

១.១ ការបង្កើត និងតួនាទីនៃនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ... ១២

១.២ ការិយាល័យប្រកាសនីយបត្រក្កកម្ម ... ១៤

២. សំណុំឯកសារចាំបាច់សម្រាប់ការដាក់ពាក្យសុំ ... ១៥

២.១ សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ........ ១៥
២.១.១ ពាក្យសុំ ........ ១៥
២.១.២ សេចក្តីអធិប្បាយពីតក្កកម្ម ........ ១៦
២.១.៣ សេចក្តីអះអាង ........ ១៦
២.១.៤ គំនូសបង្ហាញ ........ ១៦
២.១.៥ ខ្លឹមសារសង្ខេប ........ ១៦
២.២ ប្រកាសនីយបត្រតក្កកម្មបរទេស ........ ១៧
២.២.១ សំណុំលិខិតស្នើសុំនៅឯបរទេស ........ ១៧
២.២.២ សិទ្ធិអាទិភាពនៃសំណុំស្នើសុំ ........ ១៧
២.៣ ការកែតម្រូវ ការដកយកទៅវិញ និងការបំបែកសំណុំលិខិតស្នើសុំ ........ ១៨
២.៣.១ ការកែតម្រូវ ការដកយកទៅវិញសំណុំលិខិតស្នើសុំ ........ ១៨
២.៣.២ ការបំបែកសំណុំលិខិតស្នើសុំ ........ ១៨
២.៤ ការពិនិត្យសំណុំស្នើសុំ ........ ១៨
ផ្នែកទី២ ការត្រួតពិនិត្យខ្លឹមសារនៃតក្កកម្ម ........ ១៩
១. តក្កកម្មថ្មី ........ ១៩
២. ជំហានរកឃើញថ្មី ........ ២០
៣. អាចយកទៅអនុវត្តបានក្នុងវិស័យឧស្សាហកម្ម ........ ២០
ផ្នែកទី៣ ការសម្រេចលើប្រកាសនីយបត្រតក្កកម្ម ........ ២២
១.ការសម្រេចបដិសេធការផ្តល់ប្រកាសនីយបត្រតក្កកម្ម ........ ២២
១.១ មូលដ្ឋាននៃការបដិសេធ ........ ២៣
២. ការសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្ម ........ ២៤
២.១ ការជូនដំណឹងពីការផ្តល់ប្រកាសនីយបត្រតក្កកម្ម ........ ២៤
២.២ ការប្រកាសផ្សាយអំពីការផ្តល់ប្រកាសនីយបត្រតក្កកម្ម ........ ២៥
២.៣ រយៈពេលនៃការការពារ ........ ២៥
ផ្នែកទី៤ ភាតព្វកិច្ចដែលកើតចេញពីប្រកាសនីយបត្រតក្កកម្ម ........ ២៥
១. ភាតព្វកិច្ចដែលកើតចេញពីប្រកាសនីយបត្រតក្កកម្ម ........ ២៥
១.១ ភាតព្វកិច្ចបង់កម្រៃប្រចាំឆ្នាំ ........ ២៥
១.២ ភាតព្វកិច្ចធ្វើអាជីវកម្មលើតក្កកម្ម ........ ២៦
២. មោឃភាពនៃប្រកាសនីយបត្រតក្កកម្ម ........ ២៧

២.១ មូលហេតុនៃមោឃភាព.....២៧

## ជំពូកទី៣
## សិទ្ធិដែលកើតចេញពីប្រកាសនីយបត្រតក្កកម្ម ការរំលោភសិទ្ធិ និងយន្តការដោះស្រាយវិវាទ

ផ្នែកទី១ សិទ្ធិដែលកើតចេញពីប្រកាសនីយបត្រតក្កកម្ម .....២៨
១. ទំហំនៃសិទ្ធិ .....២៨
១.១ ការធ្វើអាជីវកម្មដោយម្ចាស់សិទ្ធិ.....២៨
១.២ ការកម្រិតសិទ្ធិធ្វើអាជីវកម្ម .....២៨
២. អាជីវកម្មដោយរដ្ឋាភិបាល និងអាជ្ញាប័ណ្ណបញ្ជា .....២៩
២.១ អាជីវកម្មដោយរដ្ឋាភិបាល .....២៩
២.២ អាជ្ញាប័ណ្ណបញ្ជា .....៣០
២.២.១ លក្ខខណ្ឌនៃការចេញអាជ្ញាប័ណ្ណបញ្ជា .....៣១
២.២.២ សេចក្តីសម្រេចចេញអាជ្ញាប័ណ្ណបញ្ជា .....៣១
២.២.៣ សិទ្ធិរបស់អ្នកទទួលបានអាជ្ញាប័ណ្ណបញ្ជា.....៣១
ផ្នែកទី២ ការរំលោភសិទ្ធិ និងយន្តការដោះស្រាយវិវាទ .....៣១
១. ការរំលោភសិទ្ធិ .....៣១
១.១ និយមន័យនៃការរំលោភសិទ្ធិ.....៣២
២. យន្តការដោះស្រាយវិវាទ.....៣២
២.១ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ .....៣២
២.២ ដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ .....៣៣
សេចក្តីសន្និដ្ឋាន.....៣៥
គន្ថនិទ្ទេស
ឧបសម្ព័ន្ធ

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រកាសនីយបត្រតក្កកម្មបានចាប់កំណើត និងមានការវិវត្តន៍អស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ ប៉ុន្តែគេសង្កេតឃើញមានទ្រង់ទ្រាយច្បាស់លាស់នៅក្នុងការប្រគល់នូវប្រកាសនីយបត្រតក្កកម្មនៅឆ្នាំ១៧០០ ដោយមានចែងក្នុងរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកដែលផ្តល់អំណាចដល់ សភាខនក្រិស( Congress ) ក្នុងការការពារប្រកាសនីយបត្រក្កកម្ម និងស្នាដៃតែងនិពន្ធ[1]។ សព្វថ្ងៃនេះប្រព័ន្ធប្រកាសនីយបត្រក្កកម្មនេះ ត្រូវបានអភិវឌ្ឍន៍ឲ្យក្លាយទៅជា ប្រព័ន្ធអន្តរជាតិមួយយ៉ាងទំនើបដោយប្រកាសនីយប្រតក្កកម្មនេះ ត្រូវបានការពារតាមរយៈសន្ធិសញ្ញាសហប្រតិបត្តិការ ប្រកាសនីយបត្រតក្កកម្ម **PCT (Patent Cooperation Treaty)** និងអនុសញ្ញាទីក្រុងប៉ារីស **(Paris Convention)**។

រីឯប្រទេសកម្ពុជាយើងវិញវិស័យកម្មសិទ្ធិបញ្ញា ទើបតែមានការយកចិត្តទុកដាក់ នាក្នុងអំឡុងពេលដែលកម្ពុជាត្រៀមចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកតែប៉ុណ្ណោះ។ ជាលទ្ធផលយើងមានច្បាប់ស្តីអំពីប្រកាសនីយប្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដើម្បីធ្វើការការពាលើវិស័យនេះ ព្រមទាំងលើកស្ទួយវិស័យកម្មសិទ្ធិបញ្ញា ដែលច្បាប់នេះ សភាបានអនុម័តនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៣។ ច្បាប់នេះពាក់ព័ន្ធនឹងអ្វីដែលគេហៅថាកម្មសិទ្ធិបញ្ញាផ្នែកឧស្សាហកម្ម[2]។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវប្រធានបទស្តីពី **ការអនុវត្តសិទ្ធិ និងយន្តការដោះស្រាយវិវាទសិទ្ធិលើប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា** បានចោទជាបញ្ហាមួយចំនួនដូចជា៖

តើអ្វីទៅជាប្រកាសនីយបត្រតក្កកម្ម? តើច្បាប់កម្ពុជាបានកំណត់បញ្ហាអ្វីខ្លះពាក់ព័ន្ធទៅនឹងប្រកាសនីយបត្រតក្កកម្មនេះ?

ដើម្បីទទួលបានប្រកាសនីយបត្រតក្កកម្ម តើតក្កករចាំបាច់ត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ?

តើស្ថាប័នណាមានសមត្ថកិច្ចសម្រាប់ការផ្តល់ប្រកាសនីយបត្រតក្កកម្ម?

ប្រសិនបើតក្កកម្មត្រូវបានបដិសេធក្នុងប្រទេសកម្ពុជា តើតក្កករអាចយកតក្កម្មរបស់ខ្លួនទៅចុះបញ្ជីនៅឯបរទេសបានដែលឬទេ?

---

[1] www.wipo.com

[2] សៀវភៅនីតិកម្មសិទ្ធិបញ្ញា របស់សាស្ត្រាចារ្យ អ៊ុក វណ្ណារ័ត្ន ទំព័រ១៦

តើមានយន្តការដោះស្រាយយ៉ាងណាខ្លះ ប្រសិនបើមានវិវាទកើតឡើងនៅពេលកំពុងអនុវត្តសិទ្ធិលើប្រកាសនីយបត្រតក្កកម្ម?

**៣ គោលបំណងនៃការស្រាវជ្រាវ**

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺមានគោលបំណងចង់ស្វែងយល់អំពីនីតិវិធី និងដំណើរការនៃការផ្តល់ប្រកាសនីយបត្រតក្កកម្មនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ។

**៤. ដែនកំណត់នៃការស្រាវជ្រាវ**

ការសិក្សាស្រាវជ្រាវនេះ មានដែនកំណត់ និងវិសាលភាពគ្របដណ្តប់តែទៅលើសកម្មភាពដែលទាក់ទងទៅនឹងប្រកាសនីយបត្រតក្កកម្មតែប៉ុណ្ណោះ។ ដូច្នេះនៅក្នុង ប្រធានបទស្តីពីការអនុវត្តសិទ្ធិ និងយន្តការដោះស្រាយវិវាទលើប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា។

យើងនឹងបកស្រាយទៅលើចំណុចមួយចំនួនទាក់ទងទៅនឹងដំណើរការនៃការផ្តល់ប្រកាសនីយបត្រតក្កកម្ម នីតិវិធីនៃការស្នើសុំ បញ្ហានៃវិវាទ និងយន្តការនៃការដោះស្រាយវិវាទ គឺដោយកំណត់យក**ចាប់ពីឆ្នាំ១៩៩៩ រហូតដល់ឆ្នាំ២០១៩ ព្រោះនៅឆ្នាំ១៩៩៩ ជាឆ្នាំដែលកម្ពុជា**ចាប់ផ្តើមបង្កើតគណៈកម្មការកម្មសិទ្ធិបញ្ញា។

**៥. វិធីសាស្ត្រស្រាវជ្រាវ**

ការស្រាវជ្រាវទៅលើប្រធានបទស្តីពី ប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា នេះគ្រាន់តែជាសារណាបញ្ចប់ ការសិក្សាប៉ុណ្ណោះ ដូច្នេះយើងខ្ញុំស្រាវជ្រាវ និងដកស្រង់ទៅតាមឯកសារដែលមានស្រាប់ដូចជា៖

- ច្បាប់ លិខិតបទដ្ឋានគតិយុត្តិនានា
- សៀវភៅ របាយការណ៍ និងឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងប្រធានបទសារណានេះ
- និងស្រាវជ្រាវតាមបណ្តាញអ៊ីនធើនេតជាដើម។

**៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**

រចនាសម្ព័ន្ធនៃការស្រាវជ្រាវលើប្រធានបទ ការអនុវត្តសិទ្ធិ និងយន្តការដោះស្រាយវិវាទ លើប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា ត្រូវបានរៀបចំដូចខាងក្រោម៖

-សេចក្តីផ្តើម

-ជំពូកទី១៖ គឺអំពី សញ្ញាណគតិយុត្តនៃប្រកាសនីយបត្រតក្កកម្ម យកមកបកស្រាយ។

-ជំពូកទី២៖ គឺអំពី នីតិវិធីនៃការផ្តល់ប្រកាសនីយបត្រតក្កកម្ម យកមកបកស្រាយ។

-ជំពូកទី៣៖ គឺអំពី សិទ្ធិដែលកើតចេញពីប្រកាសនីយបត្រតក្កកម្ម ការរំលោភសិទ្ធិ និងយន្តការដោះស្រាយវិវាទ យកមកបកស្រាយ។

-សេចក្តីសន្និដ្ឋាន

-គន្ថនិទ្ទេស

-ឧបសម្ពន្ធ័

# ជំពូកទី១

# សញ្ញាណគតិយុត្តនៃ

# ប្រកាសនីយបត្រតក្កកម្ម

# ជំពូកទី១

# សញ្ញាណគតិយុត្តនៃប្រកាសនីយបត្រតក្កកម្ម

## ផ្នែកទី១: ប្រកាសនីយបត្រក្កកម្ម

### ១. និយមន័យនៃប្រកាសនីយបត្រក្កកម្ម

#### ១.១ និយមន័យនៃប្រកាសនីយបត្រក្កកម្ម

តាមនិយមន័យទូទៅប្រកាសនីយបត្រតក្កកម្ម គឺជាឯកសារមួយដែលពឹងផ្អែកទៅលើការអនុញ្ញាតឲ្យចុះបញ្ជី នៅឯការិយាល័យរដ្ឋបាល ហើយកម្មវត្ថុដែលអាចចុះបញ្ជីបានលុះត្រាតែមានលក្ខណៈជាការបង្កើតឡើងពីគំនិតរបស់មនុស្ស ផលិតចេញមកត្រូវតែស្របច្បាប់ និងមានផលប្រយោជន៍អាចប្រើប្រាស់ ឬអាចលក់ដូរបាន។

តាមខ្លឹមសារនៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៣ បានកំណត់ន័យថា "ប្រកាសនីយបត្រតក្កកម្មជាវិញ្ញាបនបត្រសម្រាប់ការពារតក្កកម្ម ដែលផ្តល់ឲ្យតក្កករ ក្នុងការការពារតក្កកម្ម"។ ក្នុងន័យនេះ តក្កកម្ម ជាគំនិតរបស់តក្កករ ដែលបានរកឃើញអ្វីមួយឬបង្កើតអ្វីមួយថ្មី និងមិនទាន់មានជនណាម្នាក់រកឃើញពីមុនមក ហើយតក្កកម្មនេះអាចយកទៅអនុវត្តបានក្នុងដំណោះស្រាយបញ្ហាជាក់លាក់ណាមួយក្នុងវិស័យបច្ចេកទេស។ តក្កកម្មគឺជាការរកឃើញផលិតផល ឬដំណើរការផលិតកម្ម ឬអាចជាការរកឃើញអ្វីមួយ ដែលទាក់ទងទៅនឹងផលិតផល ឬដំណើរការផលិតកម្ម។[3]

តាមអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ប្រកាសនីយបត្រតក្កកម្មត្រូវបានកំណត់និយមន័យថា គឺជាសិទ្ធិផ្តាច់មុខ ផ្តល់ឲ្យចំពោះតក្កកម្មមួយ ដែលអាចជាផលិតផលមួយ ឬជាអាចដំណើរការផលិតកម្មណាមួយ សំដៅរួមចំណែកដល់មធ្យោបាយថ្មីនៃការបង្កើតអ្វីមួយ ឬរួមចំណែកដល់ ដំណោះស្រាយ បច្ចេកទេសថ្មីណាមួយ តបទៅនឹងចំណោទបញ្ហាណាមួយ។[4]

#### ១.២ ឋានៈជាម្ចាស់នៃប្រកាសនីយបត្រក្កកម្ម

ហេតុផលសម្រាប់ ការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មលើតក្កកម្មរបស់លោកអ្នកវានឹងនាំឲ្យតក្កករមានឋានៈជា៖

-**សិទ្ធិផ្តាច់មុខ** ប្រកាសនីយបត្រតក្កកម្មផ្តល់សិទ្ធិផ្តាច់មុខ ដែលជាធម្មតាអនុញ្ញាតឲ្យ អាជីវកម្មរបស់លោកអ្នក ប្រើប្រាស់និងធ្វើអាជីវកម្ម លើតក្កកម្មនោះរយៈពេល ២០ឆ្នាំ គិតចាប់តាំងពីកាលបរិច្ឆេទ នៃការដាក់ពាក្យស្នើរសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម។

[3] មាត្រា៣ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រដែលមានអត្ថប្រយោជន៍ និគំនូរឧស្សាហកម្ម

[4] សៀវភៅនីតិកម្មសិទ្ធិបញ្ញា សាស្ត្រាចារ្យ កាន់ សុទ្ធប៉ូលីន ត្រង់ទំព័រ ១៩០ និង ១៩១

-**ផ្តល់នូវទីតាំងដ៏រឹងមាំលើទីផ្សារ** តាមរយៈសិទ្ធិផ្តាច់មុខទាំងនេះលោកអ្នកដែលបានចុះបញ្ជី រួចហើយអាចកាត់បន្ថយបាននូវការប្រកួតប្រជែង ហើយបង្កើតឡើង នូវទីតាំងរឹងមាំ ប្រកបដោយឧត្តមភាពទីផ្សារ។

-**ផ្តល់ផលចំណូលត្រឡប់មកវិញខ្ពស់ចំពោះការវិនិយោគ** ដោយបានបោះទុនវិនិយោគជា ប្រាក់ និងពេលវេលាមួយចំនួនធំ ក្នុងការបង្កើតផល ប្រកបដោយគំនិតឆ្នៃប្រឌិត អាជីវកម្មរបស់លោកអ្នក អាចធ្វើពាណិជ្ជកម្មលើគំនិតឆ្នៃប្រឌិតនោះ ក្រោមស្លាកសិទ្ធិផ្តាច់មុខទាំងនេះ ហើយអាចឲ្យអាជីវកម្ម របស់លោកអ្នក ទទួលបានផលចំណូលខ្ពស់ជាងមុនអំពីការធ្វើវិនិយោគនេះ។

-**ឱកាសក្នុងការផ្តល់អាជ្ញាប័ណ្ណឬលក់តក្កកម្ម** ប្រសិនបើអស់លោក សម្រេចមិនធ្វើអាជីវកម្មប្រកាសនីយបត្រតក្កកម្ម ដោយខ្លួនទេ លោកអ្នកអាចលក់ ឬផ្តល់អាជ្ញាប័ណ្ណចំពោះសិទ្ធិនៃការប្រើប្រាស់វា ដើម្បីឲ្យសហគ្រាសអ្នកដទៃធ្វើពាណិជ្ជកម្មនេះ ហើយវាក៏ជាប្រភពមួយនៃប្រាក់ចំណូលសម្រាប់អាជីវកម្មរបស់លោកអ្នក។

## ២. អត្ថប្រយោជន៍នៃប្រកាសនីយបត្រតក្កកម្ម

ត្បិតតែការទទួលបានប្រកាសនីយបត្រតក្កកម្មនេះពីរដ្ឋ តម្រូវឲ្យតក្កករជាប់កាតព្វកិច្ចមួយចំនួនក៏ដោយ ក៏ការទទួលបានវិញ្ញាបនបត្រគតិយុត្តប្រភេទនេះ គឺជាប្រភពនៃអត្ថប្រយោជន៍ដល់តក្កករកាលបើបានធ្វើជាម្ចាស់របស់វាផងដែរ។ ក្រៅពីសិទ្ធិផ្តាច់មុខក្នុងការធ្វើអាជីវកម្មលើតក្កកម្ម ដែលច្បាប់បានប្រគល់ឲ្យដល់ម្ចាស់នៃប្រកាសនីយបត្រតក្កកម្មហើយនោះ ក៏នៅមានអត្ថប្រយោជន៍ជាច្រើនផ្សេងទៀតដែលម្ចាស់នៃតក្កកម្ម អាចទទួលបានពីការសុំប្រកាសនីយបត្រតក្កកម្មនេះពីរដ្ឋ។

អត្ថប្រយោជន៍ទាំងនោះរួមមាន ដូចតទៅ៖

- ប្រកាសនីយបត្រតក្កកម្ម អាចត្រូវបានចាត់ទុកដូចជាការធានាមួយរបស់រដ្ឋ ដើម្បីប្រឆាំងទល់ទៅនឹងអំពើនៃការក្លែងបន្លំទាំងឡាយ ចំពោះតក្កកម្មដែលជាកម្មវត្ថុនៃប្រកាសនីយបត្រនេះឲ្យដល់តក្កករ។ ជាទ្រឹស្តី អំពើនៃការក្លែងបន្លំ សំដៅដល់រូបភាពនៃអំពើទាំងឡាយណា ដែលបំពានដល់សិទ្ធិលើតក្កកម្មនៃម្ចាស់ប្រកាសនីយបត្រតក្កកម្មនេះទាំងលើផលិតផល ឬដំណើរការផលិតកម្មដែលតក្កករនោះបានចុះបញ្ជី និងទាំងលើមធ្យោបាយនានាដែលត្រូវបានប្រើប្រាស់សម្រាប់ជាជំនួយដល់ការផលិត ឬដល់ដំណើរការផលិតកម្មនោះទៀតផង។ មួយវិញទៀត ដោយសារវត្តមាននៃប្រកាសនីយបត្រតក្កកម្មនេះឯងទើបអំពើនៃការក្លែងបន្លំតក្កកម្ម គឺនឹងត្រូវផ្តន្ទាទោសទៅតាមបញ្ញាតិច្បាប់វិញ្ញបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្មជាមិនខាន។ ផ្ទុយទៅវិញនឹងពុំត្រូវបានការពារប្រឆាំងទៅនឹង អំពើក្លែងបន្លំតក្កកម្មនោះឡើយ ចំពោះរាល់អំពើក្លែងបន្លំណាដែលកើតមានឡើងនៅមុន និងក្រោយសុពលភាពនៃប្រកាសនីយបត្រតក្កកម្មនេះ។
- ប្រកាសនីយបត្រតក្កកម្មនេះដែរ ក៏ពិតជាអាចជម្រុញដល់ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់សហគ្រាសបាន ពីព្រោះតែវិញ្ញាបនបត្រប្រភេទនេះ ត្រូវបានចាត់ទុកជាធាតុផ្សំមួយនៃ

ទ្រព្យសកម្មរបស់សហគ្រាស និងជាប្រភពផ្ទាល់នៃការទាក់ទាញ អ្នកបណ្តាក់ទុកដើម្បីបង្កើនមូលធនវិនិយោគរបស់សហគ្រាសនោះ។ មានមូលហេតុធំៗចំនួនបួនយ៉ាងដែលអាចធ្វើការគាំទ្រដល់សារៈប្រយោជន៍ខាងសេដ្ឋកិច្ចរបស់សហគ្រាសជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្មបានរួមមាន ទី១. ព័ត៌មានស្តីពីតក្កកម្មដែលបានរៀបរាប់ក្នុងប្រកាសនីយបត្រ និងជួយសម្រួលដល់ការផ្ទេរបច្ចេកវិជ្ជា និងការដាក់វិនិយោគទុនរបស់សហគ្រាស ទី២ ប្រកាសនីយបត្រតក្កកម្មនេះក៏នឹងជួយលើកទឹកចិត្តដល់ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍បន្តបន្ទាប់ទៅមុខទៀតរបស់សហគ្រាសបាន ទី៣ ប្រកាសនីយបត្រនេះដែរក៏នឹងជួយពន្លឿនដល់ការបង្កើតបច្ចេកវិជ្ជាថ្មីៗ ក៏ដូចជាការបង្កើតមុខជំនួញថ្មីៗដល់សហគ្រាសផងទៀត និងទី៤ ប្រកាសនីយបត្រតក្កកម្មក៏គឺជាកូនសោរមួយដ៏ប្រសើរបំផុតនៅក្នុងកិច្ចសហការគ្នាលើវិស័យជំនួញដើម្បីអភិវឌ្ឍសហគ្រាសរៀងៗខ្លួន និងអាចជាប្រភពចំណូលបន្ថែមរបស់សហគ្រាសតាមរយៈការផ្តល់អាជ្ញាបណ្ណឲ្យធ្វើអាជីវកម្មលើតក្កកម្មនោះផងដែរ។

- ជាចុងក្រោយប្រកាសនីយបត្រតក្កកម្មនេះក៏អាចត្រូវបានចាត់ទុកដូចជាយុទ្ធសាស្ត្រមួយដ៏មានប្រសិទ្ធភាពមួយក្នុងការផ្សព្វផ្សាយកេរ្តិ៍ឈ្មោះ និងដើម្បីពង្រឹងដល់កិត្យានុភាពរបស់សហគ្រាសដែលជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនោះ ទៅដល់បណ្តាសាធារណជនទាំងឡាយក៏ដូចជាទៅដល់អតិថិជន និងដៃគូប្រកួតប្រជែងនានា របស់សហគ្រាសនោះ។ ដោយស្ថិតនៅក្នុងភាពជាម្ចាស់ប្រកាសនីយបត្រតក្កកម្មនេះហើយទើបសហគ្រាសទាំងឡាយរមែងមានឥទ្ធិពលខ្ពស់ជាងគេនៅក្នុងទំនាក់ទំនងពាណិជ្ជកម្មជាមួយដៃគូនានារបស់ខ្លួនជានិច្ច។[5]

### ២.១ សិទ្ធិផ្តាច់មុខ និងឧត្តមភាពលើទីផ្សារ

ការសម្រេចថាផ្តល់ជូនដល់អ្នកដាក់ពាក្យស្នើសុំនូវប្រកាសនីយបត្រតក្កកម្ម ក៏មានន័យដែរថារដ្ឋព្រមទទួលស្គាល់សិទ្ធិមួយចំនួនដែលច្បាប់នេះបានកំណត់ ឲ្យដល់អ្នកស្នើសុំ នៅក្នុងឋានៈជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនិយាយមួយបែប និងជាម្ចាស់នៃតក្កកម្មផ្ទាល់និយាយមួយទៀត។ សិទ្ធិនេះអាចបកស្រាយក្នុងន័យពីរយ៉ាង។ ក្នុងន័យវិជ្ជមាននៃសិទ្ធិ សិទ្ធិនេះអាចអនុញ្ញាតឲ្យម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម ធ្វើអាជីវកម្មលើតក្កកម្មនេះតែឯងបាន។ ប៉ុន្តែ ក្នុងន័យអវិជ្ជមាន នៃសិទ្ធិវិញ សិទ្ធិនេះក៏នឹងអនុញ្ញាតអោយអាចហាមឃាត់តតីយជនណាម្នាក់ មិនអោយធ្វើអាជីវកម្មលើតក្កកម្មរបស់ខ្លួនបានផងដែរ។ តតីយជនណាម្នាក់ប ដែលហ៊ានធ្វើអាជីវកម្មលើតក្កកម្មចុះបញ្ជីសុំប្រកាសនីយបត្រតក្កកម្ម នឹងត្រូវចាត់ទុកថាជាការរំលោភលើសិទ្ធិស្របច្បាប់របស់តក្ករនេះ ហើយ ក្នុងករណីនេះ ក៏នឹងមានយន្តការដោះស្រាយសំដៅធានាដល់សិទ្ធិស្របច្បាប់នោះ ឲ្យដល់ម្ចាស់សិទ្ធិផងដែរ។ ប្រកាសនីយបត្រតក្កកម្ម អាចបានត្រូវចាត់ទុកថាជាកម្មសិទ្ធិផ្តាច់មុខ ដោយសារតែម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនោះមានការគ្រប់គ្រងពេញលេញ លើការផលិត ការលក់ និងការប្រើ

[5] នីតិកម្មសិទ្ធិបញ្ញា សាស្ត្រាចារ្យ កាន់សុទ្ធប៉ូលីន បោះពុម្ពលើកទីពីរឆ្នាំ២០១៤ ទំព័រ១៩១ ដល់១៩៤

ប្រាស់គំនិតឆ្នៃប្រឌិតនោះ។ ប្រកាសនីយបត្រតក្កកម្មអនុញ្ញាតឲ្យម្ចាស់របស់វា ទាញយកផលប្រយោជន៍ជាសម្ភារៈ ដែលជារង្វាន់សម្រាប់កិច្ចការ និងការខិតខំប្រឹងប្រែងខាងបញ្ញាញាណខ្លួន។ តក្កកម្មនេះអាចនឹងត្រូវបានយកទៅធ្វើអាជីវកម្មលុះណាតែ មានការអនុញ្ញាតពីម្ចាស់របស់ប្រកាសនីយបត្រតក្កកម្មជាមុនសិន។

**២.២ ថាមពលក្នុងការចរចារ និងរូបភាពវិជ្ជមានដល់សហគ្រាស**

-**បង្កើតថាមពលក្នុងការចរចារ** ប្រសិនបើអាជីវកម្មរបស់លោកអ្នក ស្ថិតក្នុងដំណាក់កាលនៃ ការទទួលបាននូវសិទ្ធិ ដើម្បីប្រើប្រាស់ប្រកាសនីយបត្រតក្កកម្ម របស់សហគ្រាសដទៃមួយទៀតតាមរយៈកិច្ចសន្យាអាជ្ញាប័ណ្ណ នោះរូបភាពនៃប្រកាសនីយបត្រតក្កកម្មរបស់លោកអ្នកនិងជួយលើកកម្ពស់ ថាមពលសម្រាប់ការតថ្លៃរបស់អ្នកជាមួយសហគ្រាសនោះផងដែរ។ មានន័យ ថាប្រកាសនីយបត្រតក្កកម្មរបស់លោកអ្នក អាចជាចំណុចចាប់អារម្មណ៍មួយរបស់ សហគ្រាសមួយផ្សេងទៀត ដែលអ្នកកំពុងចរចារជាមួយហើយលោកអ្នកនឹងឈានទៅក្នុងការ រៀបចំចាត់ចែងឲ្យមានការផ្ដល់ អាជ្ញាប័ណ្ណទៅវិញទៅមករវាង សហគ្រាសរបស់លោកអ្នក និងសហគ្រាសអ្នកដទៃ។

-**រូបភាពវិជ្ជមានរបស់សហគ្រាសលោកអ្នក** ដៃគូអាជីវកម្ម ឬបណ្ដាក់ទុនវិនិយោគ និងម្ចាស់ ភាគហ៊ុន អាចយល់ឃើញថា រូបភាពប្រកាសនីយបត្រតក្កកម្មគឺជាការបង្ហាញនូវកម្រិតខ្ពស់នៃជំនាញឯកទេសកម្ម និងសមត្ថភាពខាងបច្ចេកវិទ្យា ដែលមានក្នុងក្រុមហ៊ុន របស់លោកអ្នក។ ប្រការនេះបញ្ជាក់បាននូវភាពមានប្រយោជន៍សម្រាប់ការអំពាវនាវ មូលនិធិ ការស្វែងរកដៃគូអាជីវកម្ម និងការបង្កើតតម្លៃ ទីផ្សាររបស់ក្រុមហ៊ុនលោកអ្នក។ ជាពិសេសម្ចាស់ប្រកាសនីយបត្រតក្កកម្ម(តក្កករ) មានសិទ្ធិក្នុងការហាមឃាត់ពីតតីយជន មិនឲ្យផលិត ប្រើប្រាស់ ដាក់លក់ ធ្វើសំណើរលក់ ឬនាំចូលផលិតផលដោយពុំមានការអនុញ្ញាតពីម្ចាស់ប្រកាសនីយបត្រតក្កកម្ម។

## ផ្នែកទី២: តក្កករ និង តក្កកម្ម

### ១. តក្កករ

#### ១.១ និយមន័យនៃតក្កករ

តក្កករ សំដៅលើអ្នកដែលបានបង្កើតស្នាដៃ[6] ប៉ុន្តែនៅក្នុងវិស័យកម្មសិទ្ធិបញ្ញា "គោលការណ៍ចុះបញ្ជីមុន" ត្រូវយកមកអនុវត្ត មានន័យថាប្រសិនបើបុគ្គលណាមួយ បានយកតក្កកម្មខ្លួន ទៅចុះ បញ្ជីបាន បុគ្គលនោះត្រូវទទួលបានសិទ្ធិជាម្ចាស់ **"តក្កកម្ម"** នៃតក្កកម្មដែលត្រូវបានចុះបញ្ជីនោះ។ ក្នុងករណីនេះ តើច្បាប់អាចធានាបានទេ តើបុគ្គលដែលបានចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម នោះ គឺជាម្ចាស់តក្កកម្មពិតប្រាកដ? ប្រសិនបើបុគ្គលទុច្ចរិតបានលួចយកតក្កកម្មរបស់អ្នកបង្កើតស្នាដៃ ពិត

[6] មាត្រា១០ នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម

ប្រាកដទៅចុះបញ្ជី នោះមានន័យថាទុច្ចរិតជន បានក្លាយទៅជាម្ចាស់ស្នាដៃ រីឯម្ចាស់ស្នាដៃពុំមានសិទ្ធិ ក្នុងការធ្វើអាជីវកម្មលើស្នាដៃរបស់ខ្លួនបានឡើយ។

តើច្បាប់នៃប្រទេសកម្ពុជាមានដំណោះស្រាយលើបញ្ហានេះដែរឬទេ?

បទបញ្ញត្តិនៃច្បាប់ប្រកាសនីយបត្រតក្កកម្ម ពុំបានចែងពីដំណោះស្រាយ លើបញ្ហានេះឡើយ។ លើសពីនេះទៅទៀត ក្នុងនីតិកម្ពុជា ក៏ពុំទាន់មានយុត្តិសាស្ត្រណាមួយនៅឡើយដែរ។ ក្នុងករណីនេះយើងអាចសិក្សាពីច្បាប់បរទេសដើម្បីរកដំណោះស្រាយ។

### ១.២.១ ប្រភេទតក្កករ

មិនមែនអ្នកបង្កើតស្នាដៃ សុទ្ធសឹងតែមានគុណវុឌ្ឍិជាតក្កករទេ។ តក្កករជាបុគ្គលដែលផលិតស្នាដៃ ដូចជានិយោជិតរបស់សហគ្រាស កម្មសិក្សាការីនៃសហគ្រាស ឬអាចជាមន្ត្រីនៅក្នុងជំនាញផលិតកម្ម នៃស្ថាប័នរដ្ឋ។

#### ក. តក្កកម្មរបស់និយោជិត

តាមរយៈកិច្ចសន្យាការងារ និយោជិតមានចំណង ក្រោមបង្គាប់បញ្ជារបស់និយោជក មានន័យថានិយោជិតមានកាតព្វកិច្ចបំពេញការងារ ដែលនិយោជកបានប្រគល់ឲ្យស្របតាមច្បាប់កិច្ចសន្យា និងច្បាប់ការងារ។ ក្នុងករណីនេះជាគោលការណ៍ តក្កកម្មដែលកើតចេញពីបេសកម្ម ឬសេវាក្នុងក្របខណ្ឌនៃ កិច្ចសន្យាការងារ តក្កកម្មនោះជាកម្មសិទ្ធិរបស់និយោជក ។

ផ្អែកតាមបទបញ្ញត្តិខាងលើ យើងទាញចេញជាគោលការណ៍ នៃសច្ចធារណ៍តាមច្បាប់បានថា៖ រាល់តក្កកម្ម ទាំងអស់ត្រូវចាត់ទុកជាកម្មសិទ្ធិរបស់និយោជក ប្រសិនបើតក្កកម្មនោះត្រូវបានបង្កើតឡើង៖

-ក្នុងម៉ោងធ្វើការ។

-ក្នុងក្របខណ្ឌសកម្មភាពការងារ។

-ដោយការប្រើប្រាស់មធ្យោបាយរបស់សហគ្រាស។

#### ខ.តក្កកម្មរបស់កម្មសិក្សាការី

ជាគោលការណ៍កម្មសិក្សាការីមិនស្ថិតនៅក្រោមរបបគតិយុត្តដូចនិយោជិតនោះទេ។ ច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧ នៃប្រទេសកម្ពុជា ពុំបានកំណត់អំពីរបបគតិយុត្តនៃកម្មសិក្សានោះទេ ពោលគឺកំណត់អំពី លក្ខខណ្ឌនៃការបញ្ចប់កម្មសិក្សាតែប៉ុណ្ណោះ [7]។ ក្នុងការអនុវត្តនៅកម្ពុជា ពុំទាន់ឃើញមានដំណោះស្រាយនៅឡើយទេ។ ក្នុងករណីនេះប្រសិនបើច្បាប់អវត្តមានក្នុងការកំណត់បញ្ញត្តិ

[7] មាត្រា ៨២(១) នៃច្បាប់ស្តីពីការងារ កម្មសិក្សាការី កម្មសិក្សាមិនចាំបាច់ ជូនដំណឹងជាមុនដល់និយោជក ក្នុងករណីបញ្ចប់កម្មសិក្សាឡើយ។

ពាក់ព័ន្ធ វាជាសេរីភាពរបស់គូភាគី ដែលត្រូវកំណត់លក្ខខណ្ឌជាក់លាក់ នៅក្នុងកិច្ចសន្យា (រវាងអ្នកដឹកនាំកម្មសិក្សា និងកម្មសិក្សាការី)។

**គ.តក្កកម្មរបស់មន្ត្រី**

ក្នុងក្របខណ្ឌគតិយុត្តកម្ពុជា ពុំមានបទបញ្ញាត្តិណាមួយកំណត់អំពីម្ចាស់កម្មសិទ្ធិលើតក្កកម្ម ដែលត្រូវបង្កើតឡើង ដោយមន្ត្រីសាធារណៈ ដែលមានជំនាញ និងគ្រប់គ្រងវិស័យបច្ចេកវិទ្យាណាមួយនោះទេ។ ប៉ុន្តែនីតិនៃប្រទេសបារាំង បានបញ្ញាត្តិ ភាពជាម្ចាស់កម្មសិទ្ធិលើតក្កកម្ម ដែលត្រូវបានបង្កើតឡើង ដោយមន្ត្រីសាធារណៈ។ តក្កកម្មដែលត្រូវបានបង្កើតឡើងដោយមន្ត្រីសាធារណៈ ក្នុងក្របខណ្ឌការងាររបស់គាត់ ត្រូវអនុវត្តដូចគ្នានិងនិយោជិត[8] មានន័យថាជាកម្មសិទ្ធិរបស់រដ្ឋ(ស្ថាប័ន)។

**១.២.២ ការដាក់ឈ្មោះតក្កករ**

ការដាក់ឈ្មោះតក្កករ គឺត្រូវតែដាក់ឈ្មោះខ្លួនឯងនៅក្នុងប្រកាសនីយបត្រតក្កកម្ម លើកលែងតែតក្កករនោះបានចុះហត្ថលេខាលើសេចក្តីប្រកាសជាលាយលក្ខអក្សរពិសេសមួយ ផ្ញើជូនមន្ត្រីកាន់កាប់បញ្ជីដោយបញ្ជាក់ប្រាប់ថាខ្លួនពុំមានបំណងដាក់ឈ្មោះរបស់ខ្លួនឡើយ ទើបនៅលើប្រកាសនីយបត្រតក្កកម្មនោះមិនត្រូវបានដាក់ឈ្មោះតក្កករ។ ការសន្យា ឬការទទួលរ៉ាប់រងណាមួយរបស់តក្កករដោយផ្ទាល់មាត់ធ្វើឡើងចំពោះបុគ្គលណាម្នាក់ ដែលថាខ្លួននឹងធ្វើតាមសេចក្តី ប្រកាសខាងលើ នឹងពុំមានប្រសិទ្ធិភាពស្របច្បាប់ឡើយ។

**២. តក្កកម្ម**

**២.១ និយមន័យតក្កកម្ម**

តក្កកម្ម គឺជាគំនិតរបស់តក្កករ ដែលអាចយកទៅអនុវត្តបាន ក្នុងដំណោះស្រាយបញ្ហាជាក់លាក់ណាមួយ ក្នុងវិស័យបច្ចេកវិទ្យា[9] ។ តក្កកម្មអាចជាការរកឃើញផលិតផល ឬដំណើការផលិតកម្ម។ តាមន័យគតិយុត្តនេះ ក៏ដូចជាករណី នៃស្នាដៃនិពន្ធដែរ "តក្កកម្ម" គឺត្រូវជាផលិតផល នៃគំនិតប្រាជ្ញាផ្ទាល់របស់ "តក្កករ" ដែលជាអ្នកបង្កើតវា។ ប៉ុន្តែនេះពុំមានន័យថា គ្រប់ផលិតផល នៃគំនិតរបស់តក្កករ សុទ្ធសឹងតែអាចចាត់ទុក ជាតក្កកម្មនោះបានទេ ពោលគឺលុះត្រាតែគំនិតទាំងឡាយនោះ អាចបំពេញបានត្រឹមត្រូវតាមលក្ខខណ្ឌទាំងឡាយ ដែលច្បាប់បានកំណត់ឲ្យផង និងត្រូវតែស្ថិតនៅក្នុងវិស័យដែលច្បាប់ ទទួលស្គាល់ផងទៀត។ ដូចគ្នានេះដែរ ពុំមែនគ្រប់តក្កកម្មទាំងអស់សុទ្ធតែអាចត្រូវការពារដោយប្រកាសនីយបត្រតក្កកម្ម នោះឡើយពោលគឺមានតក្កកម្មមួយចំនួនផងដែរ ដែលច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម នេះបានបដិសេធក្នុងការផ្តល់ ប្រកាសនីយ បត្រតក្កកម្មដើម្បីការពារដល់តក្កកម្មនោះ។

---

[8] មាត្រា L611-14 alinee នៃក្រមកម្មសិទ្ធិបញ្ញាបារាំង។

[9] មាត្រា៣ នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម។

តក្កកម្មដែលត្រូវបានការពារដោយច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មនេះ ត្រូវតែជា តក្កកម្មដែលអាចយកមកអនុវត្តបាន ក្នុងវិស័យឧស្សាហកម្ម [10] ឬតក្កកម្មដែលមិនពាក់ព័ន្ធ និងវិស័យឧស្សាហកម្ម ត្រូវការពារដោយច្បាប់ដោយឡែក។

## ២.២ តក្កកម្មដែលមិនមែនជាកម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្ម

យោងបញ្ញត្តិច្បាប់ស្តីពី ប្រកាសនីយបត្តបត្រតក្កកម្ម អាចរាប់បាននូវតក្កកម្មពីរជំពូក ដែលពុំមានសំណាងទទួលបានការការពារ ប្រកាសនីយបត្រតក្កកម្មនេះរួមមាន ក្នុងមាត្រា៤ និងមាត្រា៩។

**មាត្រា៤** បានចែងថា៖ "បានផ្តល់បញ្ជីឈ្មោះនៃតក្កកម្មដែលមិនត្រូវការពារ ដោយប្រកាសនីយបត្រតក្កកម្មរួមមាន ៖ (១) ការរកឃើញទ្រឹស្តីវិទ្យាសាស្ត្រ និងវិធីសាស្ត្រគណិតវិទ្យា (២) គម្រោងការ ក្បួន ឬវិធីសាស្ត្រធ្វើជំនួញ សម្រាប់ធ្វើសកម្មភាពហ្វឹកហ្វឺនខាងប្រាជ្ញាសុទ្ធសាធ ឬសម្រាប់លេងកំសាន្ត (៣) វិធីសាស្ត្រសម្រាប់ព្យាបាលមនុស្សឬសត្វ ដោយការវះកាត់ ដោយការ ព្យាបាល ក៏ដូចជាវិធីសាស្ត្រវិនិច្ឆ័យរោគ ដែលបានអនុវត្ត ចំពោះផលិតផលទាំងឡាយដែល យកមកប្រើប្រាស់ក្នុងវិធីសាស្ត្រខាងលើនេះ (៤) ផលិតផលឱសថ ដូចមានចែងក្នុង មាត្រា១៣៦នៃច្បាប់នេះ (៥) រុក្ខជាតិ ឬសត្វដែលមិនមែនជាមីក្រូសិរីរាង្គ និងដំណើរការកកើត តាមលក្ខណៈជីវសាស្ត្រ សំខាន់ៗ សម្រាប់រុក្ខជាតិឬសត្វ និង (៦) ប្រភេទផ្សេងៗ នៃពូជរុក្ខជាតិណាមួយ"។

**មាត្រា៩** បានចែងថា៖ "បើតក្កកម្មណា ដែលការធ្វើអាជីវកម្ម ឬពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា របស់វាផ្ទុយទៅនឹង សណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌ ឬមិនការពារជីវិត ឬសុខភាពរបស់មនុស្ស សត្វ ឬរុក្ខជាតិ ឬធ្វើឲ្យប៉ះពាល់ដល់បរិស្ថានធ្ងន់ធ្ងរ នោះនឹងត្រូវច្បាប់ហាម ឃាត់ និងមិនត្រូវផ្តល់ប្រកាសនីយបត្រតក្កកម្មឲ្យនោះទេ"។

## ២.៣ ប្រព័ន្ធ First to file និង ប្រព័ន្ធ First to invent

The First Inventor Concept៖ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មសហរដ្ឋអាមេរិក ឆ្នាំ១៧៩០ បានអនុវត្តគោលការណ៍ First to Invent ដោយតម្រូវឲ្យម្ចាស់សិទ្ធិ នៃប្រកាស នីយបត្រ តក្កកម្ម ត្រូវតែជាតក្កករមុនគេ និងពិតប្រាកដ (The First and True Inventor) និយាយរួមគឺ (ជាអ្នកទីមួយដែលបានបង្កើតស្នាដៃ) និងរបស់ពួក Romana Germanic មានបារាំង អាឡឺម៉ង់ដែលតាមនោះគឺ»អ្នកទីមួយដែលបានចុះបញ្ជីស្នាដៃ (First to File) ។ ក្នុងន័យនៃទ្រឹស្តីទាំង២នេះ អ្នកដែលយកតក្កកម្មនេះមុនគេនឹងត្រូវបានសន្មត់ដូចជាអ្នកបង្កើតតក្កកម្ម(ឬជាតក្កករ)។

លើសពីនេះទៀត៖ ប្រសិនបើមានបុគ្គលពីរនាក់ ឬច្រើននាក់រួមគ្នាបង្កើតបានតក្កកម្មមួយសិទ្ធិជាម្ចាស់ នៃប្រកាសនីយបត្រតក្កកម្មនេះត្រូវជាកម្មសិទ្ធិរួមគ្នានៃបុគ្គលទាំងឡាយនោះ [11]។

[10] មាត្រា៥ និងមាត្រា៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

[11] មាត្រា១១ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រដែលមានអត្ថប្រយោជន៍ និគំនូរឧស្សាហកម្ម

ផ្ទុយទៅវិញ "ប្រសិនបើមានបុគ្គលពីរនាក់ ឬច្រើននាក់ បានរកឃើញដាច់ដោយឡែកៗពីគ្នានូវតក្កកម្មមួយដូចគ្នា បុគ្គលណាបានដាក់សំណុំលិខិតស្នើសុំ ដែលមានកាលបរិច្ឆេទ សុំចុះបញ្ជីមុនគេបង្អស់ ហើយត្រូវបានប្រកាសសុពលភាពនៃកាលបរិច្ឆេទអាទិភាពនោះ ត្រូវទទួលសិទ្ធិជាម្ចាស់ប្រកាសនីយបត្រតក្កកម្ម ប្រសិនបើសំណុំលិខិតស្នើសុំនោះមិនត្រូវបានដកហូត ឬបោះបង់ចោល ឬក៏ត្រូវ បដិសេធចោល" [12] ។

[12] មាត្រា១២ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រដែលមានអត្ថប្រយោជន៍ និគំនូរឧស្សាហកម្ម

# ជំពូកទី២

# នីតិវិធីនៃការផ្តល់

# ប្រកាសនីយបត្រគក្កកម្ម

# ជំពូកទី២
# នីតិវិធីនៃការផ្ដល់ប្រកាសនីយបត្រតក្កកម្ម

## ផ្នែកទី១: ការដាក់ពាក្យសុំ

តក្កកម្ម ត្រូវតែចុះបញ្ជីនៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីទទួលបាននូវកិច្ចការពារស្របច្បាប់ និងទទួលបានសិទ្ធិផ្តាច់មុខលើតក្កកម្មនេះ។

ការដាក់ពាក្យស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម ត្រូវធ្វើឡើងដោយម្ចាស់ប្រកាសនីយបត្រតក្កកម្ម ឬអ្នកតំណាងស្របច្បាប់របស់ម្ចាស់តក្កកម្ម ដោយបំពេញតាមទម្រង់ដែលកំណត់ដោយច្បាប់ និងបទបញ្ញាត្តិពាក់ព័ន្ធ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

អាទិភាពនៃការស្នើសុំប្រកាសនីយបត្រតក្កកម្មនេះ ត្រូវបានផ្តល់ឲ្យអ្នកដែលបានចុះបញ្ជីជាផ្លូវការជាមុន ឬអ្នកដែលបានអះអាងថាមានអាទិភាពនោះ។

### ១. សមត្ថកិច្ចទទួលបន្ទុកពាក្យស្នើសុំ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម រាល់ការស្នើសុំប្រកាសនីយបត្រតក្កកម្ម ត្រូវធ្វើនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម។[13] ពាក្យស្នើសុំចុះបញ្ជីនេះ ត្រូវដាក់ជូនទៅនាយកដ្ឋាន កម្មសិទ្ធិឧស្សាហកម្ម នៃអគ្គនាយកដ្ឋាន ឧស្សាហកម្ម របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ នាយកដ្ឋាននេះដឹកនាំដោយប្រធាន នាយកដ្ឋានមួយរូប ដែលមានតួនាទីតាមច្បាប់គឺជា **មន្ត្រីកាន់កាប់បញ្ជី** សម្រាប់រាល់ការស្នើសុំប្រកាសនីយបត្រតក្កកម្មទាំងអស់។[14] ការស្នើសុំនេះ អ្នកដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម(តក្កករ) ត្រូវដាក់ឈ្មោះរបស់ខ្លួនគាត់ផ្ទាល់ លើកលែងតែមានការប្រកាសជាលាយលក្ខណ៍អក្សរពិសេសណាមួយ ហើយផ្ញើទៅមន្ត្រីកាន់កាប់បញ្ជី ដោយបញ្ជាក់ថា គាត់ពុំមានបំណងនឹងបញ្ចេញឈ្មោះទេ។

ការដាក់សំណុំលិខិតស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម គឺជាការដាក់សំណុំបែបបទដែលត្រូវបង់កម្រៃជាមុន ហើយសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ត្រូវការត្រួតពិនិត្យជាចាំបាច់។

#### ១.១ ការបង្កើត និងតួនាទីនៃនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម

នាយកដ្ឋានកម្មសិទ្ធឧស្សាហកម្ម មានតួនាទីដូចតទៅះ

[13] មាត្រា២៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

[14] មាត្រា២ នៃប្រកាសលេខ៧០៦ ឧរថ ប្រក ចុះថ្ងៃទី២៩ ឆ្នាំ២០០៦ របស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ស្តីពីប្រកាសនីយបត្រតក្កកម្ម និងវិញ្ញា បនបត្រម៉ូដែលមានអត្ថប្រយោជន៍។

-រៀបចំ និងអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ ទិសដៅ និងផែនការក្នុងការពង្រីក ការការពារ សិទ្ធិលើកម្មសិទ្ធិឧស្សាហកម្មក្នុងព្រះរាជាណាចក្រកម្ពុជា

-សហការរៀបចំគោលនយោបាយ អំពីការច្នៃប្រឌិត និងបង្កើតថ្មី ក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍបច្ចេកវិទ្យា

-រៀបចំលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធី និងបទបញ្ញាពាក់ព័ន្ធនិងការផ្តល់ប្រកាសនីយបត្រតក្កកម្មម៉ូដែលមានអត្ថប្រយោជន៍ សិទ្ធិអ្នកបង្កាត់ពូជដំណាំ និងការចុះបញ្ជីគំនូរឧស្សាហកម្ម បង្ហាញនៃស្មៀគីបង្រួម។

-អនុវត្តនីតិវិធីសម្រាប់ការផ្តល់ និងការគ្រប់គ្រងប្រកាសនីយបត្រតក្កកម្ម វិញ្ញបនបត្រ ម៉ូដែលមានអត្ថប្រយោជន៍ សិទ្ធិអ្នកបង្កាត់ពូជដំណាំ និងសម្រាប់ការចុះបញ្ជី និងការគ្រប់គ្រងគំនូរឧស្សា ហកម្ម និងគំនូរបង្ហាញនៃសៀគ្វីបង្រួមនៃព្រះរាជាណាចក្រកម្ពុជា។

- អនុវត្តយន្តការជំរុញការច្នៃប្រឌិត និងការបង្កើតថ្មី

-ផ្សព្វផ្សាយតាមរយៈព្រឹត្តិផ្លូវការ ឬតាមមធ្យោបាយផ្សេងៗទៀត សម្រាប់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ សិទ្ធិអ្នកបង្កាត់ពូជដំណាំ គំនូរឧស្សាហកម្ម និងគំនូរបង្ហាញនៃសៀគ្វីបង្រួម

-គ្រប់គ្រងមណ្ឌលកៃច្នៃប្រឌិត មណ្ឌលតក្កកម្ម មណ្ឌលស្រាវជ្រាវ និងពិនិត្យកម្មសិទ្ធិ ឧស្សាហកម្ម មណ្ឌលផ្សព្វផ្សាយ និងបណ្តុះបណ្តាលកម្មសិទ្ធឧស្សាហកម្ម

-រៀបចំអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្តុះបណ្តាលកម្មសិទ្ធិឧស្សាហកម្ម

-ផ្សព្វផ្សាយ និងប្រើប្រាស់ពិត៍មានស្តីពីកម្មសិទ្ធិឧស្សាហកម្ម ធ្វើជាឧបករណ៍ដើម្បីជម្រុញការច្នៃប្រឌិតថ្មី ការបង្កើតតក្កកម្ម ការស្រាវជ្រាវក្នុងគោលបំណងអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា ក្នុងព្រះរាជាណាចក្រកម្ពុជា

-អនុវត្តន៍នីតិវិធីក្នុងការចុះបញ្ជីភ្នាក់ងារដែលប្រកបអាជីវកម្ម ធ្វើជាតំណាងរបស់អ្នកដាក់ពាក្យសុំ ក្នុងការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម

-សម្របសម្រួល និងដោះស្រាយវិវាទពាក់ព័ន្ធនឹងកម្មសិទ្ធិឧស្សាហកម្ម

-សម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ និងអង្គការអន្តរជាតិ រួមទាំងសហការជាមួយដៃគូរអភិវឌ្ឍនានា លើការងារកម្មសិទ្ធិឧស្សាហកម្ម

-បូកសរុបរបាយការណ៍ វាយតម្លៃលទ្ធផលការងារ និងអភិវឌ្ឍវិស័យកម្មសិទ្ធិឧស្សាហកម្ម

-និងទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធានស្ថាប័នប្រគល់ជូន[15] ។

**១.២ ការិយាល័យប្រកាសនីយបត្រតក្កកម្ម**

ការិយាល័យប្រកាសនីយបត្រតក្កកម្ម ជាសេនាធិការឲ្យថ្នាក់ដឹកនាំនាយកដ្ឋាន លើការងារប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរបង្ហាញនៃសៀគ្វីបង្រួម។

ការិយាល័យប្រកាសនីយបត្រតក្កម្ម មានភារកិច្ចដូចតទៅ:

-រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការក្នុងការពង្រឹងការការពារ ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរបង្ហាញសៀគ្វីបង្រួម

-រៀបចំបទដ្ឋានគតិយុត្ត នីតិវិធី និងបទបញ្ញាពាក់ព័ន្ធនឹងការផ្តល់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរបង្ហាញសៀគ្វីបង្រួម

-ទទួលស្រាវជ្រាវ ពិនិត្យ និងវាយតម្លៃសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរបង្ហាញសៀគ្វីបង្រួម

-អនុវត្តនីតិវិធីលើការផ្តល់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរបង្ហាញសៀគ្វីបង្រួម

-អនុវត្តនីតិវិធីសំណុំលិខិតស្នើសុំអន្តរជាតិ សម្រាប់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរបង្ហាញសៀគ្វីបង្រួម តាមប្រព័ន្ធអន្តរជាតិនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មតាមប្រពន្ធថ្នាក់តំបន់ និងតាមកិច្ចសហប្រតិបត្តិការរបស់រដ្ឋ

-គ្រប់គ្រងប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរបង្ហាញសៀគ្វីបង្រួមដែលបានផ្តល់សិទ្ធិការពារនៅក្នុងព្រះរាជាណាចក្រកម្ពុជា

-សហការ ផ្តល់យោបល់បច្ចេកទេសដល់មណ្ឌលស្រាវជ្រាវ និងពិនិត្យប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

-រៀបចំចងក្រង បោះពុម្ព និងផ្សព្វផ្សាយតាមព្រឹត្តបត្រផ្លូវការ និងមធ្យោបាយផ្សេងៗទៀត អំពី៖

-សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងការងារពាក់ព័ន្ធផ្សេងៗទៀត

-សំណុំស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ការផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងការងារពាក់ព័ន្ធផ្សេងៗទៀត

[15] ប្រការ៣ នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម

-សំណុំលិខិតស្នើចុះបញ្ជីគំនូរបង្ហាញសៀគ្វីបង្រួម និងការងារពាក់ព័ន្ធផ្សេងៗទៀត។

-និងទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានបានប្រគល់ជូន[16]។

## ២. សំណុំឯកសារចាំបាច់សម្រាប់ការដាក់ពាក្យសុំ

### ២.១ សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម

សំណុំលិខិតដែលចាំបាច់បំផុតដែលតម្រូវ សម្រប់ការស្នើសុំ ប្រកាសនីយបត្រតក្កកម្មមួយ រួមមានៈ ពាក្យសុំ សេចក្តីអធិប្បាយអំពីតក្កកម្ម សេចក្តីអះអាង គំនូសបង្ហាញ និងខ្លឹមសារសង្ខេបនៃតក្កកម្មនោះជាដើម។ ការដាក់ស្នើសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម គឺជាការដាក់សំណុំបែបបទដែលត្រូវបង់កម្រៃជាមុន ហើយសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ត្រូវការត្រួតពិនិត្យជាចាំបាច់ ចំពោះទម្រង់ និងខ្លឹសារសង្ខេបពីតក្កកម្មនោះ។ ក្រោយពីការដាក់សំណុំលិខិត ស្នើសុំជាលើកដំបូង គាត់មានពេលវេលារហូតដល់១២ខែ ដើម្បីសម្រេចជ្រើសរើសប្រទេសណាមួយ ដែលគាត់ចង់បានទទួលការការពារក្នុងប្រទេសទាំងនោះ។

លើសពីនេះទៅទៀត រាល់ការដាក់ពាក្យស្នើសុំ ប្រកាសនីយបត្រតក្កកម្ម ត្រូវតែគោរពឲ្យបាននូវ "វិធានឯកភាពនៃតក្កកម្ម" ។ វិធានឯកភាពនៃតក្កកម្ម សំដៅដល់ការហាមឃាត់ចំពោះ លទ្ធភាពផ្តល់តក្កកម្មច្រើន នូវប្រកាសនីយបត្រតែមួយ។

#### ២.១.១ ពាក្យសុំ

អ្នកដាក់ពាក្យត្រូវបញ្ជាក់ក្នុងពាក្យសុំឲ្យបានច្បាស់លាស់ ពីអ្វីដែលអាចឈានដល់ការផ្តល់ជូននូវប្រកាសនីយបត្រតក្កកម្មបានរួមទាំងទិន្នន័យដែលពាក់ព័ន្ធ ទៅនឹងតក្កករ និងភ្ជាប់ជាមួយនូវចំណងជើងរបស់តក្កកម្ម។ ប្រសិនបើអ្នកដាក់ពាក្យសុំមិនមែនតក្កករ អ្នកដាក់ពាក្យសុំ ត្រូវបន្ថែម នូវឯកសារបញ្ជាក់ពីការផ្ទេរសិទ្ធិ ភ្ជាប់មកជាមួយផង។

ពាក្យសុំត្រូវបង្ហាញនូវ ព័ត៌មានដែលទាក់ទងទៅនឹង ឈ្មោះ អាស័យដ្ឋាន សញ្ជាតិ និង លំនៅដ្ឋាន របស់អ្នកដាក់ពាក្យសុំ។ ប្រសិនបើអ្នកដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មនេះ ត្រូវធ្វើតាមរយៈអ្នកតំណាងរបស់តក្កករ អត្តសញ្ញាណរបស់អ្នកតំណាងស្របច្បាប់នោះ ត្រូវដាក់នូវក្នុងពាក្យសុំនោះផងដែរ។

ក្នុងករណីដែលតក្កករ ពុំមានលំនៅដ្ឋានអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្ម សំខាន់ក្នុងប្រទេសកម្ពុជាទេ ការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម ត្រូវធ្វើឡើងតាមរយៈអ្នកតំណាងស្របច្បាប់ ដែលជាភ្នាក់ងារដែលមានទីលំនៅ និងកំពុងប្រកបអាជីវកម្មនៅក្នុងប្រទេសកម្ពុជា និងដែល

[16] ប្រការ៧ នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម

មិនបានបំពេញលក្ខខណ្ឌទាំងឡាយ ដែលបានកំណត់ដោយបញ្ញត្តិ ដោយឡែករបស់ក្រសួងឧស្សាហាកម្ម និងសិប្បកម្ម។

**២.១.២ សេចក្តីអធិប្បាយពីតក្កកម្ម**

សេចក្តីអធិប្បាយនៃតក្កកម្ម មានគោលដៅបញ្ជាក់អំពីព័ត៌មានទាក់ទងទៅនឹង បច្ចេកទេស ឬដំណើរការនៃការផលិតដែលត្រូវបាន ប្រើប្រាស់ដើម្បីបង្កើតតក្កកម្មនោះ។ អត្ថន័យនៃសេចក្តី អធិប្បាយនៃតក្កកម្មនេះ ត្រូវបានកំណត់ដោយប្រកាសរបស់ស្ថាប័នរដ្ឋ។ ក្នុងសេចក្តីអធិប្បាយនេះ ត្រូវបញ្ជាក់អំពីឈ្មោះ ឬចំណងជើងនៃតក្កកម្ម និងបញ្ជាក់អំពីលក្ខខណ្ឌបច្ចេកទេស ដែលពាក់ព័ន្ធនឹងស្នាដៃក្នុងលក្ខខណ្ឌមួយ ដែលអាចយល់បានដោយមន្ត្រីចុះបញ្ជី។ សេចក្តីអធិប្បាយត្រូវពណ៌នា អំពីផលប្រយោជន៍នៃតក្កកម្មដែលយកទៅផលិត និងប្រើប្រាស់ក្នុងវិស័យឧស្សាហាកម្មមួយជាក់លាក់។

**២.១.៣ សេចក្តីអះអាង**

កម្មវត្ថុនៃសេចក្តីសំអាង មានគោលដៅបញ្ជាក់នូវល័ក្ខខ័ណ្ឌបច្ចេកទេស សុទ្ធសាធរបស់ តក្កកម្ម ដើម្បីបញ្ជាក់ថា តក្កកម្មដែលត្រូវបានដាក់ពាក្យនេះមិនស្ថិតនៅក្នុងវិស័យណាមួយ ដែលត្រូវបានការពារដោយ ប្រកាសនីយបត្រតក្កកម្មរួចហើយ ឬវិស័យសាធារណៈ ឬដែលបម្រុងទុក ការពារឲ្យតក្កកម្ម ដែលមានសុពលភាពនៅឡើយ។ សេចក្តីសំអាងត្រូវមានលក្ខណៈច្បាស់លាស់ និងសមស្រប។

**២.១.៤ គំនូសបង្ហាញ**

គំនូសបង្ហាញសំដៅទៅលើ សញ្ញាឬគំនូសបំព្រួញ ទាំងឡាយណាដែលអនុញ្ញាតឲ្យអាចយល់ពីតក្កកម្មនោះបាន។ គំនូសបង្ហាញនេះ អាចនឹងត្រូវបានតម្រូវឲ្យភ្ជាប់មកជាមួយឬអត់ អាស្រ័យថាតើគំនូសនេះចាំបាច់ត្រូវតែមាន ដើម្បីយកមកបកស្រាយ ឬពន្យល់អំពីតក្កកម្មនោះ ឬអត់។ នៅក្នុងករណីដែលគំនូសនេះ ត្រូវបានតម្រូវឲ្យមាន អ្នកដាក់ពាក្យស្នើសុំ ត្រូវតែបំពេញនូវគំនូសបង្ហាញនេះ តាមលក្ខណៈដែលតម្រូវឲ្យ ដោយប្រការ៩ នៃប្រកាសលេខ៧០៦ ផងដែរ។

**២.១.៥ ខ្លឹមសារសង្ខេប**

ខ្លឹមសារសង្ខេបគឺជាអត្ថន័យសង្ខេបនៃលក្ខណៈបច្ចេកទេស នៃតក្កកម្មជាកម្មវត្ថុ ការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម សម្រាប់តម្កល់ឯកសារ។ ខ្លឹមសារសង្ខេបត្រូវធ្វើឡើងខ្លី ងាយយល់និងភ្ជាប់ជាមួយដោយគំរូពន្យល់អំពីតក្កកម្ម ដែលត្រូវបានដាក់ពាក្យសុំចុះបញ្ជីនោះ។

## ២.២ ប្រកាសនីយបត្រតក្កកម្មបរទេស

ទាក់ទងទៅនឹង សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម មានន័យថាតក្កកម្ម ដែល បាន រកឃើញ នោះមិនមែននៅក្នុងប្រទេស ដែលបានស្នើសុំចុះបញ្ជីនោះ។

ជាទូទៅប្រកាសនីយបត្រតក្កកម្ម មិនមានអានុភាពពាសពេញពិភពលោកនោះទេ។ ដំបូង ប្រកាសនីយបត្រតក្កកម្ម មានអានុភាពត្រឹមតែដែនដី ដែលបានចុះបញ្ជីប៉ុណ្ណោះ គឺមិនមានវិសាល ភាពនៅគ្រប់ប្រទេស ដែលជាសមាជិតនៃសន្ធិសញ្ញាទេ។ ប្រសិនបើចង់មានអនុភាពនៅកន្លែងណា មួយគេត្រូវចុះបញ្ជីនៅទីនោះ។

សម្រាប់តក្កកម្មដែលធ្លាប់បានទទួលប្រកាសនីយបត្រតក្កកម្មនៅបរទេស អ្នកស្នើសុំត្រូវ បន្ថែម នូវឯកសារមួយចំនួនផ្សេងទៀតដូចជា៖ សេចក្តីអះអាងអំពីសិទ្ធិអាទិភាព ស្របតាមអនុ សញ្ញាទីក្រុងប៉ារីស ដើម្បីអាចទទួលបានសិទ្ធិអទិភាព ក្នុងពេល១២ខែគិតចាប់ពីកាលបរិច្ឆេទចុះ បញ្ជីលើកទី១មក ព្រមទាំងសំណុំលិខិតដែលបានស្នើសុំចុះបញ្ជីនៅបរទេសនោះ និងប្រកាសនីយ បត្រតក្កកម្មបរទេស ដែលបានចុះបញ្ជីរួចរាល់នោះ ស្របតាមកិច្ចព្រមព្រៀង TRIPS។

### ២.២.១ សំណុំលិខិតស្នើសុំនៅឯបរទេស

តាមច្បាប់កម្ពុជាបុគ្គលដាក់ពាក្យសុំត្រូវបំពេញបែបបទដូចជា៖

- ត្រូវដាក់ពាក្យសុំរបស់ខ្លួនទៅមន្ត្រីកាន់កាប់បញ្ជី រួមទាំងកាលបរិច្ឆេទនិងលេខនៃសំណុំលិខិតស្នើសុំ ទាំងឡាយដែលខ្លួនបានដាក់សុំនៅបរទេសដែលមានជាប់ពាក់ព័ន្ធនឹងតក្កកម្មបានអះអាង នូវសំណុំ លិខិតស្នើសុំ។
- ភ្ជាប់មកជាមួយនូវឯកសារចម្លងនៃលិខិតឆ្លើយឆ្លងដែលជាប់ពាក់ព័ន្ធនឹងលទ្ធផល នៃការស្រាវ ជ្រាវ និងលទ្ធផលនៃការត្រួតពិនិត្យ សំណុំលិខិតស្នើសុំបរទេស ដែលដាក់ពាក្យសុំបានទទួល។
- ឯកសារចម្លងនៃប្រកាសនីយបត្រតក្កកម្មដែលបរទេសបានផ្តល់ជូនតាមរយៈលិខិតស្នើសុំបរទេស
- ឯកសារចម្លងសេចក្តីសម្រេចចុងក្រោយដែលបដិសេធ មិនទទួលលិខិតសំណុំស្នើសុំ បរទេស ឬ បដិសេធមិនផ្តល់ឲ្យ ប្រកាសនីយបត្រតក្កកម្មតាមសំណើរបស់អ្នកស្នើសុំ។ រាល់ការចុះបញ្ជី ឬការ តម្កល់ផ្សេងៗ ត្រូវបង់កម្រៃតាមការកំណត់របស់ច្បាប់។

### ២.២.២ សិទ្ធិអាទិភាពនៃសំណុំស្នើសុំ

យោងទៅតាមអនុសញ្ញាទីក្រុងប៉ារីស សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម អាចអម ដោយសេចក្តីប្រកាសមួយដែលអះអាងអំពីអាទិភាពនៃសុំណុំលិខិតស្នើសុំ ដែលបានចុះបញ្ជីមុនគេ ដោយបានដាក់ពាក្យសុំ ឬដោយអ្នកស្នងជំនួសឲ្យបុព្វជនរបស់គេក្នុងប្រទេសណាមួយ ឬច្រើននៅ

ក្នុងតំបន់នៅអន្តរជាតិ ដែលប្រទេសទាំងនោះជាសមាជិកអនុសញ្ញាខាងលើ ឬជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក[17]។

ម្យ៉ាងទៀតក្នុងករណីដែលសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មអមដោយ សេចក្តីប្រកាសដូចដែលមានចែងនៅក្នុងមាត្រា២៧នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម គឺអ្នកដាក់ពាក្យសុំត្រូវផ្តល់ដល់មន្ត្រីកាន់កាប់បញ្ជី តាមពេលវេលាកំណត់នូវឯកសារ ចម្លងនៃសំណុំលិខិតស្នើសុំដែលបានដាក់ជូនមុនគេ និងត្រូវមានការបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម ដោយការិយាល័យដែលបានទទួលសំណុំលិខិតនោះ[18]។

**២.៣ ការកែតម្រូវ ការដកយកទៅវិញ និងការបំបែកសំណុំលិខិតស្នើសុំ**

**២.៣.១ ការកែតម្រូវ ការដកយកទៅវិញសំណុំលិខិតស្នើសុំ**

មុនពេលផ្តល់ប្រកាសនីយបត្រតក្កកម្ម អ្នកដាក់ពាក្យអាចស្នើសុំអាចកែតម្រូវសំណុំលិខិតស្នើសុំរបស់ខ្លួនបានប៉ុន្តែការកែតម្រូវនោះ មិនត្រូវបន្ថែមអ្វីឲ្យលើសពីខ្លឹមសារ ដែលបានបញ្ជាក់នៅក្នុងសំណុំលិខិតពីដំបូងឡើយ[19]។

**២.៣.២ ការបំបែកសំណុំលិខិតស្នើសុំ**

មុនពេលផ្តល់ប្រកាសនីយបត្រតក្កកម្ម អ្នកដាក់ពាក្យសុំអាចសុំបំបែកលិខិតស្នើសុំជាពីរ ឬច្រើនបានដែលហៅថាសំណុំលិខិតស្នើសុំបំបែក។ ប៉ុន្តែសំណុំលិខិតស្នើសុំបំបែកនោះមិនអាចបន្ថែមអ្វីលើសពីខ្លឹមសារដែលបានបញ្ជាក់នៅក្នុងសំណុំលិខិតស្នើសុំពីដំបូងឡើយ។ ហើយសំណុំលិខិតស្នើសុំបំបែកនីមួយៗ ត្រូវបានទទួលបានកាលបរិច្ឆេទសុំចុះបញ្ជី និងកាលបរិច្ឆេទអាទិភាពសំណុំលិខិតស្នើសុំពីដំបូង។ នៅក្នុងករណីដែលប្រកាសនីយបត្រតក្កកម្មមួយត្រូវបានផ្តល់ រួចហើ យទៅតាមសំណុំ លិខិតស្នើសុំដែលបានបំពេញតាមល័ក្ខខ័ណ្ឌតម្រូវនៃការរួមបញ្ចូលតែមួយ នៃ តក្កកម្មដូចដែល មានចែងនៅក្នុងមាត្រា២៣នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម គឺត្រូវចាត់ទុក ជាមូលហេតុអសុពលភាពរបស់ប្រកាសនីយបត្រតក្កកម្មនោះបានឡើយ[20]។

**២.៤ ការពិនិត្យសំណុំស្នើសុំ**

ការដាក់ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មនេះ ត្រូវបញ្ជាក់អំពីជំពូកនៃតក្កកម្មដែលជាកម្មវត្ថុនៃកិច្ចការពារដោយអនុលោមតាមចំណាត់ថ្នាក់អន្តរជាតិនៃប្រកាសនីយបត្រតក្កកម្ម ដែលនៅ

---

[17] មានត្រា២៧នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

[18] មាត្រា២៨នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

[19] មាត្រា២៤ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

[20] មាត្រា២៥ និងមាត្រា២៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

ក្នុងកិច្ចព្រមព្រៀងទីក្រុងស្ត្រាសបួ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៧១។

ការត្រួតពិនិត្យរបស់មន្ត្រីកាន់កាប់បញ្ជី ត្រូវធ្វើឡើងជាពីរដំណាក់កាល មុនពេលចេញប្រកាសនីយបត្រតក្កកម្ម ជូនអ្នកដាក់ពាក្យស្នើសុំ៖ ការពិនិត្យលើការដាក់ពាក្យស្នើសុំ ប្រកាសនីយបត្រតក្កកម្ម និងការត្រួតពិនិត្យលម្អិត។

## ផ្នែកទី២ ការត្រួតពិនិត្យខ្លឹមសារនៃតក្កកម្ម

ការត្រួតពិនិត្យលើខ្លឹមសារនៃតក្កកម្មនេះគឺ សំដៅដល់ការត្រួតពិនិត្យលើលក្ខណៈវិនិច្ឆ័យទាំងបីរបស់តក្កកម្ម ព្រមទាំងពិនិត្យមើលល័ក្ខខ័ណ្ឌហាមឃាត់ដាច់ខាតដែលមានចែងនៅក្នុងមាត្រា៩នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម។ ដោយពុំរាប់បញ្ចូលនូវល័ក្ខខ័ណ្ឌដាច់ខាតចំពោះតក្កកម្មដែលមានចែងនៅក្នុងមានត្រា៩ ផងដែរ ដោយយើងនឹងធ្វើការសិក្សាអំពីលក្ខណៈវិនិច្ឆ័យទាំងបីនៃតក្កកម្មតាមខ្លឹមសារដែលមានចែងនៅក្នុងមានត្រា៥ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម ដែលមន្ត្រីកាន់កាប់បញ្ជីត្រូវតែធ្វើការត្រួតពិនិត្យថាតើ តក្កកម្មនោះថ្មីឬទេ? មានជំហានរកឃើញ ឬទេ និងអាចនិយាយយកទៅអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្មបានដែរឬទេ?

### ១. តក្កកម្មថ្មី

ចំពោះតក្កកម្មថ្មីនេះគឺនៅក្នុងច្បាប់បានបង្កើតនូវល័ក្ខខ័ណ្ឌជាគោលការណ៍មួយនៅក្នុងការកំណត់ ប៉ុន្តែក៏មានការទទួលស្គាល់នូវអញ្ញត្រកម្ម មួយចំនួនដែរ។ ទាក់ទងទៅនឹងគោលការណ៍ នេះផងដែរ មាត្រា៦នៃច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្មបានចែងថា៖ តក្កកម្មដែលអាចចាត់ ទុកថាថ្មីបានលុះត្រាតែតក្កកម្មនោះ ពុំទាន់មានត្រូវអ្នកណារកឃើញពីមុន។ ការរកឃើញពីមុន គឺតក្កកម្មដែលសាធារណៈជននៅកន្លែងណាមួយនៅលើពិភពលោកបានដឹង មុនកាលបរិច្ឆេទសុំ ចុះបញ្ជីសំណុំលិខិតស្នើសុំ ឬកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំនោះ តាមរយៈការផ្សព្វផ្សាយប្រើរូបភាពជាក់ស្តែង ឬដោយប្រើមាត់តាមរយៈការប្រើតក្កកម្មនោះ ឬតាមរយៈមធ្យោបាយផ្សេងៗ។ ការពិតទៅគោលការណ៍នេះ គិតទៅដល់វត្តមាននៃស្ថានភាពបច្ចេកទេស របស់តក្កកម្មនោះ និងទៅដល់កាលបរិច្ឆេទសុំចុះបញ្ជីនៃតក្កកម្មនោះទៀតផង។ នៅក្នុងន័យ នេះតក្កកម្មដែលអាចចាត់ទុកថាថ្មី លុះត្រាតែកាលបរិច្ឆេទស្នើសុំចុះបញ្ជី សាធារណៈជនដឹងទាំងឡាយសុទ្ធតែពុំទាន់បានដឹងអំពីតក្កកម្មនេះ។ ការដឹងអំពីតក្កម្មនេះ ពុំសំដៅថាទាល់តែសាធារណៈជនទាំងនោះអាចស្គាល់ ឬយល់ជាក់លាក់នោះឡើយ ប៉ុន្តែសំដៅ ទៅដល់ត្រឹមតែការដឹងមានបច្ចេកទេសនៃតក្កកម្មនោះ ក្នុងកម្រិតដែលអាចអនុវត្តតក្កកម្មបាន គឺការគ្រប់គ្រាន់សម្រាប់បដិសេធភាពថ្មីរបស់តក្កកម្មនោះបានហើយ។

ទន្ទឹមគ្នានឹងផងដែរនៅក្នុងមាត្រា៦ ដដែលបែរជាបានបង្កើតនូវ អញ្ញត្រកម្មចំនួនពីរ ឲ្យដល់គោលការណ៍ខាងលើតាមរយៈការបង្កើត ឲ្យមាននូវរយៈពេលអនុគ្រោះមួយ និងការបដិសេធ

ចោលនូវការបែកធ្លាយព័ត៌មានប្រភពផ្ទាល់ពីអ្នកដាក់ពាក្យ។ នៅក្នុងទ្រឹស្តីអញ្ញត្រកម្ម នឹងមិនត្រូវចាត់ទុកការដឹងឮដល់សាធារណៈជននោះឡើយ ចំពោះករណីពីរយ៉ាងគឺ៖

១ បើសិនបើការដឹងដល់សាធារណៈជន ចំពោះតក្កកម្មដែលបានបង្កើតឡើងក្នុងអំឡុងពេល១២ខែ មុនកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ឬកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំ។ រយៈពេល១២ខែនេះ គឺត្រូវចាប់ទុកដូចជារយៈពេលអនុគ្រោះមួយ ចំពោះរាល់ការបែកធ្លាយចេញមកក្រៅនូវព័ត៌មានដែលទាក់ទងនឹង តក្កកម្មជាយថាហេតុណាមួយនោះ ដោយមិនខ្វាយខ្វល់ពីប្រភព និងពីទម្រង់នៃការបែកធ្លាយមកនោះឡើយ។

២. ប្រសិនបើជាការធ្វើឲ្យមានការលេចឮខ្ចរខ្ចាយព័ត៌មានពីតក្កកម្មនោះ ដែលកើតឡើងតាមរយៈអ្នកដាក់ពាក្យស្នើសុំ ឬតាមរយៈអ្នកស្នងបន្តរបស់បុព្វជន ក៏ដូចជាការរំលោភសិទ្ធិ របស់ ភាគីទីបីមកលើអ្នកដាក់ពាក្យស្នើសុំ ឬមកលើអ្នកស្នងបន្តរបស់បុព្វជន ទើបបណ្តាលឲ្យលេចឮខ្ចរខ្ចាយព័ត៌នោះបាន។ ដូចនេះអញ្ញត្រកម្មទី២ ទាមទារឲ្យអ្នកដាក់ពាក្យស្នើសុំ ត្រូវបង្ហាញភស្តុតាងអំពីប្រភពនៃការបែកធ្លាយព័ត៌មានស្តីពីតក្កកម្មនេះ ក្នុងករណីដែរអ្នកដាក់ពាក្យស្នើសុំរូបនោះប្រាថ្នាចង់បានបញ្ជាក់អំពីភាពថ្មីនៃតក្កកម្មរបស់ខ្លួន ដើម្បីអាចចុះបញ្ជីបាន។

**២. ជំហានរកឃើញថ្មី**

ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម បានចែងថា ចាត់ទុក ថា៖ តក្កកម្មត្រូវចាត់ទុកថាត្រូវមានជំហានរកឃើញថ្មី ប្រសិនបើតក្កកម្មនោះមិនអាចឲ្យបុគ្គលដែល មានកម្រិតជំនាញធម្មតាក្នុងជំនាញយល់ដឹងបាន ពោលគឺបុគ្គលដែលមានចំណេះដឹងធម្មតា នៅក្នុងវិស័យ នៃតក្កកម្មដែលកំពុងតែស្នើសុំចុះបញ្ជីនោះ មិនអាចយល់ដឹងអំពីដំណោះស្រាយនៃ បញ្ហាចោទចំពោះតក្កកម្មនោះបាន។ នៅក្នុងគំនិតនេះយើងអាចនិយាយថា ជំហានរកឃើញថ្មីនេះសំដៅដល់កម្រិតនៃបច្ចេកវិទ្យារបស់តក្កកម្ម ដែលត្រូវតែខ្ពស់ជាងកម្រិតជំនាញធម្មតា។[21]

កាលបើបុគ្គលដែលមានជំនាញធម្មតានោះ ក៏អាចយល់ពីតក្កកម្មដែលកំពុងតែស្នើសុំចុះបញ្ជីនោះដែរ នោះក៏មានន័យថាតក្កកម្មនោះ គឺមិនមានអ្វីពិសេស ដែលគួរឲ្យយើងឲ្យតម្លៃ និងគួរតែការពារឲ្យដល់អ្នកស្នើសុំចុះបញ្ជីនោះដែរ ដូចនេះយើងហៅថា មិនមានជំហានរកឃើញថ្មី។

**៣. អាចយកទៅអនុវត្តបានក្នុងវិស័យឧស្សាហកម្ម**

ដោយសារតែវិធានទាក់ទងនឹងប្រកាសនីយបត្រតក្កកម្ម អនុវត្តតែស្នាដៃតក្កកម្ម នៅក្នុងផ្នែកឧស្សាហកម្មប៉ុណ្ណោះ ដូចនេះតក្កកម្មដែលជាកម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្មនេះ ក៏ត្រូវតែអនុវត្ត

[21] មាត្រា៧ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា

នៅក្នុងវិស័យឧស្សាហកម្មនេះដែរ។ ដោយយោងទៅតាមមាត្រា៨ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម បានចែងថា តក្កកម្មដែលត្រូវចាត់ទុកថាអាចអនុវត្តនៅក្នុងវិស័យឧស្សាហកម្ម ប្រសិនបើតក្កកម្មនោះ អាចត្រូវផលិត ឬត្រូវប្រើប្រាស់នៅក្នុងប្រភេទណាមួយនៃឧស្សាហកម្មបាន។ ពាក្យឧស្សាហកម្ម ដែលត្រូវបានបញ្ញត្តិនៅក្នុងមាត្រានេះ គឺពុំត្រូវបានរឹតត្បិតអត្ថន័យនោះឡើយ ពោលគឺត្រូវតែយល់នៅ ក្នុងន័យទូលាយនៃពាក្យ។

ក្នុងលក្ខណៈវិនិច្ឆ័យនេះមានន័យទូលាយណាស់ ព្រោះស្ទើរតែគ្រប់កម្មវត្ថុទាំងអស់សុទ្ធតែអាចយកទៅអនុវត្ត ឬក៏ប្រើប្រាស់ក្នុងឧស្សាហកម្ម ទោះបីជាកម្មវត្ថុស្ថិតនៅក្នុងដំណាក់កាលស្រាវជ្រាវក៏ដោយប៉ុន្តែទាំងនេះមិនមែនជាបញ្ហាចោទនោះទេ ពីព្រោះមិនមែនឲ្យតែប្រើប្រាស់ ឬ អនុវត្តបានសុទ្ធតែអាចការពារដោយច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មទាំងអស់នោះទេ គឺអាស្រ័យទៅលើប្រភេទដែលអាចការពារបាន។ រួមសេចក្តីមក ប្រសិនបើតក្កកម្មទាំងឡាយណាដែលបានបំពេញតាមលក្ខខណ្ឌតក្កកម្មនោះ អាចទទួលបានការការពារតាមរយៈប្រកាសនីយបត្រតក្កកម្ម ប៉ុន្តែប្រសិនបើមិនគោរពតាមល័ក្ខខ័ណ្ឌទាំងបីនេះទេ មិនអាចស្នើសុំការពារបាននោះទេ។

ទោះបីជាមានការកំណត់រួចមកហើយអំពីលក្ខណៈវិនិច្ឆ័យ ដើម្បីផ្តល់ឲ្យនូវប្រកាសនីយបត្រតក្កកម្ម ប៉ុន្តែផលវិបាក និងភាពមន្ទិលសង្ស័យនៅតែកើតមានឡើងក្នុងបញ្ហាជាក់ស្តែងមួយចំនួន។ ដោយឡែកប្រទេសកម្ពុជាផ្ទាល់ គឺទើបតែបានទទួលការសុំចុះបញ្ជីលើកដំបូង ដើម្បីការពារប្រកាសនីយបត្រតក្កកម្មស្តីពីរថយន្ត ម៉ាកអង្គរ ដើរថាមពលអគ្គិសនី។[22]

ឧទាហរណ៍៖ បុគ្គល"ក" ជាអ្នករកឃើញតក្កកម្មមួយដែលជាតក្កកម្មផលិតម៉ូតូកាលពីមុនមិនទាន់មាននរណាម្នាក់រកឃើញម៉ូតូនៅឡើយ ហើយតក្ករបានទទួលការការពារ តាមរយៈប្រកាសនីយបត្រតក្កកម្ម ប៉ុន្តែក្រោយមកមានបុគ្គល"ខ" បានសិក្សាលើតក្កកម្មនោះដោយធ្វើការច្នៃប្រឌិតឲ្យមានលក្ខណៈល្អប្រសើជាងមុន គឺធ្វើឲ្យម៉ូតូនោះប្រើប្រាស់សាំងតិច ឬផ្តល់ជាប្រយោជន៍ជាច្រើនសម្រាប់អ្នកប្រើប្រាស់។ តើបុគ្គល"ខ" ទទួលបានប្រកាសនីយបត្រតក្កកម្មដែលឬទេ?

ក្នុងករណីនេះ អនុលោមតាមច្បាប់ស្តីពីប្រកាសនីយត្រតក្កកម្ម ការបង្កើតថ្មីរបស់បុគ្គល"ខ" មិនអាចចាត់ទុកថាជាតក្កកម្មថ្មីបានទេ ពីព្រោះតក្កកម្មនេះធ្លាប់ត្រូវបានគេរកឃើញពីមុនរួចមកហើយ ម្យ៉ាងទៀតបើគិតលើការខិតខំប្រឹងរបស់បុគ្គល"ខ" ធៀបនឹងម្ចាស់ដើម គឺម្ចាស់ដើមប្រើពេលច្រើនជាង និងជួបប្រទះការលំបាកខ្លាំងជាងទើបអាចមកដល់ចំណុចនេះបាន។

[22] អ៊ុក វណ្ណារ័ត្ន.....etc នីតិកម្មសិទ្ធិបញ្ញា ឆ្នាំ ២០១៣ ទំព័រ២០ ដល់២១

## ផ្នែកទី៣ ការសម្រេចលើប្រកាសនីយបត្រតក្កកម្ម

លទ្ធផលនៃការសម្រេច បើក្រោយពេលមន្ត្រីកាន់កាប់បញ្ជីបានពិនិត្យលើខ្លឹមសារនៃ សំណុំពាក្យស្នើសុំ រួចហើយថាលក្ខខណ្ឌដែលតម្រូវ នៅមាត្រា៣៥ និង៣៦ មិនត្រូវបានបំពេញត្រឹមត្រូវទេ និងមិនអាចត្រូវបានកែតម្រូវទេ នោះមន្ត្រីកាន់កាប់បញ្ជី នឹងសម្រេចបដិសេធការផ្តល់ជូននូវប្រកាសនីយបត្រតក្កកម្ម(ក)។ បើផ្ទុយទៅវិញ បើពិនិត្យឃើញថាត្រឹមត្រូវរួចរាល់អស់ហើយ និងសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្មដល់អ្នកដាក់ពាក្យស្នើសុំ(ខ)។ រាល់សេចក្តីសម្រេចទាំងឡាយរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ទាក់ទងនិងប្រកាសនីយបត្រតក្កកម្មនេះសុទ្ធតែអាចធ្វើជាកម្មវត្ថុនៃការប្តឹងតវ៉ាដោយភាគីពាក់ព័ន្ធទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល៣ខែ ចាប់គិតពីថ្ងៃចេញសេចក្តីសម្រេចនោះមក[23]។

### ១.ការសម្រេចបដិសេធការផ្តល់ប្រកាសនីយបត្រតក្កកម្ម

មូលហេតុនៃការបដិសេធ ជាគោលការណ៍ ការបដិសេធផ្តល់ប្រកាសនីយបត្រតក្កកម្មជូនដល់អ្នកដាក់ពាក្យស្នើសុំណាម្នាក់ ត្រូវចាត់ទុកថាជាទណ្ឌកម្មខាងរដ្ឋបាល ក្នុងករណីដែលសំណុំនៃពាក្យសុំពុំគោរពនូវលក្ខខណ្ឌតម្រូវរបស់ច្បាប់។ មានមូលដ្ឋានពីរយ៉ាងដែលអាចនាំឲ្យមន្ត្រីកាន់កាប់បញ្ជី ត្រូវតែធ្វើការបដិសេធ គឺការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម មិនគោរពតាមលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។

បើមន្ត្រីកាន់កាប់បញ្ជីបានត្រួតពិនិត្យឃើញថា តក្កកម្មដែលស្នើសុំ ប្រកាសនីយបត្រតក្កកម្មនោះពុំបានបំពេញនូវលក្ខណៈវិនិច្ឆ័យ តាមខ្លឹមសារនៃតក្កកម្ម ដែលបានតម្រូវទេនោះ មន្ត្រីកាន់កាប់បញ្ជីបដិសេធនូវពាក្យស្នើសុំចុះបញ្ជីជាដាច់ខាត[24] ដោយមិនអាចអនុញ្ញាតឲ្យមានការកែតម្រូវ អ្វីឡើយ។ ដូចនេះ កង្វះខាតនៃលក្ខខណ្ឌទាក់ទងនឹងខ្លឹមសាររបស់តក្កកម្មនេះ ជាមូលដ្ឋាននៃការបដិសេធ ដាច់ខាត នៅក្នុងផ្តល់ប្រកាសនីយបត្រតក្កកម្មនេះ។

**ការមិនគោរពលក្ខខណ្ឌទម្រង់**

កាលណាមន្ត្រីកាន់កាប់បញ្ជីបានរកឃើញថា សំណុំលិខិតទាំងនោះ ពុំបានគោរពតាមលក្ខខណ្ឌទម្រង់ ដែលបានកំណត់ទេនោះមន្ត្រីកាន់កាប់បញ្ជី និងណែនាំឲ្យអ្នកដាក់ពាក្យស្នើសុំ ធ្វើការកែតម្រូវសារជាថ្មីឡើងវិញ។ ប៉ុន្តែប្រសិនបើសំណុំលិខិតទាំងនោះ មិនត្រូវបានកែតម្រូវតាមការ

[23] មាត្រា ១២៤ នៃច្បាប់ប្រកាសនីយបត្រតក្កកម្ម

[24] អនុលោមតាម ប្រការ ២៦ ចំណុចទី២ នៃប្រកាសលេខ៧០៦ ក្នុងករណីការសម្រេចបដិសេធ ការផ្តល់ប្រកាសនីយបត្រតក្កកម្ម មន្ត្រីកាន់កាប់បញ្ជីបញ្ជាក់អំពីមូលហេតុនៃការបដិសេធ។

ណែនាំទេ មន្ត្រីកាន់កាប់បញ្ជី នឹងបដិសេធពាក្យស្នើសុំនោះចោល ដោយចាត់ទុកថាដូចជាមិនបានសុំចុះបញ្ជី[25] ។

**១.១ មូលដ្ឋាននៃការបដិសេធ**

ការស្នើសុំដែលមិនគោរពនូវល័ក្ខខ័ណ្ឌ នឹងត្រូវបដិសេធផ្តល់កិច្ចការពារ ហើយលក្ខខណ្ឌទាំងនោះគឺមានពីរ ចំណុចទី១នៅដំណាក់កាលមុនពិនិត្យបច្ចេកទេសគឺដំណាក់កាលពិនិត្យសំណុំឯកសារ និងទី២គឺដំណាក់កាលពិនិត្យបច្ចេកទេស។

**ចំណុចទី១** ក្នុងដំណាក់កាលមុនពិនិត្យបច្ចេកទេសៈ គឺស្ថិតនៅក្នុងការពិនិត្យពាក្យសុំនៅឡើយ ដែលសំណុំលិខិតស្នើសុំកិច្ចការពារត្រូវបានបដិសេធ ក្នុងករណីបន្ទាប់ពីបានតម្រូវឲ្យកែតម្រូវហើយ តែនៅតែមិនបានបំពេញតាមលក្ខខណ្ឌទម្រង់ដែលបានកំណត់ នោះនឹងសម្រេចបដិសេធលើសំណុំលិខិតស្នើសុំនោះ។ តែការបដិសេធនេះមិនប៉ះពាល់ដល់កាលបរិច្ឆេទសំណុំលិខិតស្នើសុំឡើយ កាលបរិច្ឆេទនេះគឺជាកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំ ទោះបីជានៅកម្ពុជាបានបដិសេធសំណុំលិខិតស្នើសុំនោះក៏ដោយ ក៏តក្កករនៅតែអាចស្វែងរកកិច្ចការពារតក្កកម្មនៅបណ្តាលប្រទេសផ្សេងទៀត ហើមានអាទិភាពលើការចុះបញ្ជីមុនព្រោះតែកាលបរិច្ឆេទនោះ។ បញ្ជាក់ថា សិទ្ធិអាទិភាពដែលបានតាមរយៈកាលបរិច្ឆេទចុះបញ្ជីសំណុំលិខិតស្នើសុំនេះ គឺអាចយកអនុវត្តបាននៅបណ្តាលប្រទេសដែលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងជាសមាជិកនៃអនុសញ្ញាទីក្រុងប៉ារីសស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ដែលកម្ពុជាក៏បានដាក់នូវល័ក្ខខ័ណ្ឌនេះដែរដើម្បីទទួលស្គាល់សិទ្ធិអាទិភាពនូវការចុះបញ្ជី[26]។

**ចំណុចទី២** ដំណាក់កាលពិនិត្យបច្ចេកទេសៈ គឺការពិនិត្យបច្ចេកទេស ដែលតក្កកម្មអាចត្រូវបានបដិសេធផ្តល់កិច្ចការពារឡើយ ប្រសិនបើតក្កកម្មណា មិនបានគោរពលក្ខខណ្ឌទាំងបីដែលតម្រូវ ឬបានគោរពត្រឹមត្រូវល័ក្ខខ័ណ្ឌទាំងបីនោះមែនតែជាប្រភេទតក្កកម្មដែលមិនអាចការពារបាននោះត្រូវបដិសេធដូចគ្នាដែរ។ មិនខុសគ្នាឡើយការបដិសេធនេះនៅតែអនុញ្ញាតឲ្យមានការចុះបញ្ជីនៅបណ្តាលប្រទេសដទៃដោយអះអាងពីសិទ្ធិអាទិភាព។

គួររំលឹកដែលថា ករបដិសេធរបស់មន្ត្រីកាន់កាប់បញ្ជី ប្រសិនបើយល់ឃើញថាមិនត្រឹមត្រូវនោះអ្នកដាក់ពាក្យសុំ អាចធ្វើការប្រឆាំងតវ៉ាទៅនឹងសេចក្តីសម្រេចបដិសេធមិនផ្តល់កិច្ចការពារ ចំពោះតក្កកម្មបាន ដោយសារតែសេចក្តីសម្រេចនេះមានចរឹតលក្ខណៈជាសេចក្តីសម្រេចរដ្ឋបាលដោយអាស្រ័យទៅតាមប្រភេទ និងតួនាទីរបស់អ្នកចេញសេចក្តីសម្រេច ដូច្នេះសេចក្តីសម្រេចក្នុង

[25] មាត្រា៣៤(២) នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

[26] មាត្រា២៧ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

ការបដិសេធផ្តល់កិច្ចការពារ អាចប្តឹងទៅតុលាការដើម្បីជំទាស់បាន ក្នុងកំឡុងពេល៣ខែគិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចនោះមក[27]។

**២. ការសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្ម**

កាលបើទាំងល័ក្ខខ័ណ្ឌគ្រឹះ និងល័ក្ខខ័ណ្ឌទម្រង់ ត្រូវបានគោរពគ្រប់គ្រាន់អស់ហើយ មន្ត្រីកាន់កាប់បញ្ជី ត្រូវសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្មជូនដល់អ្នកស្នើសុំ។ នៅក្នុងករណីនេះការសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្ម ជូនដល់អ្នកស្នើសុំ គឺតម្រូវឲ្យមន្ត្រីកាន់កាប់បញ្ជី ចេញលិខិតបញ្ជាក់អំពីការផ្តល់ប្រកាសនីយបត្រតក្កកម្មមួយច្បាប់ និងផ្តល់ប្រកាសនីយបត្រតក្កកម្មចម្លងមួយច្បាប់ជូនដល់អ្នកដាក់ពាក្យស្នើសុំនោះ[28]។ បន្ទាប់មកមន្ត្រីកាន់កាប់បញ្ជីត្រូវតែកត់ត្រាប្រកាសនីយបត្រតក្កកម្មដែលផ្តល់ជូនទៅក្នុងបញ្ជីសម្រាប់ប្រកាសនីយបត្រតក្កកម្ម។ សេចក្តីចម្លងនៃប្រកាសនីយបត្រតក្កកម្មនេះ អាចនឹងត្រូវផ្តល់ជូនទៅបុគ្គលណាម្នាក់ (សាធារណជន) ដែលមានប្រយោជន៍ក្រោមរូបភាព ជាការជាវពីរដ្ឋទៅតាមតម្លៃដែលបានកំណត់។

ជាងនេះទៅទៀត ក្រោយពីបានទទួលប្រកាសនីយបត្រតក្កកម្មនេះ ម្ចាស់នៃប្រកាសនីយបត្រអាចស្នើសុំឲ្យមន្ត្រីកាន់កាប់បញ្ជីធ្វើការកែសម្រួលនៅក្នុងអត្ថបទ ឬគំនូសបង្ហាញរបស់ប្រកាសនីបត្រតក្កកម្មនោះ ដើម្បីកំណត់ពីទំហំនៃការការពារប្រកាសនីយបត្រតក្កកម្មនោះបាន វៀរលែងតែការកែសម្រួលនោះ នាំឲ្យប្រែប្រួលខ្លឹមសារ ដូចបានចែងនៅក្នុង សំណុំ លិខិតស្នើសុំ ពីដំបូងដែលសម្រាប់ ធ្វើជាមូលដ្ឋាន ឈានទៅដល់ការផ្តល់ប្រកាសនីយបត្រតក្កកម្មនេះ[29]។

ជាចុងក្រោយបើកត់សំគាល់ឃើញថា ខុសអំពីនីតិបារាំង គឺនីតិខ្មែរ ពុំមានមាត្រាណាមួយនៃច្បាប់ដែលតម្រូវឲ្យមន្ត្រីកាន់កាប់បញ្ជី មានកាតព្វកិច្ច ចុះផ្សាយនៅពាក្យស្នើសុំនោះ ដើម្បីអាចអនុញ្ញាតឲ្យតតីយជន មានប្រយោជន៍ចូលខ្លួនមក អះអាងសិទ្ធិប្រឆាំងនឹងការសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្មនោះសោះឡើយ ថ្វីត្បិតតែច្បាប់នេះបានតម្រូវឲ្យក្រសួងឧស្សាហកម្ម និងសិប្បកម្មចុះផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការ នូវរាល់ព័ត៌មានដែលត្រូវចុះផ្សាយជាសាធារណក៏ដោយ[30]។

**២.១ ការជូនដំណឹងពីការផ្តល់ប្រកាសនីយបត្រតក្កកម្ម**

មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យស្នើរសុំជាលាយលក្ខណ៍អក្សរ អំពីរការសម្រេចផ្តល់ ឬការបដិសេធការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ត

[27] សារណាបញ្ចប់ការសិក្សា និស្សិតឈ្មោះ គឹម ច័ន្ទណារិទ្ធ ឆ្នាំ២០១៣ ទំព័រ៣១-៣២

[28] មាត្រា៣៩ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

[29] មាត្រា៤០ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

[30] មាត្រា១២៩ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

ប្រយោជន៍។ ក្នុងករណីការសម្រេចបដិសេធការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រ ម៉ូដែលមានអត្ថប្រយោជន៍ មន្ត្រីកាន់កាប់ត្រូវបញ្ជាក់អំពីមូលហេតុនៃការបដិសេធនោះ។ ក្នុងករណីការសម្រេចផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើអ្នកដាក់ពាក្យសុំឲ្យបង់កម្រៃសម្រាប់ការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបន បត្រម៉ូដែលមានអត្ថប្រយោជន៍ ក្នុងរយៈពេលកំណត់គឺ ៣(បី)ខែ ចាប់ពីថ្ងៃជូនដំណឹង[31]។

**២.២ ការប្រកាសផ្សាយអំពីការផ្តល់ប្រកាសនីយបត្រតក្កកម្ម**

ក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាល័ក្ខខ័ណ្ឌដែលមានចែង នៅក្នុងច្បាប់នេះត្រូវបានបំពេញរួចរាល់ហើយនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវដំណើរការផ្តល់ប្រកាសនីយបត្រតក្កកម្មជូនអ្នកស្នើសុំ។ នៅពេលផ្តល់ប្រកាសនីយបត្រតក្កកម្ម មន្ត្រីកាន់កាប់ត្រូវចុះផ្សាយសេចក្តីបញ្ជាក់អំពីការផ្តល់ប្រកាសនីយបត្រតក្កកម្ម ចេញលិខិតបញ្ជាក់អំពីការផ្តល់ប្រកាសនីយបត្រតក្កកម្មមួយច្បាប់ និងប្រកាសនីយបត្រតក្កកម្មចម្លងមួយច្បាប់ ជូនដល់អ្នកស្នើសុំ។

**២.៣ រយៈពេលនៃការការពារ**

រយៈពេលនៃការការពារប្រកាសនីយបត្រតក្កកម្មមានចែងនៅក្នុងមាត្រា៩៥ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម គឺមានរយៈពេលការពារ២០ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីនៃការស្នើសុំចុះបញ្ជីប្រកាសនីយបត្រក្កកម្ម ហើយតក្កកម្មនោះត្រូវតែបំពេញតាមលក្ខខណ្ឌទាំងអស់ដែលមានចែងក្នុងច្បាប់នេះ។

## ផ្នែកទី៤ កាតព្វកិច្ចដែលកើតចេញពីប្រកាសនីយបត្រតក្កកម្ម

**១. កាតព្វកិច្ចដែលកើតចេញពីប្រកាសនីយបត្រតក្កកម្ម**

ត្បិតតែប្រកាសនីយបត្រតក្កកម្ម អាចចាត់ទុកជាប្រភពនៃសិទ្ធិផ្តាច់មុខក្នុង ការធ្វើអាជីវកម្មលើតក្កកម្ម ដែលរដ្ឋព្រមផ្តល់ដល់ម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនេះក៏ដោយ ក៏ភាពជាម្ចាស់ នៃប្រកាសនីយបត្រនេះ នឹងប្រឈមមុខទៅនឹងបញ្ហាចោទ២យ៉ាងៈ ទីមួយ គឺបន្ទុកនៃកាតព្វកិច្ច ដែលតម្រូវមួយចំនួន ជាថ្នូនៃសិទ្ធិដែលផ្តល់ឲ្យនេះ និងទីពីរគឺហានិភ័យនៃការប្រកាសមោឃភាព នៃប្រកាសនីយបត្រតក្កកម្មនោះចោលទៅវិញ នៅក្នុងករណីដែលមានបណ្តឹងពីវិការៈមួយចំនួន ក្រោយពេលសម្រេចផ្តល់ប្រកាសនីយបត្រនេះ។

**១.១ កាតព្វកិច្ចបង់កម្រៃប្រចាំឆ្នាំ**

ដើម្បីធានាឲ្យបាននូវសុពលភាពនៃប្រកាសនីយបត្រតក្កកម្ម ក៏ដូចជាសំណុំលិខិត នៃពាក្យស្នើសុំទាំងអស់ផងដែរ ម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម មានកាតព្វកិច្ចត្រូវបង់កម្រៃប្រចាំឆ្នាំជូន

[31] ប្រការ២៦ និង២៧ នៃប្រកាសស្តិពីការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

មន្ត្រីកាន់កាប់បញ្ជី។ នៅក្នុងកំឡុងពេលនៃសុពលភាពរបស់ប្រកាសនីយបត្រតក្កកម្ម កម្រៃនេះនឹងត្រូវបង់ជូនមន្ត្រីកាន់កាប់បញ្ជី ១ឆ្នាំម្តងៗ ជារៀងរាល់ឆ្នាំ គិតរាប់ចាប់ពីពេលមួយឆ្នាំ ក្រោយកាលបរិច្ឆេទសុំចុះបញ្ជីស្នើសុំ គឺរយៈពេល០៦ខែ គិតចាប់ពីពេលជូនដំណឹង អំពីការផ្តល់ប្រកាសនីយបត្រតក្កកម្មនេះជូនមក[32] ។

រយៈពេលអនុគ្រោះមួយ អាចនឹងត្រូវបានផ្តល់ឲ្យចំពោះរាល់ការយឺតយ៉ាវក្នុង ការបង់កម្រៃប្រចាំឆ្នាំ ជាថ្នូរនឹងការបង់ប្រាក់កម្រៃបន្ថែមលើការយឺតយ៉ាវនេះ ទៅតាមតម្លៃកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងឧស្សាហាកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[33]។ ករណីដែលពុំបានបង់កម្រៃប្រចាំឆ្នាំនេះ នឹងអាចក្លាយទៅជាកម្មវត្ថុនៃការលុបប្រកាសនីយបត្រតក្កកម្មដែលផ្តល់ជូននោះចោលទៅវិញ[34] ។

### ១.២ កាតព្វកិច្ចធ្វើអាជីវកម្មលើតក្កកម្ម

បើទោះបីជាកាតព្វកិច្ចក្នុងការធ្វើអាជីវកម្ម លើតក្កកម្មនេះ ពុំត្រូវបានបញ្ញាតិដោយជាក់ស្តែងនៅក្នុងច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មនេះក៏ដោយ ក៏កាតព្វកិច្ចធ្វើអាជីវកម្មនេះ ហាក់ស្តែងឡើងទន្ទឹមនឹងសិទ្ធិផ្តាច់មុខក្នុងការធ្វើអាជីវកម្មលើតក្កកម្ម ដែលច្បាប់នេះបានប្រគល់ជូនម្ចាស់ប្រកាសនីយបត្រទាំងឡាយផងដែរ។ ផ្អែកតាមការបកស្រាយច្រាស់ ឬផ្ទុយទៅលើអត្ថន័យនៃមាត្រា៥៦ នៃច្បាប់ដែលចែងថា៖ នៅពេលដែលមានការស្នើសុំទៅរដ្ឋមន្ត្រី នៃក្រសួងឧស្សាហាកម្ម និងសិប្បកម្ម ព្រោះរយៈពេល ៤ឆ្នាំ គិតពីកាបរិច្ឆេទសុំចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម ឬ៣ឆ្នាំ គិតចាប់ពីផ្តល់ប្រកាសនីយបត្រតក្កកម្ម ដោយយកកាលបរិច្ឆេទមួយណាដែលផុតកំណត់ក្រោយគេ រដ្ឋមន្ត្រីអាចចេញអាជ្ញាបណ្ណបាន ប្រសិនបើផ្អែកទៅលើការពិនិត្យឃើញថាតក្កកម្មដែលបានផ្តល់ប្រកាសនីយបត្រតក្កកម្មរួចហើយនោះ មិនត្រូវបានធ្វើអាជីវកម្ម ឬធ្វើអាជីវកម្មពេញលេញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា យើងអាចកំណត់បានយ៉ាងប្រាកដថា ច្បាប់នេះបានបង្ខំឲ្យម្ចាស់ប្រកាស នីយបត្រតក្កកម្ម ត្រូវតែមានកាតព្វកិច្ចធ្វើអាជីវកម្ម លើតក្កកម្មដែលខ្លួនបានស្នើសុំប្រកាសនីយបត្ររួចរាល់ហើយនោះ។ ទណ្ឌកម្មនៃការមិនគោរពកាតព្វកិច្ចនេះ ពុំមែនជាការលុបចេញពីបញ្ជីដែលបានចុះរួចរាល់ហើយ ដូចក្នុងករណីនៃសិទ្ធិលើម៉ាកនោះទេ ប៉ុន្តែគឺជាការតម្រូវឲ្យមានអាជ្ញាប័ណ្ណបញ្ជាដើម្បីធានាឲ្យបានថាការធ្វើអាជីវកម្មពិតប្រាកដ និងគ្រប់គ្រាន់មួយលើតក្កកម្មនោះទៅវិញ ពោលការបង្ខំឲ្យធ្វើអាជីវកម្មដោយរដ្ឋតែម្តង។

[32] មាត្រា៤៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

[33] មាត្រា៤៦ និង មាត្រា១៣០ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

[34] មាត្រា៤៥ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

## ២. មោឃភាពនៃប្រកាសនីយបត្រតក្កកម្ម

តក្កកម្មដែលបានចុះបញ្ជីរួចរាល់ហើយ អាចក្លាយទៅជាកម្មវត្ថុនៃការប្រកាសមោឃភាពបាន[35]។ គ្រប់បុគ្គលដែលមានការពាក់ព័ន្ធ ឬមានផលប្រយោជន៍ទាំងឡាយ អាចស្នើសុំទៅតុលាការមានសម្ថកិច្ច ឲ្យសម្រេចទុកជាមោឃៈ នូវប្រកាសនីយបត្រតក្កកម្មបាន។

### ២.១ មូលហេតុនៃមោឃភាព

មូលហេតុដែលនាំឲ្យមានការសម្រេចមោឃភាពលើប្រកាសនីយបត្រតក្កកម្មដែលបានចុះបញ្ជីរួចរាល់ រួមមានៈ តក្កកម្មនោះផ្ទុយទៅនឹងវាក្យខ័ណ្ឌទី២ និងទី៣ នៃមាត្រា៣ ទាក់ទងទៅនឹងនិយមន័យនៃតក្កកម្មនៃមាត្រា៤ ទាក់ទងនឹងល័ក្ខខ័ណ្ឌ ជាគ្រឹះនៃតក្កកម្ម និងតក្កកម្មដែលត្រូវបានហាមឃាត់ដាច់ខាត ឬប្រសិនបើម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម មិនមែនជាតក្ករ ឬមិនមែនជាអ្នកស្នងបន្តពីតក្ករទេនោះ។ ក្នុងករណីនៃបណ្ដឹងសុំមោឃភាពនេះ បន្ទុកនៃភស្តុតាងអំពីហេតុនៃមោឃភាព ត្រូវធ្លាក់ទៅលើបុគ្គលដែលជាអ្នកប្ដឹងអំពីមោឃភាពនេះ។

កាលបើមោឃភាពនៃប្រកាសនីយបត្រតក្កកម្ម ត្រូវបានប្រកាសដោយតុលាការ អានុភាពប្រតិសកម្មនៃមោឃភាពនេះ នឹងបណ្ដាលឲ្យរាល់សំណុំលិខិត និងឯកសារ គតិយុត្តទាំងឡាយដែលទាក់ទងទៅនេងប្រកាសនីយបត្រមោឃភាពនេះ រួមទាំងសេចក្ដីអះអាង ឬផ្នែកនៃសេចក្ដី អះអាងនោះផង ត្រូវទុកជាមិនបានការ និងអស់សុពលភាព ចាប់ពីថ្ងៃផ្ដល់ប្រកាសនីយបត្រតក្កកម្មនេះមក។ សេចក្ដីសម្រេចជាស្ថពរ របស់តុលាការអំពីមោឃភាព ត្រូវជូនដំណឹងដល់មន្ត្រី កាន់កាប់បញ្ជីដើម្បីកត់ត្រា និងចុះផ្សាយឲ្យបានឆាប់រហ័សតាមលទ្ធភាពដែលអាចធ្វើបាន។

[35] មាត្រា ៦៥ ដល់មាត្រា ៦៨ នៃច្បាប់ស្ដីពីប្រកាសនៅយបត្រតក្កកម្ម

# ជំពូកទី៣

# សិទ្ធិដែលកើតចេញពីប្រកាសនីយបត្រតក្កកម្ម និងយន្តការដោះស្រាយវិវាទ

# ជំពូកទី៣
# សិទ្ធិដែលកើតចេញពីប្រកាសនីយបត្រតក្កកម្ម ការរំលោភសិទ្ធិ និងយន្តការដោះស្រាយវិវាទ

## ផ្នែកទី១ សិទ្ធិដែលកើតចេញពីប្រកាសនីយបត្រតក្កកម្ម

ការសម្រេចជូនអ្នកដាក់ពាក្យស្នើសុំ នូវប្រកាសនីយបត្រតក្កកម្ម ក៏មានន័យដែរថា រដ្ឋព្រមទទួលស្គាល់សិទ្ធិមួយចំនួនដែលច្បាប់នេះបានកំណត់ ឲ្យអ្នកស្នើសុំ នៅក្នុងឋានៈជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម។ ការផ្ទេរនូវសិទ្ធិនេះ គឺអាចអនុញ្ញាតឲ្យម្ចាស់ប្រកាសនីយបត្រតក្កកម្ម អាចហាមឃាត់តតីយជនណាម្នាក់ មិនឲ្យធ្វើអាជីវកម្ម លើតក្កកម្ម ដែលទទួលការការពារ ប្រកាសនីយបត្រតក្កកម្ម ដោយគ្មានការយល់ព្រមពីម្ចាស់ ប្រកាសនីយបត្រតក្កកម្ម នឹងត្រូវចាត់ទុកជាការរំលោភសិទ្ធិស្របច្បាប់របស់តក្កកម្មនេះ ហើយក្នុងករណីនេះ និងអាចមានយន្តការដោះស្រាយ សំដៅធានាសិទ្ធិស្របច្បាប់ដល់ម្ចាស់សិទ្ធិផងដែរ។

### ១. ទំហំនៃសិទ្ធិ

#### ១.១ ការធ្វើអាជីវកម្មដោយម្ចាស់សិទ្ធិ

សិទ្ធិផ្តាច់មុខនៃម្ចាស់ប្រកាសនីយបត្រតក្កកម្ម៖ ការធ្វើអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជានូវតក្កកម្មដែលបានទទួលប្រកាសនីតបត្រតក្កកម្ម រួចហើយ ដោយបុគ្គលដទៃទៀត ចាំបាច់ត្រូវតែមានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្មនោះ[36] ។ ក្រៅពីការគោរពនូវគោលការណ៍ពេលវេលា (អាជ្ញាយុកាលនៃសិទ្ធិ) និងដែនដីនៃសិទ្ធិ ម្ចាស់នៃប្រកាសនីយបត្រតក្កកម្មមានសិទ្ធិផ្តាច់មុខទៅលើតក្កកម្មនោះក្នុងរបៀបស្រដៀងគ្នា នឹងសិទ្ធិកម្មសិទ្ធិទូទៅដែរ ពោលគឺ សិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែង។

#### ១.២ ការកម្រិតសិទ្ធិធ្វើអាជីវកម្ម

ការធ្វើអាជីវកម្មលើតក្កកម្ម ដែលទទួលបានប្រកាសនីយបត្រតក្កកម្មរួចហើយសំដៅដល់សកម្មភាពពីរប្រភេទគឺ៖ ប្រកាសនីយបត្រតក្កកម្ម សម្រាប់អាជីវកម្មចំពោះផលិតផល និងប្រកាសនីយបត្រតក្កកម្មចំពោះដំណើរការផលិតតក្កកម្ម។ ទាក់ទងនឹងសិទ្ធិរបស់ប្រកាសនីយបត្រតក្កកម្មទៅលើផលិតផលនេះរួមមាន៖ ទាំងទៅលើការផលិត ការនាំចូលការផ្គត់ផ្គង់សម្រាប់ការលក់ និងសម្រាប់ការប្រើប្រាស់ផលិតផលនោះ និងទាំងការស្តុកទុកផលិតផលនោះ ក្នុងគោលបំណងផ្គត់ផ្គង់សម្រាប់លក់ ឬសម្រាប់ប្រើប្រាស់ផងដែរ។

[36] មាត្រា៨១ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

ទាក់ទងទៅនឹងសិទ្ធិរបស់ប្រកាសនីយបត្រតក្កកម្មលើដំណើរការផលិតវិញ សិទ្ធិនេះគឺមានវិសាលភាពគ្រប់ដណ្តប់ទាំងការប្រើប្រាស់ នូវដំណើការផលិតកម្មដោយផ្ទាល់ផង និងទាំងលើសកម្មភាពណាមួយនៃការផលិត ការនាំចូល ការផ្គត់ផ្គង់ ដែលទាំងសម្រាប់លក់ និងទាំងសម្រាប់ប្រើប្រាស់ និងការស្តុកទុកផលិតផលក្នុងគោលបំណងផ្គត់ផ្គង់ការលក់ និងស្រាប់ការប្រើប្រាស់ផងទៀត។

ដោយឡែកនៅក្នុងនីតិបារាំង ក៏ត្រូវចាត់ទុកថាចូលក្នុងវិសាលភាពនៃសិទ្ធិ របស់ម្ចាស់ប្រកាសនីយបត្រតក្កកម្មនេះផងដែរ រាល់ផលិតផល និងដំណើរការផលិតកម្ម ទាំងឡាយណាដែល ពុំមែនជាតក្កកម្ម ប៉ុន្តែបានចូលរួមក្នុងការផ្តល់មធ្យោបាយ ដើម្បីសម្រេចបាននូវតក្កកម្មនោះ។ ក៏ប៉ុន្តែចំណុចនេះហាក់ពុំទាន់បានទទួលស្គាល់ដោយច្បាប់ខ្មែរស្តីពីប្រកាសនីយបត្រនេះឡើយ។

## ២. អាជីវកម្មដោយរដ្ឋាភិបាល និងអាជ្ញាប័ណ្ណបញ្ជា

### ២.១ អាជីវកម្មដោយរដ្ឋាភិបាល

ការសម្រេចអនុញ្ញាត ត្រូវតែឈរលើមូលដ្ឋាននៃការបម្រើផលប្រយោជន៍ សាធារណៈ ឬមូលហេតុនៃការធានាឲ្យមានការប្រកួតប្រជែងមួយដ៏ស្មោះត្រង់[37]។ ដើម្បីបុព្វហេតុទាំងពីរខាងលើនេះ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម អាចសម្រេចជ្រើសរើសតតីយជនណាម្នាក់ ដែលអាចជាអង្គភាពចំណុះរដ្ឋ ឬឯកជនសុទ្ធសាធ ឲ្យធ្វើអាជីវកម្មលើតក្កកម្មបាន ទោះបីជាគ្មានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្មក៏ដោយ។ ការពិតទៅ ការសម្រេចនេះអាចត្រូវចាត់ទុកដូចជាការម្រេចបង្ខំ ឲ្យម្ចាស់ប្រកាសនីយបត្រតក្កកម្ម ធ្វើអាជ្ញាប័ណ្ណលើតក្កកម្ម របស់ខ្លួនដោយគ្រាន់តែតាមរយៈយន្តការនេះ ម្ចាស់ប្រកាសនីយបត្រតក្កកម្មនឹងបាត់បង់សេរីភាពក្នុងការចុះកិច្ចសន្យានេះ ត្រូវធ្វើឡើងដោយរដ្ឋមន្ត្រីតែប៉ុណ្ណោះ។ ប៉ុន្តែម្ចាស់ប្រកាសនីយបត្រនៅតែជាម្ចាស់នៃប្រកាសនីយបត្រ តក្កកម្ម និងជាម្ចាស់អាជ្ញាប័ណ្ណដែលមានសិទ្ធិទទួលបានផលប្រយោជន៍សមរម្យ ដូចករណីអាជ្ញាប័ណ្ណទូទៅ ដដែល។

លើសពីនេះទៅទៀត យន្តការនៃអាជ្ញាប័ណ្ណដោយការសម្រេចរបស់រដ្ឋនេះ ផ្តល់អំណាចសម្រេចធំធេងណាស់ដល់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនេះ[38]។ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម អាចសម្រេចកែប្រែលើខ្លឹមសារនៃអាជ្ញាប័ណ្ណ ឬសម្រេចបញ្ចប់អាជ្ញាប័ណ្ណ នៅក្នុងសុពលភាពនៃអាជ្ញាប័ណ្ណនោះក៏បាន។ តែទោះជាយ៉ាងណាក៏ដោយ ការសម្រេចនេះ គឺគ្រាន់តែជាអាជ្ញាប័ណ្ណមិនដាច់ខាតមួយដោយសារតែច្បាប់នៅតែទទួលស្គាល់សិទ្ធិរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្ម នៅក្នុងការបង្កើតកិច្ចសន្យា អាជ្ញាប័ណ្ណ តាមឆន្ទៈរបស់ខ្លួន និងក្នុងករណីអាជ្ញាប័ណ្ណមានបញ្ហា គឺនៅតែអាចធ្វើបានដដែលជាដដែល[39]។

---

[37] មាត្រា៤៧(១) នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

[38] មាត្រា៤៨ ៤៩ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

[39] មាត្រា៥១ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

ជាចុងក្រោយ ការអនុញ្ញាតនេះ គឺគ្រាន់តែជាសេចក្តីសម្រេចរដ្ឋបាលដែលនៅក្នុងករណីមិនពេញចិត្ត នឹងសេចក្តីសម្រេចនេះ ម្ចាស់ប្រកាសនីយបត្រតក្កកម្មនៅតែមានសិទ្ធិប្តឹងប្រឆាំងតវ៉ា ទៅតុលាការមានសមត្ថកិច្ចបានជានិច្ច[40]។

## ២.២ អាជ្ញាប័ណ្ណបញ្ជា

អាជ្ញាប័ណ្ណប្រភេទនេះ គឺជាកិច្ចសន្យាដែលប្រភេទនោះ រដ្ឋបង្ខំឲ្យម្ចាស់ប្រកាសនីយបត្រតក្កកម្មបង្កើតកិច្ចព្រមព្រៀងមួយជាមួយតតីយជនណាម្នាក់តាមការស្នើសុំរបស់តតីយជននោះ នៅក្រោមរូបភាពជាទណ្ឌកម្ម នៃការមិនធ្វើអាជីវកម្មលើតក្កកម្មដែលខ្លួនបានចុះបញ្ជីរួចរាល់របស់ម្ចាស់ នៃប្រកាសនីយបត្រតក្កកម្មនោះ។ ខុសអំពីច្បាប់បារាំងដែលអាជ្ញាប័ណ្ណបញ្ជានេះ ត្រូវតែជាលទ្ធផលនៃសេចក្តីសម្រេចរបស់តុលាការ រីឯច្បាប់របស់ប្រទេសខ្មែរផ្តល់អំណាចនេះទៅឲ្យរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មតែម្នាក់ឯងប៉ុណ្ណោះ។ សេចក្តីសម្រេចអំពីអាជ្ញាប័ណ្ណបញ្ជាត្រូវតែមានចែងអំពីលក្ខខ័ណ្ឌនៃការធ្វើអាជីវកម្មដែលទទួលអាជ្ញាប័ណ្ណ រួមទាំងចែងអំពីវិសាលភាព និងមុខងារនៃអាជ្ញាប័ណ្ណ ពេលវេលាកំណត់ដែលអ្នកទទួលអាជ្ញាប័ណ្ណ ត្រូវចាប់ផ្តើមធ្វើលើអាជីវកម្មនោះ និងទាំងចំនួនទឹកប្រាក់ និងលក្ខខ័ណ្ឌទូទាត់កម្រៃសមរម្យដែលត្រូវផ្តល់ជូនម្ចាស់ប្រកាសនីយបត្រតក្កកម្មផងទៀត[41]។

ប៉ុន្តែដើម្បីទទួលបានសិទ្ធិធ្វើអាជីវកម្មតាមរយៈអាជ្ញាប័ណ្ណបញ្ជានេះក៏តម្រូវឲ្យតតិយជនដែលជាអ្នកស្នើសុំត្រូវបង្ហាញពីភស្តុតាងដែលច្បាប់បានកំណត់។ យើងអាចបែងចែកលក្ខខ័ណ្ឌទាំងនោះជាពីរ។ ជួនកាលដោយសារតែការមិនធ្វើអាជីវកម្ម ឬធ្វើអាជីវកម្មមិនពេញលេញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលករណីនេះអ្នកទទួលអាជ្ញាប័ណ្ណត្រូវមានកាតព្វកិច្ច អនុវត្តការធ្វើអាជីវកម្ម លើតក្កកម្មឲ្យបានពេញលេញតាមលក្ខខ័ណ្ឌច្បាប់[42] ពុំនោះទេរដ្ឋមន្ត្រីអាចសម្រេចបញ្ចប់អាជ្ញាប័ណ្ណនោះបានដូចនៅក្នុងករណីការធ្វើអាជីវកម្មដោយរដ្ឋាភិបាល ឬដោយមានការអនុញ្ញាតពីរដ្ឋាភិបាលផងដែរ។

ជួនកាលទៀត ដោយសារតែវត្តមាននៃជម្លោះលើការធ្វើអាជីវកម្មលើ ប្រកាសនីយបត្រតក្កកម្មពីរដែលជាកម្មវត្ថុតក្កកម្មទាក់ទងគ្នា។ ក្នុងន័យនេះ ប្រសិនតក្កកម្មពីរស្ថិតក្រោមប្រកាសនីយបត្រតក្កកម្មពីរ ដាច់ដោយឡែកពីគ្នា ដែលតក្កកម្មជាកម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្ម ក្រោយ(ទី២) មានកម្រិតនៃបច្ចេកទេសជឿនលឿន និងមានសារៈសំខាន់ចំពោះសេដ្ឋកិច្ចជាង បើធៀបទៅនឹងតក្កកម្មដែលជាកម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្មមុន(ទី១) ហើយប្រសិនបើតក្កកម្មទី២ មិនអាចនឹងធ្វើអាជីវកម្មបានដោយមិនប៉ះពាល់ដល់ការធ្វើអាជីវកម្មនៃតក្កកម្មទី១ នោះអាជ្ញាប័ណ្ណនេះអាចត្រូវបានស្នើសុំទៅរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម ដោយម្ចាស់នៃប្រកាសនីយបត្រតក្កកម្មក្រោយ(ទី២)នេះ

[40] មាត្រា៥៥ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

[41] មាត្រា៥៧ និងមាត្រា៥៨ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

[42] មាត្រា៥៨ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

ដើម្បីអាចបញ្ចៀសឲ្យផុតនូវការរំលោភសិទ្ធិ របស់ម្ចាស់ប្រកាសនីយបត្រតក្កកម្ម មុន(ទី១) នោះ។ ក្នុងករណីនេះ ផ្អែកទៅតាម**មាត្រា៦០** នៃច្បាប់នេះ នៅពេលមានការស្នើសុំរបស់ម្ចាស់ ប្រកាសនីយបត្រតក្កកម្មមុន (ទី១) រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម ត្រូវសម្រេចឲ្យមានអាជ្ញាប័ណ្ណបញ្ជា ត្រលប់ទៅវិញលើប្រកាសនីយបត្រតក្កកម្មក្រោយ (ទី២) វិញ។ ដូច្នេះ ករណីនេះត្រូវមានអាជ្ញាប័ណ្ណ បញ្ជា ចំនួនពីរ ដែលមានទំនាក់ទំនងនឹងគ្នា។ របបគតិយុត្តដែលត្រូវអនុវត្តលើអាជ្ញាប័ណ្ណបញ្ជាទាំងពីរ គឺដូចគ្នានឹងរបបគតិយុត្តនៃអាជ្ញាប័ណ្ណបញ្ជាទូទៅផងដែរលើកលែងតែការផ្ទេរដែលកើតចេញពីរ អាជ្ញាប័ណ្ណប្រភេទនេះអាចធ្វើបាន តែដោយមានការផ្ទេរប្រកាសនីយបត្រតក្កកម្មនីមួយៗប៉ុណ្ណោះ ពីព្រោះតែបុព្វហេតុនៃការបង្កើតអាជ្ញាប័ណ្ណប្រភេទនេះ គឺដើម្បីបញ្ចៀសនូវជំលោះក្នុងការរំលោភសិទ្ធិគ្នានៃប្រកាសនីយបត្រតក្កកម្មនីមួយៗ នាពេលធ្វើអាជីវកម្មប៉ុណ្ណោះ។

**២.២.១ លក្ខខណ្ឌនៃការចេញអាជ្ញាប័ណ្ណបញ្ជា**

**២.២.២ សេចក្តីសម្រេចចេញអាជ្ញាប័ណ្ណបញ្ជា**

ការសម្រេចចេញអាជ្ញាប័ណ្ណបញ្ជា ត្រូវបែងចែកជាវិសាលភាព និងមុខងារនៃអាជ្ញាប័ណ្ណ ហើយកាលកំណត់ដែលអ្នកទទួលអាជ្ញាប័ណ្ណ ត្រូវបានចាប់ផ្តើមអាជីវកម្មលើតក្កកម្មដែលទទួលបានប្រកាសនីយបត្រតក្កកម្ម។ ចំនួនប្រាក់សមរម្យជូនម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងល័ក្ខខ័ណ្ឌនៃការទូទាត់[43]។

**២.២.៣ សិទ្ធិរបស់អ្នកទទួលបានអាជ្ញាប័ណ្ណបញ្ជា**

អ្នកទទួលបានអាជ្ញាប័ណ្ណបញ្ជាមានសិទ្ធិធ្វើអាជីវកម្មលើតក្កកម្មដែលទទួលបាន ប្រកាសនីយបត្រតក្កកម្មរួច នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទៅតាមល័ក្ខខ័ណ្ឌ ដែលបានចែងនៅក្នុងសេចក្តីសម្រេចនៃការចេញអាជ្ញាប័ណ្ណនោះ។ អ្នកទទួលបានអាជ្ញាប័ណ្ណបញ្ជាត្រូវចាប់ផ្តើមធ្វើអាជីវកម្មលើតក្កកម្មនោះទៅតាមពេលវេលា ដែលបានកំណត់នៅក្នុងសេចក្តីសម្រេចខាងលើ និងត្រូវធ្វើអាជីវកម្មឲ្យបានពេញលេញលើតក្កកម្មនោះ។[44]

## ផ្នែកទី២ ការរំលោភសិទ្ធិ និងយន្តការដោះស្រាយវិវាទ

### ១. ការរំលោភសិទ្ធិ

ដូចនៅក្នុងករណីនៃសិទ្ធិអ្នកនិពន្ធ និងសិទ្ធិលើម៉ាកផងដែរ សិទ្ធិដែលប្រគល់ឲ្យតាមរយៈប្រកាសនីយបត្រតក្កកម្មនេះ ក៏ពិតជាក្លាយជាកម្មវត្ថុនៃការរំលោភបំពានសិទ្ធិដ៏ស្រួចស្រាល់មួយផងដែរ។ ដូច្នេះហើយក្នុងទិសដៅ នៃការធានាឲ្យមានប្រសិទ្ធភាពនូវការការពារសិទ្ធិស្របច្បាប់របស់

[43] មាត្រា៥៧នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

[44] មានត្រា៥៨នៃច្បាប់ស្តីពិប្រកាសនីយបត្រតក្កកម្ម

ម្ចាស់ប្រកាសនីយបត្រតក្កកម្ម ច្បាប់បានបង្កើតនូវយន្តការដោះស្រាយប្រឆាំងនឹង អំពើរំលោភបំពាន ទាំងនេះ ដើម្បីលើកទឹកចិត្តដល់ការសុំប្រកាសនីយបត្រតក្កកម្មនេះផងដែរ។

**១.១ និយមន័យនៃការរំលោភសិទ្ធិ**

ការរំលោភសិទ្ធិនៃប្រកាសនីយបត្រតក្កម្ម សំដៅដល់ការអនុញ្ញាតនូវសកម្មភាពដែលបំពានដល់សិទ្ធិរបស់ម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម ដូចមានចែងក្នុងផ្នែកទី៩ នៃជំពូកទី២ នៃច្បាប់។ ការរំលោភសិទ្ធិក្នុងន័យនេះ គឺស្តែងឡើងនៅក្រោមទម្រង់ជាអំពើក្លែងបន្លំ លើតក្កកម្មដែលបានចុះបញ្ជីការពារដោយប្រកាសនីយបត្រតក្កកម្ម។

ដើម្បីប្រឆាំងនឹងការរំលោភសិទ្ធិនេះ គឺទាមទារនូវការរៀបចំឲ្យនីតិវិធីប្តឹងទៅតុលាការ មានសមត្ថកិច្ច។ ក្នុងករណីនេះមានតែម្ចាស់ប្រកាសនីយបត្រតក្កកម្មតែម្នាក់គត់ ដែលមានគុណភាពគ្រប់គ្រាន់ក្នុងការប្តឹងនេះ។ ផ្ទុយទៅវិញ ម្ចាស់សិទ្ធិដែលទទួលបានតាមរយៈកិច្ចសន្យាអនុប្បទាន ឬតាមរយៈអាជ្ញាប័ណ្ណទាំងឡាយពុំអាចស្នើសុំទៅ តុលាការដោយផ្ទាល់នោះឡើយ ពោលគឺត្រូវស្នើសុំឲ្យម្ចាស់ប្រកាសនីយបត្រតក្កកម្មជាអ្នកប្តឹងទើបបាន។

តែទោះជាយ៉ាងណាក៏ដោយ ដើម្បីបង្ការការរំលោភសិទ្ធិក្នុងបំណង បំពានដល់ការធ្វើ អាជីវកម្មស្របច្បាប់ ឬស៊ើបព័ត៌មានអំពីតក្កកម្មណាមួយនោះ តាមរយៈការប្តឹងនេះហើយច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មបានបញ្ញត្តថា ការចោតប្រកាន់អំពីការរំលោភនេះ មិនអាចធ្វើបានទេ ប្រសិនបើផលិតផលថ្មី ហើយអ្នកដែលត្រូវចោទប្រកាន់នោះសោត បានលើកភស្តុតាងមកបញ្ជាក់ថាផលិតផលនោះមិនត្រូវបានផលិត តាមសំណើរផលិតកម្ម ដែលចោទប្រកាន់ថារំលោភនោះ។ នៅក្នុងករណីនេះផងដែរ តុលាការមានសមត្ថកិច្ចត្រូវតែគិតគូរដល់ ផលប្រយោជន៍ស្របច្បាប់របស់បុគ្គលដែលត្រូវចោទប្រកាន់ថាបានរំលោភនោះ ដោយមិនធ្វើឲ្យលេចឮខ្ចរខ្ចាយអំពីការសម្ងាត់ នៃការផលិតនិងនៃរបរជំនួញរបស់បុគ្គលដែលត្រូវបានចោទប្រកាន់នោះឡើយ។

**២. យន្តការដោះស្រាយវិវាទ**

**២.១ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**

ដំណោះស្រាយក្រៅប្រព័ន្ធតុលាការ ក៏ជាផ្នែកមួយក្នុងការការពារការរំលោភលើអាជីវកម្មតក្កកម្មដែរ។ អំពីការរំលោភសិទ្ធិលើអាជីវកម្មតក្កកកម្ម គឺជាបណ្តឹងអាជ្ញា ដែលបណ្តឹងអាជ្ញាគឺគ្មានការចរចារសម្រុះសម្រួលឡើយ យោងតាមច្បាប់តក្កកម្ម អំពើរំលោភបំពានលើតក្កកម្មគឺជាកម្មវត្ថុនៃបណ្តឹងទៅតុលាការ ដើម្បីចាត់វិធានការប្រឆាំងនឹងអំពើរំលោភបំពាននោះ ក្នុងករណីដែល រកឃើញថាពិតជាមាននូវអំពើរំលោភបំពានលើតក្កកម្មកើតមានមែន នោះទណ្ឌកម្មព្រហ្មទណ្ឌ និងរដ្ឋប្បវេណីនឹងត្រូវយកមកអនុវត្តតាមអំណាចឆន្ទានុសិទ្ធិរបស់តុលាការ បញ្ហាត្រង់ថា តើទណ្ឌកម្មព្រហ្មទណ្ឌអាចយកមកអនុវត្តបានទេ ប្រសិនបើគ្មានបណ្តឹង? អនុលោមតាមច្បាប់តក្កកម្ម បណ្តឹង

ប្រឆាំងនឹងការរំលោភបំពានលើតក្កកម្មគឺត្រូវធ្វើឡើងដោយបុគ្គលដែលមានសិទ្ធិស្របច្បាប់ លើតក្កកម្មដែលអាចជាម្ចាស់នៃតក្កកម្ម ឬបុគ្គលទទួលបានសិទ្ធិតាមអាជ្ញាប័ណ្ណ ឬកិច្ចសន្យាផ្សេងៗទៀត នោះតុលាការនឹងចាត់វិធានការបានតាមការទាមទាររបស់ម្ចាស់បណ្តឹង ហើយឈានទៅដល់ការសម្រេចលើអង្គសេចក្តីបណ្តឹងរំលោភសិទ្ធិអាជីវកម្មតក្កកម្ម។[45] សរុបសេចក្តីមកទណ្ឌកម្មព្រហ្មទណ្ឌគឺកើតឡើងដោយបណ្តឹងរបស់ម្ចាស់សិទ្ធិ នេះមានន័យថាជាចំណាត់ការរបស់សិទ្ធិក្នុងការជ្រើសរើសវិធានការតាមផ្លូវតុលាការ។ ក្រៅពីចំណាត់ការតាមវិធានការតុលាការ វិធានការក្រៅប្រព័ន្ធតុលាការជាជម្រើសមួយមានប្រសិទ្ធភាពដែរ ដែលវិធានការនេះស្តែងឡើងតាមសកម្មភាពមួយចំនួនដូចជាការចរចារ សន្ធានកម្ម និងមជ្ឈត្តការ ហើយឈានទៅរកការបង្កើតកិច្ចព្រមព្រៀង ជាមួយគ្នា។

មានកត្តាណាខ្លះ ដែលជាមូលហេតុជ្រើសរើសយកនូវវិធានការក្រៅប្រព័ន្ធតុលាការមក អនុវត្តចំពោះអំពើនៃការរំលោភបំពានលើសិទ្ធិអាជីវកម្មតក្កកម្ម? ក្នុងកិច្ចការពាណិជ្ជកម្ម បណ្តឹងទៅស្ថាប័នតុលាការអាចធ្វើឲ្យប៉ះពាល់ដល់កិត្តិយសរបស់ក្រុមហ៊ុន ក៏ដូចជាសេដ្ឋកិច្ចរបស់ក្រុមហ៊ុនផង មិនតែប៉ុណ្ណោះតាមរយៈវិធានការនេះមិនផ្តល់ឲ្យមាននូវភាគីចាញ់ ឬឈ្នះឡើយ ភាគីទាំងពីរធ្វើ ការចរចារសម្រុះសម្រួលជាមួយគ្នា ដែលនឹងបង្កើតឲ្យមានជាកិច្ចសន្យាព្រមព្រៀងមិនធ្វើការប្រកួតប្រជែងគ្នា ឬបែងចែកតំបន់អាជីវកម្មជាដើម។ [46]

## ២.២ ដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ

ទាក់ទងទៅនឹងយន្តការ ដោះស្រាយវិវាទចំពោះការរំលោភសិទ្ធិរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្មនេះ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម គ្រាន់តែបានបញ្ញាតអំពីយន្តការតុលាការ តែមួយមុខគត់។ តាមយន្តការនេះ តាមរយៈនេះតុលាការអាចសម្រេចឲ្យមានយន្តការ ជាបណ្តោះអាសន្ន នៅមុនពេលរកឃើញអំពីអត្ថិភាពនៃការរំលោភសិទ្ធិ ឬជាស្ថាពរតែម្តង នៅបន្ទាប់ពីរកឃើញនូវ ការរំលោភសិទ្ធិយ៉ាងពិតប្រាកដ។

ចំពោះយន្តការបណ្តោះអាសន្ន តុលាការមានសមត្ថកិច្ចអាចនឹងចេញសេចក្តីសម្រេចបណ្តោះអាសន្ន ដើម្បីទប់ស្កាត់ការរំលោភ ឬការរំលោភដែលប្រុងនឹងកើតមានឡើងនោះបាន។ ប៉ុន្តែអ្វីដែលជាបញ្ហាចោទចំពោះខ្លឹមសារ នៃមាត្រា១២៦នេះគឺថា៖ ទី១ យន្តការបណ្តោះអាសន្នហាក់អាចធ្វើទៅបាន លុះណាតែម្ចាស់ប្រកាសនីយបត្រតក្កកម្ម បានបដិសេធក្នុងការប្តឹងប្រឆាំងការក្លែងបន្លំ បន្ទាប់ពីមានសំណើពីម្ចាស់ដែលទទួលបានសិទ្ធិ ឬអ្នកទទួលអាជ្ញាប័ណ្ណរួចហើយ។ ទី២ តាមរយៈយន្តការនេះថ្វីត្បិតតែជាយន្តការបណ្តោះអាសន្ន ប៉ុន្តែតុលាការអាចសម្រេចឲ្យមានការសងការខូចខាតដែលករណី

---

[45] មាត្រា១២៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម

[46] សារណាបញ្ចប់ការសិក្សា និស្សិត គឹម ច័ន្ទណារិទ្ធ ឆ្នាំ២០១៣ ទំព័រ៦១-៦២

នេះនឹងនាំឲ្យផ្ទុយទៅនឹងគោលការណ៍យុត្តិធម៌ក្នុងការដាក់ទោសទណ្ឌ តាមរយៈសវនការដ៏ត្រឹមត្រូវមួយមិនខាន។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយមាត្រានេះហាក់បានបើកផ្លូវឲ្យចៅក្រមអាចយកវិធានគតិយុត្តផ្សេងទៀត ក្រៅអំពីច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម មកប្រើបានចំពោះការរំលោភសិទ្ធិនេះ ដូចជាច្បាប់ស្តីពីអ្នកនិពន្ធ ក៏ដូចជាច្បាប់ស្តីពីម៉ាកជាដើម ដែលក្នុងនោះរួមមានទាំងយន្តការរដ្ឋបាល ដូចជាយន្តការតាមមាត់ច្រកព្រំដែនជាដើមផងទៀត។

ដោយឡែក ក្នុងករណីដែលការរំលោភបានកំណត់ច្បាស់ហើយ តុលាការត្រូវកំណត់ អំពីទោសទណ្ឌ ដល់បុគ្គលដែលបានប្រព្រឹត្តិអំពើរំលោភសិទ្ធិនៃប្រកាសនីយបត្រតក្កកម្មនេះអាចនឹងត្រូវផ្តន្ទាទោស ដោយពិន័យជាប្រាក់ពី**ប្រាំលាន(៥.០០០.០០០)រៀ ដល់ម្ភៃលាន( ២០.០០០.០០០)រៀល ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពីមួយ(១)ឆ្នាំ ទៅ ប្រាំ(៥) ឆ្នាំ ឬត្រូវផ្តន្ទាទោសទាំងពីរខាង លើម្តង។ កាលបើមានករណីមិនរាងចាលក្នុងរយៈពេលប្រាំឆ្នាំ គិតចាប់ពីត្រូវបានផ្តន្ទាទោសនោះមក នឹងត្រូវផ្តន្ទាទោសទ្វេដង( ទុកជាស្ថានទម្ងន់ទោស)។**

លើសពីនេះទៅទៀត តុលាការអាចសម្រេចបញ្ជាឲ្យធ្វើការរឹបអូសទុកជាទ្រព្យសម្បត្តិរដ្ឋ ឬឲ្យបំផ្លាញចោលនូវទំនិញដែលរំលោភ និងសម្ភារឧបករណ៍ដែលយកមកប្រើប្រាស់ ក្នុងការប្រព្រឹត្តិអំពើរំលោភទៀតផង។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

យោងទៅតាមការបកស្រាយខាងលើ យើងអាចធ្វើសេចក្ដីសន្និដ្ឋានបាន ថាប្រកាសនីយបត្រតក្កកម្មគឺជាផ្នែកមួយនៃកម្មសិទ្ធបញ្ញា។ ប្រកាសនីយបត្រតក្កកម្ម គឺជាទម្រង់មួយដែល ចាស់ជាងគេបំផុតនៃកិច្ចការពារកម្មសិទ្ធបញ្ញា គោលបំណងរបស់វាគឺដើម្បីលើកទឹកចិត្តការ អភិវឌ្ឍន៍សេដ្ឋកិច្ចជម្រុញការបង្កើតថ្មី តាមរយៈកម្មសិទ្ធិបញ្ញា។

ច្បាប់ស្ដីពីប្រកាសនីយបត្រតក្កកម្មបានគ្របដណ្ដប់ទាំងការបង្កើតថ្មី និងការអភិវឌ្ឍន៍ដូចជាតក្កកម្មនៃថ្នាំប៉ៃលីសាលីន សំខាន់ត្រូវការពារម៉ាស៊ីនតក្កកម្មដើម្បីឲ្យម៉ាស៊ីនផលិតកាន់តែឆាប់។ ជាទូរទៅការការពារតក្កកម្មជាដំណោះស្រាយមួយលើបញ្ហាបច្ចេកទេស ។ ដំណោះស្រាយ នេះគឺជាគំនិត និងការការពារដែលស្ថិតនៅក្រោមច្បាប់ប្រកាសនីយបត្រតក្កកម្ម តែមិនតម្រូវឲ្យបង្ហាញ តក្កកម្មនោះទេ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏មានវត្ថុខ្លះមិនអាចក្លាយជា ប្រកាសនីយបត្រតក្ក កម្មបានទេ ដោយវត្ថុទាំងនោះរួមមាន វត្ថុនៃរបកគំឃើញក្នុងធម្មជាតិ ម៉ាស៊ីនដែលប្រឆាំងទៅនឹង ច្បាប់ធម្មជាតិ ក្រៅពីនោះ មានចែងនៅក្នុងច្បាប់ដូចជាទ្រឹស្ដីវិទ្យាសាស្ត្រ និងទ្រឹស្ដីគណិតវិទ្យា រូបមន្ត វិធីសាស្ត្រធ្វើពាណិជ្ជកម្ម វិធីសាស្ត្រសម្រាប់ព្យាបាលមនុស្ស ឬសត្វ។

តាមរយៈកិច្ចព្រមព្រៀងអន្តរជាតិ រាល់តក្កកម្មអាចជាប្រកាសនីយបត្រតក្កកម្ម ទាំងដំណើរការផលិត ទាំងផលិតផលនៅគ្រប់ផ្នែកបច្ចេកវិទ្យា។ ជាទូទៅប្រកាសនីយបត្រតក្កកម្ម អ្នក ស្នើសុំត្រូវតែបំពេញទៅតាមល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងច្បាប់ស្ដីពីប្រកាសនីយបត្រតក្កកម្ម ហើយការិយាល័យប្រកាសនីយបត្រ ត្រូវធ្វើការត្រួតពិនិត្យ នូវសំណុំបែបបទ ដើម្បីកំណត់ វិនិច្ឆ័យថាតើពាក្យស្នើសុំនោះ គ្រប់គ្រាន់ទៅតាមល័ក្ខខ័ណ្ឌហើយឬនៅមុននឹងសម្រេចផ្ដល់។ ក៏ប៉ុន្តែក្នុងករណីអ្នកស្នើសុំមិនបានបំពេញនូវរាល់ល័ក្ខខ័ណ្ឌដែលបានកំណត់ដោយច្បាប់នោះបាន ន័យថាអ្នកស្នើសុំនឹងមិនទទួលបាននូវប្រកាសនីយបត្រតក្កកម្មទេ។

ក្នុងករណីប្រសិនបើតក្កករបានរកឃើញរបបគំហើញថ្មីណាមួយ ដោយមិនធ្វើការចុះបញ្ជីនៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មទេ នោះម្ចាស់នៃរបបគំហើញនឹងប្រឈមទៅនឹងការបាត់បង់តាមរយៈតតីយជនណាម្នាក់យករបបគំហើញនោះទៅធ្វើការស្នើសុំមុន នោះគឺបានន័យថាតតីតជននឹងទទួលបានសិទ្ធិជាម្ចាស់ស្រប់ច្បាប់ និងទទួលបានការការពារពីច្បាប់ស្ដីពីប្រកាសនីយបត្រតក្កកម្មដែលសភាបានអនុមត័ និងប្រកាសឲ្យប្រើនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣។ ទោះជាយ៉ាងណាក៏ដោយការទទួលស្គាល់ប្រកាសនីយបត្រតក្កកម្ម របស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម គឺមានវិសាលភាពការពារលើតក្កកម្មតែក្នុងតែរង្វង់នៃប្រទេសកម្ពុជាតែប៉ុណ្ណោះ ប្រសិនបើតក្កករមានបំណងចង់ឲ្យតក្កកម្មរបស់ខ្លួនទទួលបានការការពារនៅឯបរទេស នោះតក្កករត្រូវទៅធ្វើការស្នើសុំប្រកាសនីយបត្រតក្កកម្មនៅបរទេស។

នៅពេលមានវិវាទកើតឡើងទាក់ទងទៅនឹងប្រកាសនីយបត្រតក្កកម្ម ម្ចាស់ប្រកាសនីយបត្រតក្កកម្ម(តក្កករ) អាចសម្រេចជ្រើសរើសយកវិធីណាមួយក្នុងចំណោមវិធីពីរយ៉ាងគឺ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលជានីតិវិធីមួយសម្រាប់ភាគីទាំងពីរធ្វើការចរចារ ក៏ដូចសម្របសម្រួលដើម្បីឈានទៅរកដំណោះស្រាយ និងបង្កើតបានជាកិច្ចព្រមព្រៀងមួយ ប៉ុន្តែប្រសិនបើនៅ តែពុំមានដំណោះស្រាយនោះទេ ភាគីទាំងពីរអាចជ្រើសរើសយកមធ្យោបាយម្យ៉ាងទៀត គឺការដោះស្រាយតាមប្រព័ន្ធតុលាការ មធ្យោបាយនេះជាមធ្យោបាយចុងក្រោយ ដើម្បីឈានទៅ ដល់ការបញ្ចប់វិវាទ។

# គន្ថនិទ្ទេស

# ឯកសារយោង

**១.អត្ថបទច្បាប់៖**

១.១ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣

១.២ អនុសញ្ញាទីក្រុងប៉ារីស ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨៣ ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម

១.៣ ប្រកាសលេខ៤៥១ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម

១.៤ ប្រកាសលេខ៧០៦ ឧរថ.កសឧ.ប្រក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

**២.សៀវភៅ៖**

២.១ "នីតិកម្មសិទ្ធិបញ្ញា" សាស្ត្រាចារ្យ ទេព សុខ ឆ្នាំ២០១៨

២.២ "នីតិកម្មសិទ្ធិបញ្ញា" សាស្ត្រាចារ្យ ឥន យឿន និង អ៊ុក វណ្ណារ័ត្ន បោះពុម្ពលើកទី១ ឆ្នាំ២០១៣

២.៣ "នីតិកម្មសិទ្ធិបញ្ញា" សាស្ត្រាចារ្យ កាន់ សុទ្ធប៉ូលីន បោះពុម្ពលើកទី១

**៣.គេហទំព័រ៖**

http://www.mih.gov.kh/Events.aspx?DepartmentId=10

# ឧបសម្ព័ន្ធ១

# ច្បាប់ស្តីពីប្រកាសនីយបត្រ តក្ក
# កម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថ
# ប្រយោជន៍

# ឧបសម្ព័ន្ធ២

# ពាក្យស្នើសុំប្រកាសនីយបត្រតក្ក

# កម្ពុជា

# ឧបសម្ព័ន្ធ៣

# តារាងតម្លៃការពារ

# ឧបសម្ព័ន្ធ៤

# តារាងស្ថិតិស្នើសុំ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# ច្បាប់

# ស្ដីពី

# ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅការពារតក្កកម្មដែលបានទទួលប្រកាសនីយបត្រ-តក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ដែលបានទទួលវិញ្ញាបនបត្រ និងការពារគំនូរឧស្សាហកម្ម ដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់នេះ និងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ។

**មាត្រា ២.-**

ច្បាប់នេះមានគោលបំណង :

១-លើកទឹកចិត្តចំពោះការច្នៃប្រឌិតថ្មី និងចំពោះការស្រាវជ្រាវ និងការអភិវឌ្ឍន៍វិទ្យាសាស្ត្រនិងបច្ចេកវិជ្ជា

២-ជំរុញនិងលើកទឹកចិត្តការធ្វើពាណិជ្ជកម្ម ក្នុងនិងក្រៅប្រទេសនិងការវិនិយោគ

៣-លើកទឹកចិត្តចំពោះការផ្ទេរបច្ចេកវិជ្ជាមកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជួយសម្រួលសកម្មភាពឧស្សាហកម្មនិងការអភិវឌ្ឍន៍សេដ្ឋកិច្ច

៤-ផ្តល់ការការពារចំពោះសិទ្ធិនៃកម្មសិទ្ធិឧស្សាហកម្ម និងប្រឆាំងចំពោះការរំលោភសិទ្ធិខាងលើ ក៏ដូចជាប្រឆាំងនឹងការធ្វើជំនួញមិនស្របច្បាប់ ។

# ជំពូកទី ២
## ប្រកាសនីយបត្រតក្កកម្ម
### ផ្នែកទី ១
### តក្កកម្មដែលអាចផ្តល់ប្រកាសនីយបត្រតក្កកម្មបាន

**មាត្រា ៣.-**

ប្រកាសនីយបត្រតក្កកម្ម ក្នុងន័យនៃច្បាប់នេះ គឺជាវិញ្ញាបនបត្រដែលបានផ្តល់ដើម្បីការពារតក្កកម្ម ។

តក្កកម្មក្នុងន័យនៃច្បាប់នេះ គឺជាគំនិតរបស់តក្កករដែលអាចយកទៅអនុវត្តបាន នៅក្នុងដំណោះស្រាយបញ្ហាជាក់លាក់ណាមួយក្នុងវិស័យបច្ចេកវិជ្ជា ។

តក្កកម្មអាចជាការរកឃើញផលិតផល ឬដំណើរការផលិតកម្ម ឬអាចជាការរកឃើញអ្វីមួយ ដែលទាក់ទងទៅនឹងផលិតផល ឬដំណើរការផលិតកម្ម ។

**មាត្រា ៤.-**

តក្កកម្មខាងក្រោមនេះ មិនត្រូវការពារដោយប្រកាសនីយបត្រតក្កកម្មនៃច្បាប់នេះទេ :

១-ការរកឃើញ ទ្រឹស្តីវិទ្យាសាស្ត្រ និងវិធីសាស្ត្រគណិតវិទ្យា

២-គម្រោងការ ក្បួន ឬវិធីសាស្ត្រសម្រាប់ធ្វើជំនួញ សម្រាប់ធ្វើសកម្មភាពហ្វឹកហ្វឺនខាងប្រាជ្ញាសុទ្ធសាធ ឬសម្រាប់លេងល្បែងកំសាន្ត

៣-វិធីសាស្ត្រសម្រាប់ព្យាបាលរាងកាយមនុស្សឬសត្វ ដោយការវះកាត់ ឬដោយការព្យាបាល ក៏ដូចជាវិធីសាស្ត្រវិនិច្ឆ័យរោគដែលបានអនុវត្តលើរាងកាយមនុស្ស ឬសត្វ ។ បទប្បញ្ញត្តិនេះមិនយកមកអនុវត្តចំពោះផលិតផលទាំងឡាយដែលយកមកប្រើប្រាស់ក្នុងវិធីសាស្ត្រខាងលើនេះទេ

៤-ផលិតផលឱសថដូចមានចែងក្នុងមាត្រា ១៣៦ នៃច្បាប់នេះ

៥-រុក្ខជាតិ ឬសត្វដែលមិនមែនជាមីក្រូសរីរាង្គ និងដំណើរការកកើតតាមលក្ខណៈជីវសាស្ត្រសំខាន់ៗ សម្រាប់ផលិតកម្មរុក្ខជាតិឬសត្វ

៦-ប្រភេទផ្សេងៗនៃពូជរុក្ខជាតិណាមួយ ។

**មាត្រា ៥.-**

តក្កកម្មដែលអាចទទួលប្រកាសនីយបត្រតក្កកម្មបាន លុះត្រាតែតក្កកម្មនោះ :

១-ថ្មី

២-មានជំហានរកឃើញថ្មី និង

៣-អាចយកទៅអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្ម ។

**មាត្រា ៦.-**

តក្កកម្មដែលអាចចាត់ទុកថាថ្មីបាន លុះត្រាតែតក្កកម្មនោះពុំទាន់មានអ្នកណាបានរកឃើញពីមុន ។

ការរកឃើញពីមុន គឺតក្កកម្មដែលសាធារណជន នៅកន្លែងណាមួយនៅលើពិភពលោកបានដឹងមុនកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ឬកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំនោះ តាមរយៈការផ្សព្វផ្សាយ ដោយប្រើរូបភាពជាក់ស្តែង ឬដោយផ្ទាល់មាត់ តាមរយៈការប្រើប្រាស់តក្កកម្មនោះ ឬតាមរយៈមធ្យោបាយផ្សព្វផ្សាយផ្សេងៗទៀត ។

ក្នុងន័យនៃវាក្យខណ្ឌទី ២ នៃមាត្រានេះ មិនត្រូវចាត់ទុកថាជាការដឹងដល់សាធារណជន ចំពោះករណីដូចខាងក្រោម :

ក- ការដឹងដល់សាធារណជននូវតក្កកម្ម ដែលបានកើតឡើងក្នុងអំឡុងពេលដប់ពីរ(១២)ខែ មុនកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ឬកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំនោះ ។

ខ- ការធ្វើឱ្យលេចឮខ្ចរខ្ចាយពត៌មានស្តីអំពីតក្កកម្ម តាមរយៈអ្នកដាក់ពាក្យសុំ តាមរយៈអ្នកស្នងរបស់បុព្វជន ឬតាមរយៈការរំលោភរបស់ភាគីទីបីទៅលើអ្នកដាក់ពាក្យសុំ ឬអ្នកស្នងរបស់បុព្វជន ដែលបណ្តាលឱ្យលេចឮខ្ចរខ្ចាយពត៌មាននេះ ។

**មាត្រា ៧.-**

ដោយពិនិត្យទៅលើការរកឃើញពីមុន ផ្អែកតាមសំណុំលិខិតស្នើសុំដែលអះអាងអំពីតក្កកម្មនោះ និងដូចដែលបានចែងនៅក្នុងវាក្យខណ្ឌទី ២ នៃមាត្រា ៦ នៃច្បាប់នេះ តក្កកម្ម ត្រូវចាត់ទុកថាមានជំហានរកឃើញថ្មី ប្រសិនបើតក្កកម្មនោះមិនអាចឱ្យបុគ្គលណាដែលមានកម្រិតធម្មតាក្នុងជំនាញយល់ដឹងបាន ។

**មាត្រា ៨.-**

តក្កកម្មមួយត្រូវចាត់ទុកថាអាចអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្ម ប្រសិន

បើតក្កកម្មនោះអាចត្រូវផលិត ឬត្រូវប្រើប្រាស់នៅក្នុងប្រភេទណាមួយនៃឧស្សាហកម្មបាន ។

**មាត្រា ៩.-**

តក្កកម្មណាដែលការធ្វើអាជីវកម្មពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា

- ផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ ឬសីលធម៌
- មិនការពារជីវិត ឬសុខភាពរបស់មនុស្ស សត្វ ឬរុក្ខជាតិ
- ធ្វើឱ្យខូចបរិស្ថានធ្ងន់ធ្ងរ ឬ
- ត្រូវបានច្បាប់ហាមឃាត់មិនត្រូវផ្ដល់ប្រកាសនីយបត្រតក្កកម្មឱ្យទេ។

## ផ្នែកទី ២
## សិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម
## និងការដាក់ឈ្មោះតក្កករ

**មាត្រា ១០.-**

សិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម គឺជាកម្មសិទ្ធិរបស់តក្កករ ។

**មាត្រា ១១.-**

ប្រសិនបើមានបុគ្គលពីរនាក់ ឬច្រើននាក់រួមគ្នាបង្កើតបានតក្កកម្មមួយ សិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្មនេះ ត្រូវតែជាកម្មសិទ្ធិរួមគ្នានៃបុគ្គលទាំងឡាយនោះ ។

**មាត្រា ១២.-**

ប្រសិនបើមានបុគ្គលពីរនាក់ឬច្រើននាក់ បានរកឃើញដោយឡែកៗ ពីគ្នានូវតក្កកម្មមួយដូចគ្នា បុគ្គលណាបានដាក់សំណុំលិខិតស្នើសុំដែលមានកាលបរិច្ឆេទសុំចុះបញ្ជីមុនគេបង្អស់ ឬមានកាលបរិច្ឆេទអាទិភាពមុនគេបង្អស់ ហើយបានប្រកាស

សុពលភាពនៃកាលបរិច្ឆេទអាទិភាពនោះ ត្រូវទទួលសិទ្ធិជាម្ចាស់ប្រកាសនីយបត្រតក្កកម្ម ប្រសិនបើសំណុំលិខិតស្នើសុំខាងលើមិនត្រូវដកយកទៅវិញ ឬបោះបង់ចោល ឬក៏ត្រូវបដិសេធ ។

**មាត្រា ១៣.-**

សិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្ម អាចប្រគល់ឬផ្ទេរទៅឱ្យបុគ្គលដទៃដើម្បីស្នងជំនួសបាន ។

**មាត្រា ១៤.-**

តក្កកម្មមួយដែលធ្វើឡើងនៅក្នុងការប្រតិបត្តិទៅតាមកិច្ចសន្យាជួលធ្វើការងារ សិទ្ធិជាម្ចាស់នៃប្រកាសនីយបត្រតក្កកម្មត្រូវតែជាកម្មសិទ្ធិរបស់និយោជក ប្រសិនបើនៅក្នុងកិច្ចសន្យានោះ ពុំមានប្រការអ្វីចែងផ្ទុយអំពីនេះ ។

**មាត្រា ១៥.-**

តក្ករត្រូវតែដាក់ឈ្មោះរបស់ខ្លួននៅក្នុងប្រកាសនីយបត្រតក្កកម្ម លើកលែងតែតក្ករនោះបានចុះហត្ថលេខាលើសេចក្តីប្រកាសជាលាយលក្ខអក្សរពិសេសមួយផ្ញើជូនមន្ត្រីកាន់កាប់បញ្ជីដោយបញ្ជាក់ថា ខ្លួនពុំមានបំណងឱ្យដាក់ឈ្មោះរបស់ខ្លួនឡើយ ទើបនៅលើប្រកាសនីយបត្រតក្កកម្មនោះមិនត្រូវដាក់ឈ្មោះតក្ករ ។ ការសន្យា ឬការទទួលរ៉ាប់រងណាមួយរបស់តក្ករដោយផ្ទាល់មាត់ធ្វើឡើងចំពោះបុគ្គលណាម្នាក់ ដែលថាខ្លួននឹងធ្វើតាមសេចក្តីប្រកាសខាងលើ នឹងពុំមានប្រសិទ្ធភាពស្របច្បាប់ឡើយ ។

## ផ្នែកទី ៣
## សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម

**មាត្រា ១៦.-**

សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មត្រូវដាក់ជូនទៅក្រសួងទទួលបន្ទុកឧស្សាហកម្មដែលក្នុងនោះត្រូវរួមមាន ពាក្យសុំសេចក្តីអធិប្បាយអំពីតក្កកម្ម សេចក្តី

អះអាង គំនូសបង្ហាញប្រសិនបើចាំបាច់និងខ្លឹមសារសង្ខេប ។ ការដាក់សំណុំលិខិតស្នើសុំត្រូវតែមានការបង់កម្រៃតាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។

**មាត្រា ១៧.-**

ពាក្យសុំត្រូវមានបញ្ជាក់អំពីអ្វីដែលអាចឈានទៅដល់ការផ្តល់ប្រកាស-នីយបត្រតក្កកម្មបាន ដូចជានាម និងទិន្នន័យផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងអ្នកដាក់ពាក្យសុំតក្កករ និងភ្នាក់ងារតំណាងប្រសិនបើមាន និងចំណងជើងនៃតក្កកម្មនោះ ។

ក្នុងករណីអ្នកដាក់ពាក្យសុំមិនមែនជាតក្កករទេនោះ ពាក្យសុំត្រូវតែភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់អំពីសិទ្ធិរបស់អ្នកដាក់ពាក្យសុំ ចំពោះប្រកាសនីយបត្រ-តក្កកម្មនោះ ។

**មាត្រា ១៨.-**

សេចក្តីអធិប្បាយត្រូវលើកបង្ហាញអំពីតក្កកម្មក្នុងលក្ខណៈច្បាស់លាស់និងពេញលេញ ដើម្បីឱ្យបុគ្គលដែលមានកម្រិតជំនាញធម្មតាក្នុងជំនាញអាចអនុវត្តបាននូវតក្កកម្មនោះ ។ ដោយឡែកសេចក្តីអធិប្បាយនោះ ត្រូវចង្អុលបង្ហាញឱ្យដឹងនូវវិធីដែលល្អជាងគេ ដើម្បីអនុវត្តតាមបាននូវតក្កកម្មខាងលើ នៅពេលចុះកាលបរិច្ឆេទសុំចុះបញ្ជី ឬនៅពេលចុះកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំក្នុងករណីអាទិភាពត្រូវបានអះអាង ។

**មាត្រា ១៩.-**

សេចក្តីអះអាងត្រូវតែកំណត់ឱ្យបានច្បាស់លាស់ អំពីចំណុចដែលសុំឱ្យមានការការពារ ។ សេចក្តីអធិប្បាយនិងគំនូសបង្ហាញអាចត្រូវយកទៅប្រើប្រាស់បានសម្រាប់ធ្វើការបកស្រាយសេចក្តីអះអាងនោះ ។

សេចក្តីអះអាងត្រូវតែច្បាស់លាស់ និងសង្ខេប ។ សេចក្តីអះអាងនោះត្រូវតែផ្អែកទាំងស្រុងលើសេចក្តីអធិប្បាយ ។

**មាត្រា ២០.-**

គំនូសបង្ហាញចាំបាច់ត្រូវតែមាន ដើម្បីយកមកបកស្រាយពន្យល់អំពីតក្កកម្មនោះ ។

**មាត្រា ២១.-**

ខ្លឹមសារសង្ខេបត្រូវបកស្រាយត្រឹមតែគោលបំណងនៃពត៌មានបច្ចេកទេស ប៉ុណ្ណោះ មិនត្រូវបកស្រាយអំពីវិសាលភាពនៃការការពារឡើយ ។

**មាត្រា ២២.-**

អ្នកដាក់ពាក្យសុំអាចដកសំណុំលិខិតស្នើសុំទៅវិញនៅពេលណាក៏បាន ក្នុងករណីដែលសំណុំលិខិតស្នើសុំនោះស្ថិតក្នុងរយៈពេលព្យួរទុកសម្រាប់ពិនិត្យ ដើម្បីផ្តល់ប្រកាសនីយបត្រតក្កកម្ម ។

## ផ្នែកទី ៤
## ការរួមបញ្ចូលតែមួយនៃតក្កកម្ម
## ការកែតម្រូវនិងការបំបែកសំណុំលិខិតស្នើសុំ

**មាត្រា ២៣.-**

សំណុំលិខិតស្នើសុំត្រូវពាក់ព័ន្ធទៅនឹងតក្កកម្មតែមួយគត់ ឬតក្កកម្មមួយក្រុមដែលទាក់ទងគ្នាបង្កើតបានជាទស្សនៈរួមមួយនៃតក្កកម្មនោះ ។

**មាត្រា ២៤.-**

មុនពេលផ្តល់ប្រកាសនីយបត្រតក្កកម្ម អ្នកដាក់ពាក្យសុំអាចកែតម្រូវសំណុំលិខិតស្នើសុំរបស់ខ្លួនបាន ប៉ុន្តែការកែតម្រូវនោះមិនត្រូវបន្ថែមអ្វីឱ្យលើសពីខ្លឹមសារដែលបានបញ្ជាក់នៅក្នុងសំណុំលិខិតស្នើសុំពីដំបូងឡើយ ។

**មាត្រា ២៥.-**

មុនពេលផ្តល់ប្រកាសនីយបត្រតក្កកម្ម អ្នកដាក់ពាក្យសុំ អាចសុំបំបែកសំណុំ

លិខិតស្នើសុំជាពីរ ឬច្រើនបានដែលហៅថាសំណុំលិខិតស្នើសុំបំបែក ។ ប៉ុន្តែសំណុំលិខិតស្នើសុំបំបែកនោះ មិនត្រូវបន្ថែមអ្វីឱ្យលើសពីខ្លឹមសារ ដែលបានបញ្ជាក់នៅក្នុងសំណុំលិខិតស្នើសុំពីដំបូងឡើយ ។

សំណុំលិខិតស្នើសុំបំបែកនីមួយៗ ត្រូវទទួលបានកាលបរិច្ឆេទសុំចុះបញ្ជី និងកាលបរិច្ឆេទអាទិភាព ដូចសំណុំលិខិតស្នើសុំពីដំបូងដែរ ។

**មាត្រា ២៦.-**

ក្នុងករណីដែលប្រកាសនីយបត្រតក្កកម្មមួយ ត្រូវផ្តល់រួចហើយទៅតាមសំណុំលិខិតស្នើសុំដែលមិនបានបំពេញតាមល័ក្ខខ័ណ្ឌតម្រូវនៃការរួមបញ្ចូលតែមួយនៃតក្កកម្មដូចបានចែងនៅក្នុងមាត្រា ២៣ នៃច្បាប់នេះ មិនត្រូវចាត់ទុកជាមូលហេតុនៃអសុពលភាពរបស់ប្រកាសនីយបត្រតក្កកម្មនោះបានឡើយ ។

## ផ្នែកទី ៥
## សិទ្ធិអាទិភាព

**មាត្រា ២៧.-**

យោងតាមអនុសញ្ញាទីក្រុងប៉ារីស សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មអាចអមដោយសេចក្តីប្រកាសមួយដែលអះអាងអំពីអាទិភាពនៃសំណុំលិខិតស្នើសុំដែលបានសុំចុះបញ្ជីមុនគេដោយអ្នកដាក់ពាក្យសុំ ឬដោយអ្នកស្នងជំនួសឱ្យបុព្វជនរបស់គេនៅក្នុងប្រទេសមួយ ឬច្រើននៅក្នុងតំបន់ ឬនៅអន្តរជាតិ ដែលប្រទេសទាំងនោះជាសមាជិកអនុសញ្ញាខាងលើ ឬដែលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ។

**មាត្រា ២៨.-**

ក្នុងករណីដែលសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មមានអមដោយសេចក្តីប្រកាស ដូចមានចែងនៅក្នុងមាត្រា ២៧ នៃច្បាប់នេះ អ្នកដាក់ពាក្យសុំត្រូវផ្តល់ដល់មន្ត្រីកាន់កាប់បញ្ជីតាមពេលវេលាកំណត់នូវឯកសារចម្លងនៃសំណុំលិខិតស្នើ

ស៊ុំដែលបានដាក់មុនគេ និងត្រូវមានការបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម ដោយការិយាល័យដែលបានទទួលសំណុំលិខិតស្នើសុំនោះ ។

មាត្រា ២៩.-

អានុភាពនៃសេចក្តីប្រកាសខាងលើ ដូចមានចែងនៅក្នុងមាត្រា ២៧ នៃច្បាប់នេះ ត្រូវបានកំណត់នៅក្នុងអនុសញ្ញាទីក្រុងប៉ារីស ។

ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា ល័ក្ខខ័ណ្ឌតម្រូវនៅក្រោមផ្នែកទី ៥ នៃជំពូកទី ២ នៃច្បាប់នេះ និងបទបញ្ជាទាំងឡាយដែលពាក់ព័ន្ធនឹងផ្នែកនេះមិនបានបំពេញត្រឹមត្រូវទេនោះ សេចក្តីប្រកាសអមខាងលើត្រូវចាត់ទុកថាមិនបានធ្វើឡើយ ។

## ផ្នែកទី ៦
## ពត៌មានស្តីអំពីសំណុំលិខិតស្នើសុំនៅឯបរទេស និងប្រកាសនីយបត្រតក្កកម្មបរទេស

មាត្រា ៣០.-

នៅពេលមានសំណើពីមន្ត្រីកាន់កាប់បញ្ជី អ្នកដាក់ពាក្យសុំត្រូវតែផ្តល់ជូនមន្ត្រីកាន់កាប់បញ្ជីនូវកាលបរិច្ឆេទនិងលេខនៃសំណុំលិខិតស្នើសុំទាំងឡាយដែលខ្លួនបានដាក់នៅឯបរទេស ដែលមានការពាក់ព័ន្ធទៅនឹងតក្កកម្មដូចគ្នា ឬស្ទើរតែដូចគ្នាដូចបានអះអាងនៅក្នុងសំណុំលិខិតស្នើសុំដែលបានដាក់នៅក្រសួងទទួលបន្ទុកឧស្សាហកម្ម ។

មាត្រា ៣១.-

យោងតាមមាត្រា ៣០ នៃច្បាប់នេះ នៅពេលមានសំណើពីមន្ត្រីកាន់កាប់បញ្ជី អ្នកដាក់ពាក្យសុំត្រូវតែផ្តល់ជូនមន្ត្រីកាន់កាប់បញ្ជី នូវឯកសារដែលពាក់ព័ន្ធទៅនឹងសំណុំលិខិតស្នើសុំនៅឯបរទេស ដែលបានដាក់នៅប្រទេសណាមួយ ឬច្រើនដូចខាងក្រោម ៖

ក- ឯកសារចម្លងនៃលិខិតឆ្លងឆ្លើយ ដែលពាក់ព័ន្ធទៅនឹងលទ្ធផលនៃការស្រាវជ្រាវ ឬលទ្ធផលនៃការពិនិត្យសំណុំលិខិតស្នើសុំនៅឯបរទេស ដែលអ្នកដាក់ពាក្យសុំបានទទួល ។

ខ- ឯកសារចម្លងនៃប្រកាសនីយបត្រតក្កកម្ម ដែលបរទេសបានផ្ដល់ជូនតាមការដាក់សំណុំលិខិតស្នើសុំនៅឯបរទេស ។

គ- ឯកសារចម្លងនៃសេចក្ដីសម្រេចចុងក្រោយដែលបដិសេធ មិនទទួលសំណុំលិខិតស្នើសុំនៅឯបរទេស ឬបដិសេធមិនផ្ដល់ជូននូវប្រកាសនីយបត្រ-តក្កកម្ម តាមសំណើនៃសំណុំលិខិតស្នើសុំនោះ ។

យោងតាមវាក្យខណ្ឌទី ១ នៃមាត្រានេះ នៅពេលមានសំណើពីមន្ត្រីកាន់កាប់បញ្ជី អ្នកដាក់ពាក្យសុំត្រូវផ្ដល់នូវឯកសារចម្លងនៃសេចក្ដីសម្រេចចុងក្រោយស្ដីអំពីអសុពលភាពនៃប្រកាសនីយបត្រតក្កកម្មដែលបានផ្ដល់ជូន ផ្អែកតាមការដាក់សំណុំលិខិតស្នើសុំនៅឯបរទេស ។

**មាត្រា ៣២.-**

ក្នុងករណីនាយកដ្ឋានទទួលបន្ទុកចុះបញ្ជីដែលបានបង្កើតឡើងតាមមាត្រា ១១៧ នៃច្បាប់នេះ អនុវត្តតួនាទីជាការិយាល័យជ្រើសតាំង ដូចមានចែងក្នុងមាត្រា ៨៣ នៃច្បាប់នេះ ចំណុច ក និងចំណុច គ របស់វាក្យខណ្ឌទី ១ នៃមាត្រា ៣១ នៃច្បាប់នេះ មិនត្រូវយកមកអនុវត្តទេ អំពីពត៌មានទាក់ទងទៅនឹងការពិនិត្យរបស់ការិយាល័យជ្រើសតាំងផ្សេងៗទៀត លើសំណុំលិខិតស្នើសុំអន្តរជាតិដែលនោះ ។

## ផ្នែកទី ៧
## កាលបរិច្ឆេទនៃការសុំចុះបញ្ជី និងការពិនិត្យ

**មាត្រា ៣៣.-**

មន្ត្រីកាន់កាប់បញ្ជី ត្រូវទទួលស្គាល់កាលបរិច្ឆេទនៃការទទួលសំណុំលិខិតស្នើសុំថាជាកាលបរិច្ឆេទនៃការសុំចុះបញ្ជីសំណុំលិខិតស្នើសុំបាន លុះត្រាតែនៅពេល

ដែលទទួលនោះ សំណុំលិខិតមានអមដោយឯកសារត្រឹមត្រូវដូចខាងក្រោម ៖

១-ការបញ្ជាក់យ៉ាងច្បាស់លាស់ ឬគ្រប់គ្រាន់ អំពីបំណងនៃការសុំផ្តល់ប្រកាសនីយបត្រតក្កកម្ម

២-ការបញ្ជាក់អំពីអត្តសញ្ញាណនៃអ្នកស្នើសុំ

៣-ផ្នែកមួយនៃសំណុំលិខិតស្នើសុំ ដែលនៅលើផ្នែកនោះ មានបញ្ជាក់នូវសេចក្តីអធិប្បាយរបស់តក្កកម្ម ។

នៅពេលបានទទួលសំណុំលិខិតស្នើសុំ ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាសំណុំលិខិតស្នើសុំនោះមិនបានបំពេញត្រឹមត្រូវទៅតាមល័ក្ខខ័ណ្ឌតម្រូវរបស់វាក្យខណ្ឌទី ១ នៃមាត្រានេះទេ មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើឱ្យអ្នកដាក់ពាក្យសុំធ្វើការកែតម្រូវទៅតាមល័ក្ខខ័ណ្ឌតម្រូវនោះ និងកត់ត្រាកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំទៅតាមកាលបរិច្ឆេទដែលបានទទួលការកែតម្រូវ ។ ប៉ុន្តែប្រសិនបើសំណុំលិខិតស្នើសុំមិនបានកែតម្រូវទៅតាមការណែនាំទេ សំណុំលិខិតស្នើសុំនោះ ត្រូវបានចាត់ទុកថាដូចជាមិនបានសុំចុះបញ្ជីឡើយ ។

**មាត្រា ៣៤.-**

ក្នុងករណីដែលសំណុំលិខិតស្នើសុំបានយោងទៅគំនូសបង្ហាញ ហើយអ្នកដាក់ពាក្យសុំមិនបានភ្ជាប់មកជាមួយទេ មន្ត្រីកាន់កាប់បញ្ជីត្រូវឱ្យអ្នកដាក់ពាក្យសុំផ្តល់នូវគំនូសបង្ហាញដែលមិនបានភ្ជាប់មកជាមួយនោះ ។ ប្រសិនបើអ្នកដាក់ពាក្យសុំបានអនុវត្តតាមការណែនាំរួចហើយ មន្ត្រីកាន់កាប់បញ្ជីត្រូវកត់ត្រាកាលបរិច្ឆេទនៃការសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ទៅតាមកាលបរិច្ឆេទទទួលគំនូសបង្ហាញដែលពីមុនមកអ្នកដាក់ពាក្យសុំមិនបានភ្ជាប់ជាមួយ ។ បើមិនដូច្នោះទេ មន្ត្រីកាន់កាប់បញ្ជីត្រូវកត់ត្រាកាលបរិច្ឆេទនៃការសុំចុះបញ្ជីសំណុំលិខិតស្នើសុំទៅតាមកាលបរិច្ឆេទទទួលសំណុំលិខិតស្នើសុំ ហើយត្រូវចាត់ទុកសំណុំលិខិតស្នើសុំនោះថាពុំមានគំនូសបង្ហាញឡើយ។

**មាត្រា ៣៥.-**

បន្ទាប់ពីបានយល់ព្រមលើកាលបរិច្ឆេទសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យមើលសំណុំលិខិតស្នើសុំនោះឱ្យបំពេញត្រឹមត្រូវទៅតាមល័ក្ខខ័ណ្ឌតម្រូវ ដែលបានចែងនៅក្នុងមាត្រា ១៦ និងមាត្រា ១៧ នៃច្បាប់នេះ និងល័ក្ខខ័ណ្ឌតម្រូវនានាដែលបានកំណត់ជាបទបញ្ញាចាំបាច់នៃច្បាប់នេះ ។ ក្នុងករណីដែលសំណុំលិខិតស្នើសុំនិងប្រកាសនីយបត្រតក្កកម្មមានទំនាក់ទំនងនឹងបរទេស មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យមើលឱ្យគ្រប់គ្រាន់បន្ថែមទៀតអំពីពត៌មាននៃល័ក្ខខ័ណ្ឌតម្រូវ ដែលមានចែងនៅក្នុងមាត្រា ៣០ មាត្រា ៣១ និងមាត្រា ៣២ នៃច្បាប់នេះ ។

**មាត្រា ៣៦.-**

ក្នុងករណីមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា សំណុំលិខិតស្នើសុំបានបំពេញតាមល័ក្ខខ័ណ្ឌតម្រូវដូចបានកំណត់ក្នុងមាត្រា ៣៥ នៃច្បាប់នេះរួចហើយ មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យបន្តទៀតនូវល័ក្ខខ័ណ្ឌតម្រូវដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ និងទី ៣ នៃមាត្រា ៣ ល័ក្ខខ័ណ្ឌតម្រូវនៅក្នុងមាត្រា ៤ ដល់មាត្រា ៩ មាត្រា ១៨ ដល់មាត្រា ២០ មាត្រា ២៣ ដល់មាត្រា ២៦ នៃច្បាប់នេះ និងបទបញ្ញាទាំងឡាយដែលពាក់ព័ន្ធនឹងច្បាប់នេះ ។

**មាត្រា ៣៧.-**

យោងតាមមាត្រា ៣៦ នៃច្បាប់នេះ មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

១-លទ្ធផលនៃរបាយការណ៍ស្រាវជ្រាវរបស់អន្តរជាតិ និងលទ្ធផលរបាយការណ៍ពិនិត្យជំហានដំបូងរបស់អន្តរជាតិ ដែលធ្វើឡើងតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មរបស់សំណុំលិខិតស្នើសុំ

២-របាយការណ៍ស្រាវជ្រាវ និងរបាយការណ៍ពិនិត្យ ដែលបានចែងនៅក្នុងចំណុច ក របស់វាក្យខណ្ឌទី ១ នៃមាត្រា ៣១ ឬសេចក្តីសម្រេចចុងក្រោយ

ដែលបានចែងនៅក្នុងចំណុច គ របស់វាក្យខណ្ឌទី ១ នៃមាត្រា ៣១ នៃច្បាប់នេះស្តីអំពីការបដិសេធផ្តល់ប្រកាសនីយបត្រតក្កកម្ម ចំពោះសំណុំលិខិតស្នើសុំនៅឯបរទេស

៣-របាយការណ៍ស្រាវជ្រាវ និងរបាយការណ៍ពិនិត្យ ដែលបានធ្វើឡើងដោយស្ថាប័នស្រាវជ្រាវនិងពិនិត្យនៅក្រៅប្រទេស តាមសំណើរបស់មន្ត្រីកាន់កាប់បញ្ជី ។

## ផ្នែកទី ៨
## ការផ្តល់ប្រកាសនីយបត្រតក្កកម្ម
## និងការផ្លាស់ប្តូរនៅក្នុងប្រកាសនីយបត្រតក្កកម្ម

**មាត្រា ៣៨.-**

ក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងមាត្រា ៣៥ និងមាត្រា ៣៦ នៃច្បាប់នេះត្រូវបំពេញរួចហើយនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវដំណើរការផ្តល់ប្រកាសនីយបត្រតក្កកម្មជូនអ្នកដាក់ពាក្យសុំ ។ បើមិនដូច្នោះទេ មន្ត្រីកាន់កាប់បញ្ជីត្រូវបដិសេធសំណុំលិខិតស្នើសុំនិងជូនដំណឹងទៅអ្នកដាក់ពាក្យសុំអំពីសេចក្តីសម្រេចនេះ ។

**មាត្រា ៣៩.-**

នៅពេលផ្តល់ប្រកាសនីយបត្រតក្កកម្ម មន្ត្រីកាន់កាប់បញ្ជីត្រូវ :

១-ចុះផ្សាយសេចក្តីបញ្ជាក់អំពីការផ្តល់ប្រកាសនីយបត្រតក្កកម្ម

២-ចេញលិខិតបញ្ជាក់អំពីការផ្តល់ប្រកាសនីយបត្រតក្កកម្មមួយច្បាប់ និងប្រកាសនីយបត្រតក្កកម្មចម្លងមួយច្បាប់ ជូនដល់អ្នកដាក់ពាក្យសុំ

៣-កត់ត្រាប្រកាសនីយបត្រតក្កកម្មនៅក្នុងបញ្ជី

៤-ច្បាប់ចម្លងនៃប្រកាសនីយបត្រតក្កកម្មត្រូវមានសម្រាប់សាធារណជនជាវតាមតម្លៃដែលបានកំណត់ ។

**មាត្រា ៤០.-**

នៅពេលមានសំណើពីម្ចាស់ប្រកាសនីយបត្រតក្កកម្ម ផ្អែកលើមូលដ្ឋាននៃប្រកាសនីយបត្រតក្កកម្មដែលបានផ្តល់ជូនរួចហើយ មន្ត្រីកាន់កាប់បញ្ជីអាចធ្វើការកែសម្រួលបាននៅក្នុងអត្ថបទឬគំនូសបង្ហាញរបស់ប្រកាសនីយបត្រតក្កកម្មនោះ ដើម្បីកំណត់ទំហំនៃការការពារដែលផ្តល់ដោយប្រកាសនីយបត្រតក្កកម្ម ឱ្យតែការកែសម្រួលនោះមិនមានឥទ្ធិពលនាំឱ្យប្រែប្រួលលើសពីខ្លឹមសារ ដូចបានចែងនៅក្នុងសំណុំលិខិតស្នើសុំពីដំបូងដែលសម្រាប់ធ្វើជាមូលដ្ឋានឈានទៅដល់ការផ្តល់ប្រកាសនីយបត្រតក្កកម្មនោះ ។

## ផ្នែកទី ៩

## សិទ្ធិដែលបានប្រគល់តាមរយៈប្រកាសនីយបត្រតក្កកម្ម

**មាត្រា ៤១.-**

ការធ្វើអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជានូវតក្កកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្មរួចហើយដោយបុគ្គលដទៃទៀត ចាំបាច់ត្រូវតែមានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្មនោះ ។

**មាត្រា ៤២.-**

ក្នុងន័យនៃច្បាប់នេះ ការធ្វើអាជីវកម្មនៃតក្កកម្មដែលបានទទួលប្រកាស-នីយបត្រតក្កកម្មរួចហើយ គឺមានន័យថា ជាសកម្មភាពណាមួយនៃសកម្មភាពទាំងឡាយខាងក្រោមនេះ :

១-ចំពោះផលិតផលមួយ ដែលបានផ្តល់ជូននូវប្រកាសនីយបត្រតក្ក-កម្មរួចហើយ ការធ្វើអាជីវកម្មគឺជា :

**ក**- ការផលិត ការនាំចូល ការផ្គត់ផ្គង់សម្រាប់ការលក់ និងការប្រើប្រាស់ផលិតផលនោះ

**ខ**- ការស្តុកទុកផលិតផលនោះ ក្នុងគោលបំណងផ្គត់ផ្គង់សម្រាប់លក់ ឬប្រើប្រាស់

២-ចំពោះដំណើរការផលិតកម្មមួយ ដែលបានផ្តល់ជូននូវប្រកាសនីយបត្រតក្កកម្មរួចហើយ ការធ្វើអាជីវកម្មគឺជា :

ក- ការប្រើប្រាស់ដំណើរការផលិតកម្មនោះ

ខ- ការធ្វើសកម្មភាពណាមួយនៃសកម្មភាពទាំងឡាយ ដូចមានចែងក្នុងចំណុច ក និងចំណុច ខ នៃចំណុចទី ១ នៃមាត្រានេះ លើផលិតផលដែលទទួលបានដោយផ្ទាល់ពីមធ្យោបាយនៃដំណើរការផលិតកម្មនោះ ។

**មាត្រា ៤៣.-**

លើកលែងតែមាត្រា ៤៤ និងមាត្រា ៤៧ ដល់មាត្រា ៥៥ នៃច្បាប់នេះ ម្ចាស់ប្រកាសនីយបត្រតក្កកម្មមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ច ចំពោះបុគ្គលណាដែលរំលោភលើប្រកាសនីយបត្រតក្កកម្មរបស់ខ្លួន តាមរយៈការអនុវត្តនូវ សកម្មភាពណាមួយ ដូចមានចែងក្នុងមាត្រា ៤២ នៃច្បាប់នេះ ដោយគ្មានការយល់ព្រមពីម្ចាស់ ឬមានសិទ្ធិប្តឹងចំពោះបុគ្គលណាដែលអនុវត្តសកម្មភាពទាំងឡាយដែលអាចនឹងបណ្តាលឱ្យមានការរំលោភដូចគ្នានេះកើតឡើង ។

**មាត្រា ៤៤.-**

សិទ្ធិដែលបានប្រគល់តាមរយៈប្រកាសនីយបត្រតក្កកម្មមិនអនុវត្តចំពោះ :

ក- សកម្មភាពពាក់ព័ន្ធនឹងសម្ភារៈ ដែលបានដាក់តាំងនៅលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ឬនៅលើទីផ្សារក្រៅព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់ប្រកាសនីយបត្រតក្កកម្ម ឬដោយមានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្ម

ខ- ការប្រើប្រាស់សម្ភារៈនៅលើអាកាសយាន យានយន្តផ្លូវគោក ឬនាវារបស់ប្រទេសដទៃ ដែលចូលចតជាបណ្តោះអាសន្ន ឬចូលចតដោយឧបទ្ទវហេតុក្នុងដែនអាកាស ដែនគោក ឬដែនទឹកនៃព្រះរាជាណាចក្រកម្ពុជា

គ- សកម្មភាពដែលធ្វើត្រឹមតែក្នុងគោលបំណងពិសោធន៍ ដែលទាក់ទងទៅនឹងតក្កកម្មដែលបានផ្តល់ប្រកាសនីយបត្រតក្កកម្មរួចហើយ

ឃ- សកម្មភាពដែលប្រព្រឹត្តក្នុងគោលបំណងល្អ ដោយបុគ្គលណាម្នាក់ ដោយប្រើប្រាស់តក្កកម្ម ឬក៏ធ្វើការរៀបចំឱ្យមានប្រសិទ្ធភាពនិងហ្មត់ចត់នូវតក្កកម្មនោះ មុនកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ឬមុនកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំ ដែលបានអះអាងក្នុងករណីដែលប្រកាសនីយបត្រតក្កកម្មបានផ្តល់រួចហើយ និងបានផ្តល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

យោងតាមចំណុច ឃ របស់វាក្យខណ្ឌទី ១ នៃមាត្រានេះ សិទ្ធិរបស់អ្នកប្រើប្រាស់មុន អាចផ្ទេរបានជាមួយតែសហគ្រាស ឬក្រុមហ៊ុន ឬមួយផ្នែកនៃសហគ្រាស ឬក្រុមហ៊ុនដែលបានប្រើប្រាស់ ឬបានរៀបចំការប្រើប្រាស់តក្កកម្ម នោះរួចហើយ ។

## ផ្នែកទី ១០
## រយៈពេលនៃការការពារ និងការបង់កម្រៃប្រចាំឆ្នាំ

### មាត្រា ៤៥.-

ប្រកាសនីយបត្រតក្កកម្ម មានសុពលភាពរយៈពេលម្ភៃ (២០)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជី នៃការស្នើសុំប្រកាសនីយបត្រតក្កកម្ម លុះត្រាតែបានបំពេញតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៤៦ នៃច្បាប់នេះ ។

### មាត្រា ៤៦.-

ការបង់កម្រៃប្រចាំឆ្នាំ ត្រូវបង់ជាមុនជូនមន្ត្រីកាន់កាប់បញ្ជីសម្រាប់រយៈពេលមួយ(១)ឆ្នាំម្តងៗ ដោយគិតចាប់ពីពេលមួយ(១)ឆ្នាំ ក្រោយកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ដើម្បីរក្សាសុពលភាពនៃប្រកាសនីយបត្រតក្កកម្ម ឬសំណុំលិខិតស្នើសុំនៃប្រកាសនីយបត្រតក្កកម្មនោះ ។ ការយឺតយ៉ាវក្នុងការបង់កម្រៃប្រចាំឆ្នាំ ត្រូវបានអនុញ្ញាតយ៉ាងយូរប្រាំមួយ(៦)ខែ ដោយមានការបង់កម្រៃបន្ថែមលើការយឺតយ៉ាវនេះ តាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។ ប្រសិនបើមិនបានបង់កម្រៃប្រចាំឆ្នាំ ទៅតាមល័ក្ខខ័ណ្ឌដែលមានចែង

នៅក្នុងមាត្រានេះ សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម នឹងត្រូវចាត់ទុកថាបានដកយកទៅវិញ ឬប្រកាសនីយបត្រតក្កកម្មត្រូវអស់សុពលភាព ។

## ផ្នែកទី ១១

## ការធ្វើអាជីវកម្មដោយរដ្ឋាភិបាល ឬដោយបុគ្គលដែលបានទទួលការអនុញ្ញាតពីរដ្ឋាភិបាល

**មាត្រា ៤៧.-**

រដ្ឋមន្ត្រីអាចសម្រេចជ្រើសរើសឱ្យអង្គភាពរដ្ឋ ឬតតិយជន ធ្វើអាជីវកម្មលើតក្កកម្មបាន ទោះជាគ្មានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្មក៏ដោយ ចំពោះករណីដូចខាងក្រោម :

១-មានសេចក្តីតម្រូវចាំបាច់ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ជាពិសេសផ្នែកសន្តិសុខជាតិ អាហារូបត្ថម្ភ សុខាភិបាល ឬដើម្បីអភិវឌ្ឍវិស័យសេដ្ឋកិច្ចជាតិសំខាន់ៗផ្សេងទៀត ឬ

២-តុលាការមានសមត្ថកិច្ចបានវិនិច្ឆ័យថា របៀបធ្វើអាជីវកម្មដោយម្ចាស់ប្រកាសនីយបត្រតក្កកម្ម ឬដោយអ្នកទទួលអាជ្ញាប័ណ្ណ មានលក្ខណៈប្រឆាំងនឹងការប្រកួតប្រជែង ។

ការធ្វើអាជីវកម្មលើតក្កកម្មនោះ ត្រូវអនុវត្តតាមវត្ថុបំណងដែលបានអនុញ្ញាត និងត្រូវបង់ប្រាក់សំណងសមស្របជូនម្ចាស់ប្រកាសនីយបត្រតក្កកម្ម ដោយគិតដល់តម្លៃសេដ្ឋកិច្ច ដូចបានកំណត់នៅក្នុងសេចក្តីអនុញ្ញាតរបស់រដ្ឋមន្ត្រី ។

រដ្ឋមន្ត្រីត្រូវធ្វើការសម្រេច បន្ទាប់ពីបានស្តាប់យោបល់របស់ម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងបុគ្គលទាំងឡាយដែលពាក់ព័ន្ធក្នុងរឿងនេះ ។

**មាត្រា ៤៨.-**

ផ្អែកតាមសំណើរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្ម របស់អង្គភាពរដ្ឋ ឬរបស់តតិយជន ដែលអនុញ្ញាតឱ្យធ្វើអាជីវកម្មលើតក្កកម្ម ដែលបានទទួលប្រកាស

នីយបត្រតក្កកម្មរួចហើយ រដ្ឋមន្ត្រីអាចធ្វើការផ្លាស់ប្ដូរល័ក្ខខ័ណ្ឌនៃសេចក្ដីសម្រេច ដែលអនុញ្ញាតឱ្យធ្វើអាជីវកម្មលើតក្កកម្មខាងលើបាន ក្នុងកម្រិតដែលការផ្លាស់ប្ដូរនោះ សមស្របតាមសភាពការណ៍ជាក់ស្ដែង បន្ទាប់ពីបានស្ដាប់យោបល់របស់ភាគីណាមួយ ឬភាគីទាំងពីរ ។

**មាត្រា ៤៩.-**

ផ្អែកតាមសំណើរបស់ម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងក្រោយពីបានស្ដាប់យោបល់របស់ភាគីណាមួយ ឬភាគីទាំងពីរ រដ្ឋមន្ត្រីអាចបញ្ចប់សេចក្ដីអនុញ្ញាតឱ្យធ្វើអាជីវកម្មនោះបាន ក្នុងករណីដែលអង្គភាពរដ្ឋ ឬតតិយជនដែលបានជ្រើសរើសដោយរដ្ឋមន្ត្រី មិនបានបំពេញល័ក្ខខ័ណ្ឌនៃសេចក្ដីសម្រេច ឬថាករណីនៃចំណុចទី ១ និងចំណុចទី ២ ដូចបានចែងក្នុងវាក្យខណ្ឌទី ១ នៃមាត្រា ៤៧ នៃច្បាប់នេះ លែងកើតមានទៀតហើយ ។

ថ្វីបើមានចែងនៅក្នុងវាក្យខណ្ឌទី ១ នៃមាត្រានេះក៏ដោយ ក៏រដ្ឋមន្ត្រីមិនត្រូវបញ្ចប់សេចក្ដីអនុញ្ញាតឱ្យធ្វើអាជីវកម្មនេះដែរ ប្រសិនបើពិនិត្យឃើញថា តម្រូវការសម្រាប់ការការពារផលប្រយោជន៍ស្របច្បាប់របស់អង្គភាពរដ្ឋ ឬតតិយជនដែលបានជ្រើសរើសដោយរដ្ឋមន្ត្រី ត្រឹមត្រូវទៅតាមខ្លឹមសារដែលមានចែងក្នុងសេចក្ដីសម្រេច ។

**មាត្រា ៥០.-**

តតិយជនដែលត្រូវជ្រើសរើសដោយរដ្ឋមន្ត្រីឱ្យធ្វើអាជីវកម្ម អាចផ្ទេរសិទ្ធិធ្វើអាជីវកម្មបានជាមួយតែសហគ្រាស ឬក្រុមហ៊ុន ឬមួយផ្នែកនៃសហគ្រាស ឬក្រុមហ៊ុនរបស់តតិយជន ដែលកំពុងធ្វើអាជីវកម្មលើតក្កកម្មនោះ ។

**មាត្រា ៥១.-**

សេចក្ដីអនុញ្ញាតឱ្យធ្វើអាជីវកម្មត្រូវមានជាចាំបាច់ :

១-ការចុះកិច្ចសន្យាអាជ្ញាប័ណ្ណ ដែលធ្វើឡើងដោយម្ចាស់ប្រកាសនីយ-បត្រតក្កកម្ម ឬការអនុវត្តន៍បន្តសិទ្ធិធ្វើអាជីវកម្ម ដោយម្ចាស់ប្រកាសនីយបត្រតក្កកម្ម

ដូចមានចែងក្នុងមាត្រា ៤២ នៃច្បាប់នេះ

២-ការចេញអាជ្ញាប័ណ្ណបញ្ញា ដូចមានចែងក្នុងផ្នែកទី ១២ នៃជំពូកទី ២ នៃច្បាប់នេះ ។

**មាត្រា ៥២.-**

សំណើសុំសេចក្ដីអនុញ្ញាតធ្វើអាជីវកម្មពីរដ្ឋមន្ត្រី ត្រូវតែភ្ជាប់មកជាមួយនូវភស្តុតាងបញ្ជាក់ថា ម្ចាស់ប្រកាសនីយបត្រតក្កកម្ម បានទទួលសំណើសុំចុះកិច្ចសន្យាអាជ្ញាប័ណ្ណពីបុគ្គលដែលចង់បានសិទ្ធិធ្វើអាជីវកម្ម តែបុគ្គលនោះមិនអាចទទួលកិច្ចសន្យាអាជ្ញាប័ណ្ណនោះបាន លើបែបបទពាណិជ្ជកម្ម ល័ក្ខខ័ណ្ឌផ្សេងៗ និងពេលវេលាសមស្រប ។

វាក្យខណ្ឌទី ១ នៃមាត្រានេះមិនត្រូវយកមកអនុវត្តទេ ក្នុងករណី :

ក- ប្រទេសជាតិមានភាពអាសន្ន ឬកាលៈទេសៈដទៃទៀត ដែលកើតឡើងជាបន្ទាន់បំផុត ។ តែទោះជាយ៉ាងណាក៏ដោយ រដ្ឋមន្ត្រីត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចនេះយ៉ាងឆាប់រហ័សដែលអាចធ្វើទៅបានដល់ម្ចាស់ប្រកាសនីយបត្រតក្កកម្ម ។

ខ- ការប្រើប្រាស់ជាសាធារណៈ មិនមានលក្ខណៈពាណិជ្ជកម្ម ។

គ- ការធ្វើអាជីវកម្ម មានលក្ខណៈប្រឆាំងនឹងការប្រកួតប្រជែង ដូចមានចែងនៅក្នុងមាត្រា ៤៧ នៃច្បាប់នេះ ។

**មាត្រា ៥៣.-**

ការធ្វើអាជីវកម្មលើតក្កកម្ម ដោយអង្គភាពរដ្ឋ ឬដោយតតិយជនដែលបានជ្រើសរើសដោយរដ្ឋមន្ត្រី គឺសម្រាប់ផ្គត់ផ្គង់ឱ្យបានបរិបូរណ៍ដល់ទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥៤.-**

ការផ្ដល់ការអនុញ្ញាត ឱ្យអង្គភាពរដ្ឋ ឬតតិយជន ធ្វើអាជីវកម្មលើតក្កកម្ម

ក្នុងវិស័យបច្ចេកវិជ្ជាសីមីខុនដាក់ទ័រ ដែលបានទទួលប្រកាសនីយបត្រតក្កកម្មរួចហើយ ហើយ គឺសម្រាប់តែការប្រើប្រាស់ជាសាធារណៈ ដែលមិនមានលក្ខណៈពាណិជ្ជកម្មតែប៉ុណ្ណោះ ។

ក្នុងករណី ដែលតុលាការមានសមត្ថកិច្ចបានវិនិច្ឆ័យថារបៀបធ្វើអាជីវកម្មលើតក្កកម្មក្នុងវិស័យបច្ចេកវិជ្ជាសីមីខុនដាក់ទ័រនោះដោយម្ចាស់ដើម ឬដោយអ្នកទទួលអាជ្ញាប័ណ្ណមានលក្ខណៈប្រឆាំងនឹងការប្រកួតប្រជែង រដ្ឋមន្ត្រីអាចចេញអាជ្ញាប័ណ្ណបញ្ជាដើម្បីកែតម្រូវរបៀបធ្វើអាជីវកម្មនេះ ។

មាត្រា ៥៥.-

សេចក្តីសម្រេចរបស់រដ្ឋមន្ត្រី នៅក្នុងផ្នែកទី ១១ នៃជំពូកទី ២ នៃច្បាប់នេះ អាចជាកម្មវត្ថុសម្រាប់ប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចបាន ។

## ផ្នែកទី ១២
## អាជ្ញាប័ណ្ណបញ្ជា

មាត្រា ៥៦.-

នៅពេលដែលមានការស្នើសុំទៅរដ្ឋមន្ត្រី ក្រោយរយៈពេលបួន(៤)ឆ្នាំ គិតពីកាលបរិច្ឆេទសុំចុះបញ្ជីនៃការស្នើសុំប្រកាសនីយបត្រតក្កកម្ម ឬបី(៣)ឆ្នាំ គិតពីកាលបរិច្ឆេទផ្តល់ប្រកាសនីយបត្រតក្កកម្ម ដោយយកកាលបរិច្ឆេទមួយណាដែលផុតកំណត់ក្រោយគេ រដ្ឋមន្ត្រីអាចចេញអាជ្ញាប័ណ្ណបញ្ជាបាន ប្រសិនបើរដ្ឋមន្ត្រីពិនិត្យឃើញថា តក្កកម្មដែលបានផ្តល់ប្រកាសនីយបត្រតក្កកម្មរួចហើយនោះ មិនត្រូវបានធ្វើអាជីវកម្ម ឬក៏ធ្វើអាជីវកម្មមិនពេញលេញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ថ្វីបើមានចែងនៅក្នុងវាក្យខណ្ឌទី ១ នៃមាត្រានេះក៏ដោយ អាជ្ញាប័ណ្ណបញ្ជាមិនត្រូវបានចេញទេ ប្រសិនបើម្ចាស់ប្រកាសនីយបត្រតក្កកម្មបានបំភ្លឺជូនរដ្ឋមន្ត្រីនូវកាលៈទេសៈសមស្របជាក់ស្តែង ដែលបង្ហាញភស្តុតាងត្រឹមត្រូវពីការមិនបានធ្វើអាជីវកម្ម ឬការធ្វើអាជីវកម្មមិនពេញលេញ ។

**មាត្រា ៥៧.-**

ការសម្រេចចេញអាជ្ញាប័ណ្ណបញ្ជាត្រូវមានចែងអំពី :

១-វិសាលភាព និងមុខងារនៃអាជ្ញាប័ណ្ណ

២-ពេលវេលាកំណត់ដែលអ្នកទទួលអាជ្ញាប័ណ្ណ ត្រូវចាប់ផ្ដើមធ្វើអាជីវកម្មលើតក្កកម្ម ដែលបានទទួលប្រកាសនីយបត្រតក្កកម្មរួចហើយ

៣-ចំនួនប្រាក់កម្រៃសមរម្យជូនទៅម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងល័ក្ខខ័ណ្ឌនៃការទូទាត់ ។

**មាត្រា ៥៨.-**

អ្នកទទួលអាជ្ញាប័ណ្ណបញ្ជាមានសិទ្ធិធ្វើអាជីវកម្មលើតក្កកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្មរួចហើយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទៅតាមល័ក្ខខ័ណ្ឌដែលបានចែងនៅក្នុងសេចក្ដីសម្រេចនៃការចេញអាជ្ញាប័ណ្ណនោះ ។ អ្នកទទួលអាជ្ញា-ប័ណ្ណបញ្ជា ត្រូវចាប់ផ្ដើមធ្វើអាជីវកម្មលើតក្កកម្មនោះ ទៅតាមពេលវេលាដែលបានកំណត់នៅក្នុងសេចក្ដីសម្រេចខាងលើ និងត្រូវធ្វើអាជីវកម្មឱ្យបានពេញលេញលើតក្កកម្មនោះ ។

**មាត្រា ៥៩.-**

នៅពេលមានសំណើពីម្ចាស់ប្រកាសនីយបត្រតក្កកម្មក្រោយ រដ្ឋមន្ត្រីអាចចេញអាជ្ញាប័ណ្ណបញ្ជាដើម្បីបញ្ជៀសការធ្វើអាជីវកម្មនៅក្នុងប្រទេសរំលោភលើប្រកាសនីយបត្រតក្កកម្មមុន ក្នុងករណីតក្កកម្មដែលបានអះអាងនៅក្នុងប្រកាសនីយ-បត្រតក្កកម្មក្រោយនោះ មានការប្រើប្រាស់បច្ចេកទេសជឿនលឿនដែលបានចាត់ទុកថាមានសារៈសំខាន់ចំពោះសេដ្ឋកិច្ច ធៀបទៅនឹងតក្កកម្មដែលបានអះអាងនៅក្នុងប្រកាសនីយបត្រតក្កកម្មមុន ។

**មាត្រា ៦០.-**

ក្នុងករណីដែលអាជ្ញាប័ណ្ណបញ្ជា ត្រូវបានចេញឱ្យដូចមានចែងនៅក្នុង

មាត្រា ៥៩ នៃច្បាប់នេះ នៅពេលមានសំណើ ពីម្ចាស់ប្រកាសនីយបត្រតក្កកម្មមុន រដ្ឋមន្ត្រី ត្រូវចេញអាជ្ញាប័ណ្ណបញ្ជាមួយទៀតឱ្យប្រើប្រាស់ប្រកាសនីយបត្រតក្កកម្មក្រោយ ។

**មាត្រា ៦១.-**

ក្នុងករណីមានសំណើសុំអាជ្ញាប័ណ្ណបញ្ជា ដូចមានចែងក្នុងមាត្រា ៥៩ និង មាត្រា ៦០ នោះ មាត្រា ៥៧ នៃច្បាប់នេះ ត្រូវយកមកអនុវត្តជាមួយនឹងល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀង ដោយមិនចាំបាច់បញ្ជាក់ពីពេលវេលាកំណត់ទេ ។

**មាត្រា ៦២.-**

ក្នុងករណីចេញអាជ្ញាប័ណ្ណបញ្ជា ដែលមានចែងក្នុងមាត្រា ៥៩ នៃច្បាប់នេះ ការផ្ទេរសិទ្ធិធ្វើអាជីវកម្ម អាចធ្វើបានតែជាមួយនឹងប្រកាសនីយបត្រតក្កកម្មក្រោយតែប៉ុណ្ណោះ ឬក្នុងករណីចេញអាជ្ញាប័ណ្ណបញ្ជាដែលមានចែងក្នុងមាត្រា ៦០ នៃច្បាប់នេះ ការផ្ទេរសិទ្ធិធ្វើអាជីវកម្មអាចធ្វើបានតែជាមួយនឹងប្រកាសនីយបត្រតក្កកម្មមុនតែប៉ុណ្ណោះ ។

**មាត្រា ៦៣.-**

ការស្នើសុំអាជ្ញាប័ណ្ណបញ្ជាត្រូវបង់កម្រៃតាមការកំណត់ដូចមានចែងក្នុង មាត្រា ១៣០ នៃច្បាប់នេះ ។

**មាត្រា ៦៤.-**

ខ្លឹមសារទាំងឡាយ ដែលមានចែងនៅក្នុងវាក្យខណ្ឌទី ២ នៃមាត្រា ៤៧ ដល់ មាត្រា ៥៥ នៃច្បាប់នេះ ត្រូវយកមកអនុវត្តនៅក្នុងផ្នែកទី ១២ នៃជំពូកទី ២ នៃ ច្បាប់នេះ ។

# ផ្នែកទី ១៣

## មោឃភាព

**មាត្រា ៦៥.-**

បុគ្គលដែលមានការពាក់ព័ន្ធ អាចស្នើសុំទៅតុលាការមានសមត្ថកិច្ច ឱ្យទុកជាមោឃៈនូវប្រកាសនីយបត្រតក្កកម្មបាន ។

**មាត្រា ៦៦.-**

តុលាការមានសមត្ថកិច្ច ត្រូវចាត់ទុកជាមោឃៈនូវប្រកាសនីយបត្រតក្កកម្ម ប្រសិនបើបុគ្គលដែលស្នើសុំនូវមោឃភាពនោះ បានបង្ហាញភស្តុតាងថាល័ក្ខខ័ណ្ឌតម្រូវណាមួយនៃវាក្យខណ្ឌទី ២ និងទី ៣ នៃមាត្រា ៣ មាត្រា ៤ ដល់មាត្រា ៩ និងមាត្រា ១៨ ដល់មាត្រា ២០ នៃច្បាប់នេះ មិនត្រូវបានបំពេញគ្រប់គ្រាន់ ឬប្រសិនបើម្ចាស់ប្រកាសនីយបត្រតក្កកម្មមិនមែនជាតក្កករ ឬមិនមែនជាអ្នកស្នងរបស់តក្កករ។

**មាត្រា ៦៧.-**

ចំពោះប្រកាសនីយបត្រតក្កកម្មដែលត្រូវបានចាត់ទុកជាមោឃៈ ឬសេចក្តីអះអាង ឬផ្នែកនៃសេចក្តីអះអាងដែលត្រូវចាត់ទុកថាមិនបានការ ត្រូវអស់សុពលភាពចាប់ពីថ្ងៃដែលផ្តល់ប្រកាសនីយបត្រតក្កកម្មមក ។

**មាត្រា ៦៨.-**

សេចក្តីសម្រេចជាស្ថាពររបស់តុលាការមានសមត្ថកិច្ចត្រូវបានជូនដំណឹងដល់មន្ត្រីកាន់កាប់បញ្ជី ដើម្បីឱ្យមន្ត្រីកាន់កាប់បញ្ជីកត់ត្រា និងចុះផ្សាយសេចក្តីសម្រេចរបស់តុលាការឱ្យបានឆាប់រហ័សតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

# ជំពូកទី ៣
# វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

## ផ្នែកទី ១
## វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ដែលអាចការពារបាន

**មាត្រា ៦៩.-**

ក្នុងន័យនៃច្បាប់នេះ វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ គឺជាវិញ្ញាបនបត្រដែលបានផ្ដល់ដើម្បីការពារម៉ូដែលមានអត្ថប្រយោជន៍ ។ ម៉ូដែលមានអត្ថប្រយោជន៍ គឺជាតក្កកម្មណាមួយដែលថ្មី និងអាចយកទៅអនុវត្តបានក្នុងវិស័យឧស្សាហកម្ម និងដែលអាចជាផលិតផល ឬដំណើរការផលិតកម្ម ឬដែលអាចទាក់ទងទៅនឹងផលិតផល ឬដំណើរការផលិតកម្ម ។

## ផ្នែកទី ២
## ការអនុវត្តន៍បទប្បញ្ញត្តិ
## ពាក់ព័ន្ធនឹងប្រកាសនីយបត្រតក្កកម្ម

**មាត្រា ៧០.-**

បទប្បញ្ញត្តិទាំងឡាយនៃជំពូកទី២នៃច្បាប់នេះត្រូវយកមកអនុវត្តចំពោះវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ឬចំពោះសំណុំលិខិតស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ លើកលែងតែមាត្រា ៧១ ដល់មាត្រា ៧៤ នៃច្បាប់នេះ ។

ក្នុងករណីមានទំនាស់រវាងសិទ្ធិលើប្រកាសនីយបត្រតក្កកម្មនិងសិទ្ធិលើវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ដូចបានចែងនៅក្នុងផ្នែកទី ២ នៃជំពូកទី ២ នៃច្បាប់នេះ បទប្បញ្ញត្តិចែងក្នុងវាក្យខណ្ឌខាងលើត្រូវយកមកអនុវត្ត ដោយគ្រាន់តែជំនួសពាក្យប្រកាសនីយបត្រតក្កកម្ម ដោយពាក្យប្រកាសនីយបត្រតក្កកម្មវិញ ឬពាក្យវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ។

# ផ្នែកទី ៣
# បទប្បញ្ញត្តិពិសេស
# ពាក់ព័ន្ធនឹងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

**មាត្រា ៧១.-**

មាត្រា ៥ និងមាត្រា ៧ នៃច្បាប់នេះ មិនត្រូវយកមកអនុវត្តទេ ក្នុងករណីដែលតក្កកម្មត្រូវបានស្នើសុំផ្ដល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ។

**មាត្រា ៧២.-**

មាត្រា ៣៦ និងមាត្រា ៤៥ នៃច្បាប់នេះ មិនត្រូវយកមកអនុវត្តទេ ចំពោះសំណុំលិខិតស្នើសុំផ្ដល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ។

**មាត្រា ៧៣.-**

វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ មានសុពលភាពរយៈពេលប្រាំពីរ (៧)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ដោយមិនមានការផ្ដល់ជាថ្មីឡើងវិញឡើយ ។

**មាត្រា ៧៤.-**

អនុលោមតាមមាត្រា ៦៥ ដល់មាត្រា ៦៧ នៃច្បាប់នេះ តុលាការមានសមត្ថកិច្ច ត្រូវចាត់ទុកជាមោឃៈ នូវវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ដោយមូលហេតុណាមួយដូចខាងក្រោម :

១-តក្កកម្មដែលអះអាងនោះ មិនបំពេញតាមល័ក្ខខ័ណ្ឌតម្រូវរបស់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ដោយយោងតាមមាត្រា ៦ មាត្រា ៨ មាត្រា ៩ និងមាត្រា ៦៩ នៃច្បាប់នេះ ។

២-សេចក្ដីអធិប្បាយនិងសេចក្ដីអះអាងមិនបានបំពេញតាមល័ក្ខខ័ណ្ឌតម្រូវដែលមានចែងក្នុងមាត្រា ១៨ និងមាត្រា ១៩ នៃច្បាប់នេះ និងបទបញ្ជាដែលពាក់ព័ន្ធនឹងមាត្រាទាំងនោះ ។

៣-គំនូសបង្ហាញដែលត្រូវការចាំបាច់សម្រាប់ពន្យល់អំពីតក្កកម្មមិនត្រូវបានផ្តល់ឱ្យតាមលក្ខខ័ណ្ឌតម្រូវ ។

៤-ម្ចាស់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍មិនមែនជាតក្កករ ឬមិនមែនជាអ្នកស្នងរបស់តក្កករ ។

## ផ្នែកទី ៤
## ការផ្លាស់ប្តូរសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ឬសំណុំលិខិតស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍

**មាត្រា ៧៥.-**

មុនពេលផ្តល់ ឬបដិសេធការផ្តល់ប្រកាសនីយបត្រតក្កកម្ម អ្នកដាក់ពាក្យសុំអាចផ្លាស់ប្តូរសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មរបស់ខ្លួន ទៅជាសំណុំលិខិតស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍បាន ដោយត្រូវបង់កម្រៃតាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។ កាលបរិច្ឆេទសុំចុះបញ្ជីស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍នោះ ត្រូវបានកត់ត្រាទៅតាមកាលបរិច្ឆេទសុំចុះបញ្ជីស្នើសុំប្រកាសនីយបត្រតក្កកម្ម ។

មុនពេលផ្តល់ ឬបដិសេធការផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ អ្នកដាក់ពាក្យសុំអាចផ្លាស់ប្តូរសំណុំលិខិតស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍របស់ខ្លួន ទៅជាសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មបាន ដោយត្រូវបង់កម្រៃតាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។ កាលបរិច្ឆេទសុំចុះបញ្ជីស្នើសុំប្រកាសនីយបត្រតក្កកម្មនោះ ត្រូវបានកត់ត្រាទៅតាមកាលបរិច្ឆេទសុំចុះបញ្ជីស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ។

**មាត្រា ៧៦.-**

អនុលោមតាមមាត្រា ៧៥ នៃច្បាប់នេះ ការផ្លាស់ប្តូរសំណុំលិខិតស្នើសុំធ្វើបានបានតែមួយដងប៉ុណ្ណោះ ។

# ជំពូកទី ៤
# សំណុំលិខិតស្នើសុំអន្តរជាតិ ក្រោមសន្ធិសញ្ញា សហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

## ផ្នែកទី ១
## ការបកស្រាយនៃពាក្យសំខាន់ពាក់ព័ន្ធនឹង សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

**មាត្រា ៧៧.-**

ក្នុងន័យនៃច្បាប់នេះ :

១-សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មមានន័យថាជាសន្ធិសញ្ញាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យប្រកាសនីយបត្រតក្កកម្ម ដែលបានចុះហត្ថលេខានៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៧០ នៅទីក្រុងវ៉ាស៊ីងតោន ។

២-ពាក្យ : ជ្រើសរើស ការិយាល័យជ្រើសរើស ជ្រើសតាំង ការិយាល័យជ្រើសតាំង សំណុំលិខិតស្នើសុំអន្តរជាតិ កាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំអន្តរជាតិ ការពិនិត្យជំហានដំបូងអន្តរជាតិ និងការិយាល័យទទួលសំណុំលិខិតស្នើសុំ មានន័យដូចមានចែងនៅក្នុងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ។

## ផ្នែកទី ២
## កាលបរិច្ឆេទសុំចុះបញ្ជី និងអានុភាពនៃសំណុំលិខិតស្នើសុំអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលត្រូវបានជ្រើសរើស

**មាត្រា ៧៨.-**

យោងតាមជំពូកនេះ សំណុំលិខិតស្នើសុំអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាប្រទេសដែលត្រូវបានជ្រើសរើស ត្រូវចាត់ទុកថាជាសំណុំលិខិតស្នើសុំប្រ-

កាសនីយបត្រតក្កកម្ម ឬវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៏ ដែលបានសុំចុះបញ្ជី នៅក្រោមច្បាប់នេះ ដោយមានកាលបរិច្ឆេទសុំចុះបញ្ជីដូចគ្នា ទៅនឹងកាលបរិច្ឆេទសុំចុះបញ្ជីអន្តរជាតិ ដូចបានចែងនៅក្នុងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយ-បត្រតក្កកម្ម ។

## ផ្នែកទី ៣
## នាយកដ្ឋានទទួលបន្ទុកចុះបញ្ជីដែលអនុវត្តតួនាទី ជាការិយាល័យទទួលសំណុំលិខិតស្នើសុំ

**មាត្រា ៧៩.-**

នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ត្រូវអនុវត្តតួនាទីជាការិយាល័យទទួលសំណុំលិខិតស្នើសុំ ចំពោះសំណុំលិខិតស្នើសុំអន្តរជាតិដែលបានដាក់នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជីដោយជនដែលមានទីលំនៅ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនដែលមានសញ្ជាតិខ្មែរ ។

**មាត្រា ៨០.-**

រដ្ឋមន្ត្រីអាចចុះកិច្ចព្រមព្រៀងបាន ដោយយោងទៅតាមវិធាន ១៩.១(ខ) នៃបទប្បញ្ញត្តិរបស់សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ដែលតាមរយៈនោះ អង្គការអន្តររដ្ឋាភិបាល ឬការិយាល័យជាតិនៃរដ្ឋ ដែលជាសមាជិកសន្ធិ-សញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ត្រូវអនុវត្តតួនាទីជាការិយាល័យទទួលសំណុំលិខិតស្នើសុំជំនួសនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី សម្រាប់អ្នកដាក់ពាក្យសុំជាជនដែលមានទីលំនៅ នៅក្នុងព្រះរាជាណាចក្រកម្ពុជាឬជនដែលមានសញ្ជាតិខ្មែរ ។

## ផ្នែកទី ៤
## ការដាក់សំណុំលិខិតស្នើសុំអន្តរជាតិ
## នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី

**មាត្រា ៨១.-**

សំណុំលិខិតស្នើសុំអន្តរជាតិដែលត្រូវដាក់នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ក្នុងតួនាទីជាការិយាល័យទទួលសំណុំលិខិតស្នើសុំនោះ ត្រូវធ្វើជាភាសាណាមួយដែលបានកំណត់ ។ កម្រៃក្នុងការបញ្ជូនឯកសារត្រូវបង់នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី តាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។

## ផ្នែកទី ៥
## នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី
## ដែលអនុវត្តតួនាទីជាការិយាល័យជ្រើសរើស

**មាត្រា ៨២.-**

នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ត្រូវបំពេញតួនាទីជាការិយាល័យជ្រើសរើស ចំពោះសំណុំលិខិតស្នើសុំអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើស ដោយយោងតាមជំពូកទី ១ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ក្នុងគោលបំណងទទួលបាននូវប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍កម្រិតជាតិនៅក្រោមច្បាប់នេះ ។

## ផ្នែកទី ៦
## នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី
## ដែលអនុវត្តតួនាទីជាការិយាល័យជ្រើសតាំង

**មាត្រា ៨៣.-**

នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ត្រូវបំពេញតួនាទីជាការិយាល័យជ្រើសតាំង ចំពោះសំណុំលិខិតស្នើសុំអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើស

យោងតាមមាត្រា ៨២ នៃច្បាប់នេះ ប្រសិនបើអ្នកដាក់ពាក្យសុំជ្រើសតាំងព្រះរាជាណាចក្រកម្ពុជា ដោយយោងតាមជំពូកទី ២ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ក្នុងគោលបំណងទទួលបាននូវប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍កម្រិតជាតិ នៅក្រោមច្បាប់នេះ ។

## ផ្នែកទី ៧
## កិច្ចដំណើរការពិនិត្យកម្រិតជាតិ

**មាត្រា ៨៤.-**

នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ដែលជាការិយាល័យជ្រើសរើស ឬការិយាល័យជ្រើសតាំង មិនត្រូវចាប់ដំណើរការពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិដែលបានជ្រើសរើសព្រះរាជាណាចក្រកម្ពុជា មុនរយៈពេលផុតកំណត់ដូចបានចែងក្នុងមាត្រា ៨៥ នៃច្បាប់នេះទេ លើកលែងតែអ្នកដាក់ពាក្យសុំបានបំពេញតាមល័ក្ខខ័ណ្ឌតម្រូវនៃមាត្រានោះ ហើយដាក់នូវសំណើជាការប្រញាប់មកនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ដើម្បីឱ្យចាប់ផ្ដើមពិនិត្យសំណុំលិខិតស្នើសុំមុនរយៈពេលកំណត់ ។

## ផ្នែកទី ៨
## ការឈានចូលដំណាក់ការពិនិត្យកម្រិតជាតិ

**មាត្រា ៨៥.-**

មុនផុតរយៈពេលកំណត់ ដែលមានចែងក្នុងមាត្រា ២២ ឬមាត្រា ៣៩ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ឬរយៈពេលកំណត់ចុងក្រោយដែលមានចែងនៅក្នុងបទបញ្ញានៃច្បាប់នេះ អ្នកដាក់សំណុំលិខិតស្នើសុំអន្តរជាតិនៅព្រះរាជាណាចក្រកម្ពុជាត្រូវ :

១-បង់កម្រៃតាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០នៃច្បាប់នេះ នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី

២-ដាក់ជូននាយកដ្ឋានទទួលបន្ទុកចុះបញ្ជីនូវសេចក្តីបកប្រែនៃសំណុំលិខិតស្នើសុំអន្តរជាតិជាភាសាណាមួយតាមការកំណត់ ប្រសិនបើសំណុំលិខិតស្នើសុំអន្តរជាតិនោះមិនបានដាក់ជូនជាភាសាដែលបានកំណត់ ឬមិនបានចុះផ្សាយក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មនូវការបកប្រែជាភាសាដែលបានកំណត់នោះ ។

## ផ្នែកទី ៩
## ការខកខានមិនបានឈានចូល
## ដំណាក់ការពិនិត្យក្រម្រិតជាតិ

**មាត្រា ៨៦.-**

ក្នុងន័យនៃច្បាប់នេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបំពេញតាមល័ក្ខខ័ណ្ឌតម្រូវ និងតាមរយៈពេលកំណត់នៃមាត្រា ៨៥ នៃច្បាប់នេះទេ សំណុំលិខិតស្នើសុំអន្តរជាតិនោះនឹងត្រូវបានចាត់ទុកថាបានដកយកទៅវិញ ។

## ផ្នែកទី ១០
## កិច្ចដំណើរការពិនិត្យ
## សំណុំលិខិតស្នើសុំអន្តរជាតិអនុលោមតាម
## សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

**មាត្រា ៨៧.-**

នាយកដ្ឋានទទួលបន្ទុកចុះបញ្ជីត្រូវដំណើរការពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិ ដោយអនុលោមតាមបទប្បញ្ញត្តិនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ព្រមទាំងអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ នៅពេលមានទំនាស់កើតឡើង ត្រូវយកបទប្បញ្ញត្តិនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មមកអនុវត្ត ។ បទបញ្ជាទាំងឡាយដែលបង្កើតឡើងនៅក្រោមច្បាប់នេះត្រូវបានចែងឡើងសម្រាប់កិច្ចដំណើរការពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិ ។

**មាត្រា ៨៨.-**

ការពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិ ដោយនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី និងការប្រព្រឹត្តិទៅនៃនាយកដ្ឋាននេះដែលទាក់ទងជាមួយនឹងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម រួមទាំងកម្រៃដែលត្រូវបង់ ការកំណត់ពេលវេលា និងល័ក្ខខ័ណ្ឌតម្រូវផ្សេងៗដែលពាក់ព័ន្ធទៅនឹងសំណុំលិខិតស្នើសុំអន្តរជាតិ ត្រូវកំណត់ដោយបទបញ្ជានិងត្រូវអនុវត្តតាមមាត្រា ១៣០ នៃច្បាប់នេះ ។

## ជំពូកទី ៥

## គំនូរឧស្សាហកម្ម

### ផ្នែកទី ១

### គំនូរឧស្សាហកម្មដែលអាចការពារបាន

**មាត្រា ៨៩.-**

គំនូរឧស្សាហកម្ម ក្នុងន័យនៃច្បាប់នេះ គឺជាការផ្គុំនៃបន្ទាត់ ឬពណ៌ ឬទម្រង់បីវិមាត្រ ឬសម្ភារៈណាមួយ ទោះបីជាមានឬពុំមានការផ្សំរួមជាមួយបន្ទាត់ ឬពណ៌ក៏ដោយ ឱ្យតែការផ្គុំទម្រង់ ឬសម្ភារៈទាំងនោះវិលេចឡើងជារូបរាងពិសេសរបស់ផលិតផលឧស្សាហកម្ម ឬសិប្បកម្មនិងដែលអាចធ្វើជាគំរូផលិតផលឧស្សាហកម្ម ឬសិប្បកម្ម និងអាចសម្គាល់បានដោយចក្ខុ ។

**មាត្រា ៩០.-**

ច្បាប់នេះមិនការពារផ្នែកណាមួយនៃគំនូរឧស្សាហកម្ម ដែលបម្រើឱ្យគោលបំណងសម្រាប់តែទទួលបាននូវលទ្ធផលបច្ចេកទេស និងដែលផ្នែកនោះមិនមានរូបរាងច្បាស់លាស់ ។

## ផ្នែកទី ២
## គំនូរឧស្សាហកម្មដែលអាចចុះបញ្ជីបាន

**មាត្រា ៩១.-**

គំនូរឧស្សាហកម្មអាចចុះបញ្ជីបាន ប្រសិនបើថ្មី ។

**មាត្រា ៩២.-**

គំនូរឧស្សាហកម្មត្រូវចាត់ថាថ្មី ប្រសិនបើគំនូរឧស្សាហកម្មនោះមិនទាន់បាន បញ្ចេញឱ្យដឹងដល់សាធារណជននៅទីកន្លែងណាមួយនៅលើពិភពលោក មុនកាលបរិច្ឆេទសុំចុះបញ្ជី ឬមុនកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំ តាមរយៈការផ្សព្វផ្សាយដោយប្រើរូបភាពជាក់ស្តែង ឬតាមរយៈការប្រើប្រាស់ ឬតាមរយៈមធ្យោបាយផ្សព្វផ្សាយផ្សេងៗទៀត ។

ក្នុងន័យនៃវាក្យខណ្ឌទី ១ នៃមាត្រានេះ មិនបានចាត់ទុកថាជាការដឹងដល់សាធារណជនចំពោះករណីដូចខាងក្រោម :

ក-ការដឹងដល់សាធារណជននូវគំនូរឧស្សាហកម្មដែលបានកើតឡើងក្នុងអំឡុងពេលដប់ពីរ(១២)ខែ មុនកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើ សុំ ឬកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំនោះ

ខ-ការធ្វើឱ្យលេចព្ធខ្ជរខ្ជាយពត៌មានអំពីគំនូរឧស្សាហកម្ម តាមរយៈអ្នកដាក់ពាក្យសុំ តាមរយៈអ្នកស្នងរបស់បុព្វជន ឬតាមរយៈការរំលោភរបស់ភាគីទីបីទៅលើអ្នកដាក់ពាក្យសុំ ឬអ្នកស្នងរបស់បុព្វជនដែលបណ្តាលឱ្យលេចព្ធខ្ជរខ្ជាយពត៌មាននេះ ។

**មាត្រា ៩៣.-**

គំនូរឧស្សាហកម្ម ដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌មិនអាចចុះបញ្ជីបានឡើយ ។

## ផ្នែកទី ៣
## សិទ្ធិក្នុងការចុះបញ្ជីគំនូរឧស្សាហកម្ម
## និងការដាក់ឈ្មោះអ្នកបង្កើតស្នាដៃ

**មាត្រា ៩៤.-**

ខ្លឹមសារទាំងឡាយ ដែលមានចែងនៅក្នុងមាត្រា ១០ ដល់មាត្រា ១៥ នៃច្បាប់នេះ ត្រូវយកមកអនុវត្តនៅផ្នែកទី ៣ នៃជំពូកទី ៥ នៃច្បាប់នេះ ។

## ផ្នែកទី ៤
## សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម

**មាត្រា ៩៥.-**

សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មត្រូវដាក់ជូនទៅក្រសួងទទួលបន្ទុកឧស្សាហកម្ម ដែលក្នុងនោះត្រូវរួមមានពាក្យសុំ គំនូសបង្ហាញ រូបថត ឬគំនូសតាងផ្សេងៗទៀត ជាតំណាងនៃវត្ថុដែលបង្កើតឡើងពីគំនូរឧស្សាហកម្ម និងការចង្អុលបង្ហាញប្រភេទផលិតផលដែលគំនូរឧស្សាហកម្មត្រូវយកមកប្រើប្រាស់ ។ ក្នុងករណីដែលគំនូរឧស្សាហកម្មនោះមានទម្រង់ពីរវិមាត្រ សំណុំលិខិតស្នើសុំនេះត្រូវភ្ជាប់ដោយរូបសំណាកវត្ថុដែលតាងឱ្យរូបរាងពិតរបស់គំនូរឧស្សាហកម្ម ។ ការដាក់សំណុំលិខិតស្នើសុំត្រូវតែមានការបង់កម្រៃតាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។

**មាត្រា ៩៦.-**

ក្នុងករណីអ្នកដាក់ពាក្យសុំមិនមែនជាអ្នកបង្កើតស្នាដៃ ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្មនោះត្រូវតែភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់អំពីសិទ្ធិរបស់អ្នកដាក់ពាក្យសុំ ក្នុងការសុំចុះបញ្ជីគំនូរឧស្សាហកម្មនោះ ។

**មាត្រា ៩៧.-**

គំនូរឧស្សាហកម្មពីរ ឬច្រើននៃវត្ថុដែលស្ថិតនៅក្នុងក្រុមជាមួយគ្នានៃចំ-

ណាត់ថ្នាក់អន្តរជាតិ ឬក្នុងឈុតជាមួយគ្នា ឬក៏ការផ្គុំដូចគ្នា អាចជាកម្មវត្ថុដើម្បីធ្វើសំណុំលិខិតស្នើសុំតែមួយបាន ។

**មាត្រា ៩៨.-**

ក្នុងករណីសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មមានភ្ជាប់ពាក្យសុំពន្យារការធ្វើការចុះផ្សាយគំនូរឧស្សាហកម្មនោះ អាចត្រូវពន្យារធ្វើការចុះផ្សាយបាន តែមិនត្រូវលើសពីដប់ពីរ(១២)ខែ គិតពីកាលបរិច្ឆេទសុំចុះបញ្ជី ឬកាលបរិច្ឆេទអាទិភាព ។

**មាត្រា ៩៩.-**

អ្នកដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម អាចដកសំណុំលិខិតស្នើសុំទៅវិញនៅពេលណាក៏បាន ក្នុងករណីដែលសំណុំលិខិតស្នើសុំនោះស្ថិតក្នុងរយៈពេលរង់ចាំទុកសម្រាប់ពិនិត្យដើម្បីសម្រេចឱ្យចុះបញ្ជី ។

## ផ្នែកទី ៥
## សិទ្ធិអាទិភាព

**មាត្រា ១០០.-**

ខ្លឹមសារទាំងឡាយដែលមានចែងនៅក្នុងមាត្រា ២៧ ដល់មាត្រា ២៩ នៃច្បាប់នេះ ត្រូវយកមកអនុវត្តនៅផ្នែកទី ៥ នៃជំពូកទី ៥ នៃច្បាប់នេះ ។

## ផ្នែកទី ៦
## ការពិនិត្យ ការចុះបញ្ជី និងការចុះផ្សាយគំនូរឧស្សាហកម្ម

**មាត្រា ១០១.-**

មន្ត្រីកាន់កាប់បញ្ជីអាចទទួលស្គាល់កាលបរិច្ឆេទទទួលសំណុំលិខិតស្នើសុំថាជាកាលបរិច្ឆេទសុំចុះបញ្ជីបាន លុះត្រាតែនៅពេលទទួលនោះ សំណុំលិខិតមាន

អមដោយសេចក្តីបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំ និងមានបង្ហាញគំនូសតាងជាតំណាងនៃវត្ថុដែលបង្កើតដោយគំនូរឧស្សាហកម្មនោះ ។

នៅពេលបានទទួលសំណុំលិខិតស្នើសុំ ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាសំណុំលិខិតស្នើសុំនោះមិនបានបំពេញត្រឹមត្រូវទៅតាមល័ក្ខខ័ណ្ឌតម្រូវរបស់វាក្យខណ្ឌទី ១ នៃមាត្រានេះទេ មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើឱ្យអ្នកដាក់ពាក្យសុំធ្វើការកែតម្រូវទៅតាមល័ក្ខខ័ណ្ឌតម្រូវនោះ និងកត់ត្រាកាលបរិច្ឆេទសុំចុះបញ្ជីទៅតាមកាលបរិច្ឆេទដែលបានទទួលការកែតម្រូវ ។ ប៉ុន្តែប្រសិនបើសំណុំលិខិតស្នើសុំមិនបានកែតម្រូវទៅតាមការណែនាំទេ សំណុំលិខិតស្នើសុំនោះមិនត្រូវទទួលចុះបញ្ជីឡើយ ។

**មាត្រា ១០២.-**

បន្ទាប់ពីការកត់ត្រាកាលបរិច្ឆេទសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យលើ :

១-សំណុំលិខិតស្នើសុំចុះបញ្ជីបំពេញឱ្យបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌតម្រូវនៃមាត្រា ៩៥ និងមាត្រា ៩៦ នៃច្បាប់នេះ និងបទបញ្ញាដែលពាក់ព័ន្ធទៅនឹងមាត្រាទាំងនេះ ។

២-ការបង់កម្រៃក្នុងការដាក់សំណុំលិខិតស្នើសុំ ឱ្យបានត្រឹមត្រូវទៅតាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។

៣-គំនូរឧស្សាហកម្មបំពេញឱ្យបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌតម្រូវនៃមាត្រា ៨៩ មាត្រា ៩០ មាត្រា ៩៣ នៃច្បាប់នេះ និងបទបញ្ញាដែលពាក់ព័ន្ធទៅនឹងមាត្រាទាំងនេះ ។

**មាត្រា ១០៣.-**

មន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីគំនូរឧស្សាហកម្ម ចុះផ្សាយសេចក្តីបញ្ជាក់អំពីការចុះបញ្ជី និងត្រូវដំណើរការចេញវិញ្ញាបនបត្រចុះបញ្ជីឱ្យអ្នកដាក់ពាក្យសុំ ប្រ-សិនបើពិនិត្យឃើញថាល័ក្ខខ័ណ្ឌទាំងឡាយ ដូចមានចែងនៅក្នុងមាត្រា ១០២ នៃច្បាប់

នេះបានបំពេញត្រឹមត្រូវ ។ ក្នុងករណីសំណុំលិខិតស្នើសុំមិនបានបំពេញត្រឹមត្រូវ មន្ត្រីកាន់កាប់បញ្ជីត្រូវធ្វើការបដិសេធសំណុំលិខិតស្នើសុំនោះ ។

**មាត្រា ១០៤.-**

មន្ត្រីកាន់កាប់បញ្ជីមិនត្រូវបើកបង្ហាញជាសាធារណៈនូវគំនូរ ឬឯកសារណាមួយដែលពាក់ព័ន្ធទៅនឹងសំណុំលិខិតស្នើសុំ ក្នុងករណីមានពាក្យសុំពន្យារការធ្វើការចុះផ្សាយគំនូរឧស្សាហកម្ម ដូចមានចែងនៅក្នុងមាត្រា ៩៨ នៃច្បាប់នេះ ។ ក្នុងករណីខាងលើនេះ មន្ត្រីកាន់កាប់បញ្ជីត្រូវចុះផ្សាយការបញ្ជាក់អំពីការសុំពន្យារការធ្វើការចុះផ្សាយគំនូរឧស្សាហកម្ម និងពត៌មានដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ម្ចាស់គំនូរឧស្សាហកម្ម ព្រមទាំងបញ្ជាក់អំពីកាលបរិច្ឆេទសុំចុះបញ្ជី សំណុំលិខិតស្នើសុំរយៈពេលនៃការសុំពន្យារ និងចំណុចសំខាន់ៗផ្សេងទៀតដែលបានកំណត់ ។

នៅពេលផុតកំណត់ការពន្យារការធ្វើការចុះផ្សាយ មន្ត្រីកាន់កាប់បញ្ជីត្រូវតែចុះផ្សាយគំនូរឧស្សាហកម្មដែលបានចុះបញ្ជីរួចហើយនោះ ។

នៅក្នុងអំឡុងពេលពន្យារការធ្វើការចុះផ្សាយ ការប្តឹងអំពីការរំលោភលើគំនូរឧស្សាហកម្មដែលបានចុះបញ្ជីរួចហើយអាចធ្វើទៅបាន លុះត្រាតែអាចកំណត់បានថា បុគ្គលដែលត្រូវបានចោទថារំលោភនោះបានដឹងអំពីពត៌មានដែលមាននៅក្នុងបញ្ជី និងនៅក្នុងឯកសារពាក់ព័ន្ធនឹងសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មនោះ។

## ផ្នែកទី ៧
## សិទ្ធិដែលទទួលបានពីការចុះបញ្ជី
## រយៈពេលការពារ និងការចុះបញ្ជីសារឡើងវិញ

**មាត្រា ១០៥.-**

ការធ្វើអាជីវកម្មដោយបុគ្គលដទៃទៀត ដែលមិនមែនជាម្ចាស់លើគំនូរឧស្សាហកម្មដែលបានចុះបញ្ជីរួចហើយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែមានការយល់ព្រមពីម្ចាស់ដើម ។

**មាត្រា ១០៦.-**

ក្នុងន័យនៃច្បាប់នេះ ការធ្វើអាជីវកម្មលើគំនូរឧស្សាហកម្មដែលបានចុះបញ្ជីរួចហើយ គឺការផលិត ការលក់ ឬការនាំចូលវត្ថុទាំងឡាយដែលបង្កើតឡើងដោយគំនូរឧស្សាហកម្មនោះ ។

**មាត្រា ១០៧.-**

សិទ្ធិទទួលបានពីការចុះបញ្ជីគំនូរឧស្សាហកម្ម មិនអនុវត្តទៅលើសម្ភារៈដែលបានដាក់តាំងនៅលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ឬនៅលើទីផ្សារក្រៅព្រះរាជាណាចក្រកម្ពុជាដោយម្ចាស់ ឬដោយមានការយល់ព្រមពីម្ចាស់គំនូរឧស្សាហកម្មនោះទេ ។

**មាត្រា ១០៨.-**

ម្ចាស់គំនូរឧស្សាហកម្មអាចមានសិទ្ធិប្ដឹងទៅតុលាការមានសមត្ថកិច្ច ចំពោះបុគ្គលណាដែលរំលោភលើគំនូរឧស្សាហកម្មរបស់ខ្លួនបាន តាមរយៈការអនុវត្តន៍សកម្មភាពទាំងឡាយ ដូចមានចែងនៅក្នុងមាត្រា ១០៦ នៃច្បាប់នេះ ដោយគ្មានការយល់ព្រមពីម្ចាស់ ឬតាមរយៈការអនុវត្តន៍សកម្មភាពដែលបណ្ដាលឱ្យមានការរំលោភកើតឡើង ។

**មាត្រា ១០៩.-**

ការចុះបញ្ជីគំនូរឧស្សាហកម្មមានសុពលភាពប្រាំ(៥)ឆ្នាំ ចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ។ ការចុះបញ្ជីអាចធ្វើសាឡើងវិញបានចំនួនពីរ(២)ដងជាប់ៗគ្នា ដែលម្ដងៗមានសុពលភាពប្រាំ(៥)ឆ្នាំ ដោយម្ចាស់គំនូរឧស្សាហកម្មត្រូវបង់កម្រៃបន្តសុពលភាព តាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។ ការយឺតយ៉ាវក្នុងការបង់កម្រៃបន្តសុពលភាពនេះ ត្រូវអនុញ្ញាតយ៉ាងយូរត្រឹមប្រាំមួយ(៦)ខែ ដោយត្រូវមានការបង់កម្រៃបន្ថែម លើការយឺតយ៉ាវនោះទៅតាមការកំណត់ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។

## ផ្នែកទី ៨
## មោឃភាព

**មាត្រា ១១០.-**

បុគ្គលដែលមានការពាក់ព័ន្ធអាចស្នើសុំទៅតុលាការមានសមត្ថកិច្ចឱ្យទុកជាមោឃៈ នូវការចុះបញ្ជីគំនូរឧស្សាហកម្មបាន ។

**មាត្រា ១១១.-**

តុលាការមានសមត្ថកិច្ចត្រូវចាត់ទុកជាមោឃៈ នូវការចុះបញ្ជីគំនូរឧស្សាហកម្ម ប្រសិនបើបុគ្គលដែលស្នើសុំនោះ បង្ហាញភស្តុតាងថាល័ក្ខខ័ណ្ឌតម្រូវណាមួយនៃផ្នែកទី ១ និងផ្នែកទី ២ នៃជំពូកនេះមិនបានបំពេញត្រឹមត្រូវ ឬប្រសិនបើអ្នកសុំចុះបញ្ជីមិនមែនជាអ្នកបង្កើតស្នាដៃ ឬមិនមែនជាអ្នកស្នងរបស់អ្នកបង្កើតស្នាដៃ ។

**មាត្រា ១១២.-**

ចំពោះគំនូរឧស្សាហកម្មដែលតុលាការមានសមត្ថកិច្ចសម្រេចចាត់ទុកជាមោឃៈ ការអស់សុពលភាពនោះត្រូវគិតចាប់ពីថ្ងៃចុះបញ្ជីគំនូរឧស្សាហកម្មមក ។

**មាត្រា ១១៣.-**

សេចក្តីសម្រេចជាស្ថាពររបស់តុលាការមានសមត្ថកិច្ចត្រូវជូនដំណឹងដល់មន្ត្រីកាន់កាប់បញ្ជី ដើម្បីឱ្យមន្ត្រីកាន់កាប់បញ្ជីកត់ត្រានិងចុះផ្សាយសេចក្តីសម្រេចរបស់តុលាការឱ្យបានឆាប់រហ័សតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

# ជំពូកទី ៦
## បទប្បញ្ញត្តិរួម

### ផ្នែកទី ១
### ការប្តូរម្ចាស់កម្មសិទ្ធិ និងកិច្ចសន្យាអាជ្ញាប័ណ្ណ

**មាត្រា ១១៤.-**

យោងតាមសំណើរបស់ភាគីដែលពាក់ព័ន្ធមកមន្ត្រីកាន់កាប់បញ្ជី ការប្តូរម្ចាស់កម្មសិទ្ធិនៃប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ឬការចុះបញ្ជីគំនូរឧស្សាហកម្ម ឬការប្តូរម្ចាស់កម្មសិទ្ធិនៃសំណុំលិខិតស្នើសុំខាងលើ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវកត់ត្រាចូលបញ្ជី និងចុះផ្សាយជាសាធារណៈដោយមន្ត្រីកាន់កាប់បញ្ជី លើកលែងតែករណីនៃសំណុំលិខិតស្នើសុំដែលមិនត្រូវធ្វើការចុះផ្សាយ ។ ការប្តូរម្ចាស់កម្មសិទ្ធិនេះនឹងមិនមានអានុភាពចំពោះភាគីទីបីឡើយ រហូតដល់ការកត់ត្រាចូលបញ្ជីត្រូវបានធ្វើរួចជាស្ថាពរ ។

**មាត្រា ១១៥.-**

កិច្ចសន្យាអាជ្ញាប័ណ្ណនៃប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ឬគំនូរឧស្សាហកម្មដែលបានចុះបញ្ជីរួចហើយ ឬសំណុំលិខិតស្នើសុំនៃករណីខាងលើនេះ ត្រូវដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជី ។ មន្ត្រីកាន់កាប់បញ្ជីត្រូវរក្សាការសម្ងាត់ដែលមាននៅក្នុងកិច្ចសន្យាអាជ្ញាប័ណ្ណ ប៉ុន្តែត្រូវកត់ត្រាចូលបញ្ជីនិងត្រូវចុះផ្សាយជាសាធារណៈនូវចំណុចគោលមួយចំនួន ។ កិច្ចសន្យាអាជ្ញាប័ណ្ណនេះមិនមានអានុភាពចំពោះភាគីទីបីឡើយ រហូតដល់ការកត់ត្រាចូលបញ្ជីត្រូវធ្វើរួចជាស្ថាពរ ។

## ផ្នែកទី ២
## ភ្នាក់ងារ

**មាត្រា ១១៦.-**

ក្នុងករណីអ្នកដាក់ពាក្យសុំមានទីលំនៅអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មសំខាន់ស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជា អ្នកស្នើសុំនោះត្រូវតែមានតំណាងជាភ្នាក់ងារដែលមានទីលំនៅ និងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលបានបំពេញតាមល័ក្ខខ័ណ្ឌតម្រូវទាំងឡាយដែលបានកំណត់ ។

## ផ្នែកទី ៣
## ការរៀបចំនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី

**មាត្រា ១១៧.-**

ក្រសួងទទួលបន្ទុកឧស្សាហកម្ម ត្រូវបង្កើតនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ដែលមានតួនាទីទាក់ទងទៅនឹងនីតិវិធីសម្រាប់ :

១-ការផ្តល់ប្រកាសនីយបត្រតក្កកម្ម ការផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងការចុះបញ្ជីគំនូរឧស្សាហកម្ម

២-ការគ្រប់គ្រងប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ដែលបានផ្តល់ និងគំនូរឧស្សាហកម្ម ដែលបានចុះបញ្ជីដូចមានចែងនៅក្នុងច្បាប់នេះ និងនៅក្នុងបទបញ្ញាទាំងឡាយ ។

## ផ្នែកទី ៤
## បញ្ជី និង ព្រឹត្តិបត្រផ្លូវការ

**មាត្រា ១១៨.-**

ក្រសួងទទួលបន្ទុកឧស្សាហកម្ម ត្រូវមានបញ្ជីពីរដាច់ដោយឡែកពីគ្នា គឺមួយសម្រាប់ប្រកាសនីយបត្រតក្កកម្មនិងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និង

មួយទៀតសម្រាប់គំនូរឧស្សាហកម្ម ។ រាល់ការកត់ត្រាដែលមានចែងនៅក្នុងច្បាប់នេះ ត្រូវធ្វើនៅក្នុងបញ្ជីខាងលើ ។

បុគ្គលណាក៏ដោយក៏អាចពិនិត្យមើលបញ្ជីខាងលើបាន ហើយអាចដកស្រង់ពត៌មានផ្សេងៗបាន ស្របទៅតាមល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងបទបញ្ជាទាំងឡាយ ។

**មាត្រា ១១៩.-**

ក្រសួងទទួលបន្ទុកឧស្សាហកម្មត្រូវចុះផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការនូវរាល់ពត៌មានដែលត្រូវចុះផ្សាយជាសាធារណៈ ដូចមានចែងនៅក្នុងច្បាប់នេះ ។

## ផ្នែកទី ៥
## ការកែកំហុស និងការពន្យារពេល

**មាត្រា ១២០.-**

មន្ត្រីកាន់កាប់បញ្ជីអាចកែតម្រូវរាល់កំហុសក្នុងការបកប្រែ ការកត់ត្រាកំហុសដែលមាននៅក្នុងសំណុំលិខិតស្នើសុំ ឯកសារដែលបានដាក់នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ឬនៅក្នុងការកត់ត្រាផ្សេងៗបានដោយអនុលោមតាមច្បាប់នេះនិងបទបញ្ជាទាំងឡាយ ។

**មាត្រា ១២១.-**

នៅពេលបានទទួលសំណើសុំជាលាយលក្ខណ៍អក្សរ ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាជាការសមស្រប មន្ត្រីកាន់កាប់បញ្ជីអាចពន្យារពេលបានសម្រាប់អនុវត្តសកម្មភាពណាមួយ ឬប្រកាន់យកចំណាត់ការណាមួយក្រោមច្បាប់នេះ និងក្រោមបទបញ្ជាទាំងឡាយ ដោយជូនដំណឹងដល់ភាគីពាក់ព័ន្ធ និងតាមល័ក្ខខ័ណ្ឌដែលមន្ត្រីកាន់កាប់បញ្ជីណែនាំ ។ ការពន្យារនេះ អាចត្រូវយល់ព្រមបានទោះបីរយៈពេលអនុវត្តនូវសកម្មភាព ឬប្រកាន់យកនូវចំណាត់ការត្រូវផុតកំណត់ហើយក៏ដោយ ។

## ផ្នែកទី ៦
## ការអនុវត្តន៍អំណាចឆន្ទានុសិទ្ធិ

**មាត្រា ១២២.-**

មន្ត្រីកាន់កាប់បញ្ជីត្រូវផ្តល់ឱកាសសម្រាប់សវនាការដល់ភាគីណាមួយនៃបណ្តឹងនៅចំពោះមុខខ្លួន មុនពេលអនុវត្តអំណាចឆន្ទានុសិទ្ធិដែលបានប្រគល់ឱ្យដោយច្បាប់នេះ និងដោយបទបញ្ជាទាំងឡាយចំពោះភាគីនោះ ។

## ផ្នែកទី ៧
## សមត្ថកិច្ចរបស់តុលាការ និងការប្តឹងតវ៉ា

**មាត្រា ១២៣.-**

រាល់វិវាទដែលបានកើតឡើងពាក់ព័ន្ធទៅនឹងការអនុវត្តន៍ច្បាប់នេះនិងបទបញ្ជាទាំងឡាយ ត្រូវប្តឹងទៅតុលាការមានសមត្ថកិច្ច ។

**មាត្រា ១២៤.-**

សេចក្តីសម្រេចរបស់ក្រសួងទទួលបន្ទុកឧស្សាហកម្ម នៅក្រោមច្បាប់នេះជាពិសេសការផ្តល់ប្រកាសនីយបត្រតក្កកម្ម ការផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ការចុះបញ្ជីគំនូរឧស្សាហកម្ម ការបដិសេធសំណុំលិខិតស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្ម ការបដិសេធសំណុំលិខិតស្នើសុំផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ឬការបដិសេធសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មអាចជាកម្មវត្ថុនៃការប្តឹងតវ៉ាដោយភាគីពាក់ព័ន្ធទៅតុលាការមានសមត្ថកិច្ចបាន ។ បណ្តឹងតវ៉ានោះត្រូវតែដាក់ក្នុងរយៈពេលបី(៣)ខែ ចាប់ពីថ្ងៃចេញសេចក្តីសម្រេច ។

## ផ្នែកទី ៨
## ការរំលោភ និងសកម្មភាពមិនស្របច្បាប់

**មាត្រា ១២៥.-**

ការរំលោភ គឺជាការអនុវត្តន៍សកម្មភាពរំលោភសិទ្ធិទាំងឡាយនៅក្នុងព្រះ-

រាជាណាចក្រកម្ពុជា ដូចមានចែងក្នុងផ្នែកទី ៩ នៃជំពូកទី ២ និងផ្នែកទី ៧ នៃជំពូកទី ៥ នៃច្បាប់នេះ ដោយបុគ្គលដទៃ និងដោយគ្មានការព្រមព្រៀងពីម្ចាស់ដែលបានទទួលសិទ្ធិការពារ ។

**មាត្រា ១២៦.-**

តាមបណ្តឹងរបស់ម្ចាស់ដែលបានទទួលសិទ្ធិការពារ ឬរបស់អ្នកទទួលអាជ្ញាប័ណ្ណ ក្រោយពីបានស្នើសុំទៅម្ចាស់ឱ្យប្តឹងទៅតុលាការមានសមត្ថកិច្ចដើម្បីដោះស្រាយបញ្ហាជាក់លាក់អ្វីមួយ ប៉ុន្តែម្ចាស់នោះបានបដិសេធ ឬខកខានមិនបានធ្វើតាមសំណើនោះទេ តុលាការមានសមត្ថកិច្ចអាចចេញសេចក្តីសម្រេចបណ្តោះអាសន្នដើម្បីទប់ស្កាត់ការរំលោភ ឬការរំលោភដែលប្រុងនឹងកើតមានឡើង សម្រេចឱ្យសងការខូចខាត និងផ្តល់នូវដំណោះស្រាយផ្សេងៗដែលមានចែងក្នុងច្បាប់ផ្សេងទៀតជាធរមាន។

**មាត្រា ១២៧.-**

ក្នុងករណីកម្មវត្ថុប្រកាសនីយបត្រតក្កកម្ម ឬវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ជាដំណើរការផលិតកម្មហើយត្រូវចោទប្រកាន់ថាបានប្រព្រឹត្តរំលោភដោយបង្កើតជាផលិតផល តាមរយៈការប្រើប្រាស់ដំណើរការផលិតកម្មរបស់អ្នកចោទប្រកាន់នោះ គឺមិនត្រូវចោទប្រកាន់ទេ ប្រសិនបើផលិតផលនោះ គឺជាផលិតផលថ្មី ហើយអ្នកដែលត្រូវចោទប្រកាន់ថារំលោភនោះ បានលើកភស្តុតាងមកបញ្ជាក់ថាផលិតផលនោះមិនត្រូវបានផលិតតាមដំណើរការផលិតកម្មដែលបានចោទប្រកាន់ថារំលោភនោះទេ ។

**មាត្រា ១២៨.-**

ក្នុងការទាមទាររកភស្តុតាងមុនដំណាក់ការជម្រះក្តី ដោយអនុលោមតាមមាត្រា ១២៧ នៃច្បាប់នេះ តុលាការមានសមត្ថកិច្ចត្រូវតែគិតគូរដល់ផលប្រយោជន៍ស្របច្បាប់របស់បុគ្គល ដែលត្រូវចោទប្រកាន់ថារំលោភ ដោយមិនធ្វើឱ្យលេចឮខ្ចរខ្ចាយអំពីការសម្ងាត់នៃការផលិត និងការសម្ងាត់នៃរបរជំនួញរបស់បុគ្គលដែល

ត្រូវចោទប្រកាន់នោះឡើយ ។

## ផ្នែកទី ៩
## ការអនុវត្តន៍សន្ធិសញ្ញាអន្តរជាតិ

**មាត្រា ១២៩.-**

បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញាអន្តរជាតិ អំពីកម្មសិទ្ធិឧស្សាហកម្មដែលព្រះរាជាណាចក្រកម្ពុជាជាភាគីមួយនៃសន្ធិសញ្ញានោះត្រូវយកមកអនុវត្ត ចំពោះបញ្ហាដែលទាក់ទងជាមួយនឹងច្បាប់នេះបានផងដែរ ។ ក្នុងករណីមានទំនាស់ជាមួយបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ បទប្បញ្ញត្តិនៃសន្ធិសញ្ញាអន្តរជាតិនោះត្រូវចាត់ទុកជាបទប្បញ្ញត្តិគោល ។

## ផ្នែកទី ១០
## បទបញ្ជា និងសេចក្តីណែនាំរដ្ឋបាល

**មាត្រា ១៣០.-**

រដ្ឋមន្ត្រីត្រូវចេញបទបញ្ជាចាំបាច់ណែនាំលំអិត អំពីការអនុវត្តន៍ច្បាប់នេះ។

ចំពោះការបង់កម្រៃដែលទាក់ទងទៅនឹងការដាក់សំណុំលិខិតស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងសុំចុះបញ្ជីគំនូរឧស្សាហកម្មត្រូវកំណត់ដោយសេចក្តីប្រកាសរួមរបស់ក្រសួងទទួលបន្ទុកឧស្សាហកម្ម និងក្រសួងទទួលបន្ទុកហិរញ្ញវត្ថុ ។

## ផ្នែកទី ១១
## ការបកស្រាយ

**មាត្រា ១៣១.-**

នៅក្នុងច្បាប់នេះ :

- **ចំណាត់ថ្នាក់អន្តរជាតិ** មានន័យថាចំណាត់ថ្នាក់ដែលអនុលោមតាមកិច្ចព្រមព្រៀងទីក្រុងឡូការណូ ដែលបង្កើតឡើងនូវចំណាត់ថ្នាក់អន្តរជាតិនៃគំនូរ

ឧស្សាហកម្ម ដែលបានកែសម្រួលចុងក្រោយ ។

- **រដ្ឋមន្ត្រី** មានន័យថារដ្ឋមន្ត្រីទទួលបន្ទុកឧស្សាហកម្ម ។

- **អនុសញ្ញាទីក្រុងប៉ារីស** មានន័យថាអនុសញ្ញាដែលបានចុះហត្ថលេខានៅទីក្រុងប៉ារីស ស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៨៨៣ ដែលបានកែសម្រួលចុងក្រោយ ។

- **កាលបរិច្ឆេទអាទិភាព** មានន័យថាជាកាលបរិច្ឆេទដែលបានដាក់សំណុំលិខិតស្នើសុំមុនគេបង្អស់ដែលប្រើប្រាស់ធ្វើជាមូលដ្ឋាន ដើម្បីទទួលសិទ្ធិអាទិភាព ដូចបានចែងនៅក្នុងអនុសញ្ញាទីក្រុងប៉ារីស ។

- **មន្ត្រីកាន់កាប់បញ្ជី** មានន័យថាប្រធាននាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ។

- **នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី** មានន័យថានាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មដែលត្រូវបង្កើតឡើងនៅក្រសួងទទួលបន្ទុកឧស្សាហកម្ម ។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ១៣២.-**

បុគ្គលណាមួយដែលផ្តល់ពត៌មានមិនពិតនៅក្នុងឯកសារ ដែលបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន(១.០០០.០០០)រៀល ដល់ប្រាំលាន (៥.០០០.០០០)រៀល ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ទៅប្រាំមួយ(៦)ខែ ឬត្រូវផ្តន្ទាទោសទាំងពីរខាងលើ ។ ក្នុងករណីមិនរាងចាលក្នុងរយៈពេលប្រាំ(៥)ឆ្នាំ គិតចាប់ពីពេលផ្តន្ទាទោសលើកមុន ត្រូវផ្តន្ទាទោសទ្វេដង ។

**មាត្រា ១៣៣.-**

បុគ្គលណាមួយដែលរំលោភដោយចេតនា ដូចមានចែងក្នុងមាត្រា ១២៥

ត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ពីប្រាំលាន(៥.០០០.០០០)រៀល ដល់ម្ភៃលាន (២០.០០០.០០០)រៀល ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពីមួយ(១)ឆ្នាំ ទៅប្រាំ(៥) ឆ្នាំ ឬត្រូវផ្តន្ទាទោសទាំងពីរខាងលើ ។ ក្នុងករណីមិនរាងចាល ក្នុងរយៈពេលប្រាំ(៥) ឆ្នាំ គិតចាប់ពីពេលផ្តន្ទាទោសលើកមុន ត្រូវផ្តន្ទាទោសទ្វេដង ។

**មាត្រា ១៣៤.-**

ក្នុងករណីបុគ្គលណាមួយ ត្រូវបានផ្តន្ទាទោស តុលាការមានសមត្ថកិច្ចអាច បញ្ជាឱ្យធ្វើការរឹបអូសទុកជាសម្បត្តិរដ្ឋ ឬបំផ្លាញចោលនូវទំនិញដែលរំលោភ និង សម្ភារៈឧបករណ៍ដែលយកមកប្រើប្រាស់ក្នុងការប្រព្រឹត្តិរំលោភ ។

**មាត្រា ១៣៥.-**

មន្ត្រីមានសមត្ថកិច្ចណាដែលបានខុសឆ្គងក្នុងការអនុវត្តន៍ភារកិច្ចរបស់ខ្លួន ដែលបានផ្តល់ឱ្យស្របតាមច្បាប់នេះ ត្រូវទទួលទោសរដ្ឋបាលដោយពុំទាន់គិតដល់ បទល្មើសព្រហ្មទណ្ឌផ្សេងទៀត ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**មាត្រា ១៣៦.-**

ផលិតផលឱសថ ដូចមានចែងក្នុងមាត្រា ៤ នៃច្បាប់នេះ មិនត្រូវការពារ ដោយប្រកាសនីយបត្រតក្កកម្ម រហូតដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ យោងតាម សេចក្តីប្រកាសពត៌មានស្តីពីកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា និងសុខ ភាពសាធារណៈនៃសន្និសីទថ្នាក់រដ្ឋមន្ត្រីរបស់អង្គការពាណិជ្ជកម្ម ពិភពលោកចុះថ្ងៃ ទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០១ នៅទីក្រុងដូហានៃប្រទេសកាតា ។

# ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ១៣៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០២ នាសម័យប្រជុំលើកទី ៩ នីតិកាលទី ២ ។

ភ្នំពេញ,ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០២

ប្រធានរដ្ឋសភា

នរោត្តម រណឫទ្ធិ